**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de droit et des Sciences Economoiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សុំកូនពេញលេញ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា. **ប៉ុល ម៉ាឌីលីន**

លោក. **ឯល សុខគ្រី**

សាស្ត្រាចារ្យណែនាំ

លោក **ភេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ម៉ុល ម៉ាឌីលីន** និងខ្ញុំបាទឈ្មោះ **ឯល សុខត្រី** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២០ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៩-២០២០។

ជាដំបូងពួកខ្ញុំទាំងពីរនាក់ ពិតជាមានសេចក្តីសោមនស្សយ៉ាងកក់ក្តៅជាទីបំផុត ដែលមានឱកាសថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

លោក ឪពុក **ម៉ុល និលឯក** និងអ្នកម្តាយ **ថ្លាង កុសល**

លោក ឪពុក **ស្លេះ ស្មាឯល** និងអ្នកម្តាយ **ឡឹប ម៉ែសំ**

ដែលបានផ្តល់កំណើតបញ្ញាស្មារតីដល់រូបកូន ព្រមទាំងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅ ផ្តល់ការសិក្សា ផ្តល់នូវព្រហ្មវិហារធម៌ដល់កូនប្រុសស្រី ការលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងថវិកាដល់កូន បានឲ្យកូនរៀនសូត្រចំណេះដឹងរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។ មាតាបិតុគុណដ៏ធំធេងរបស់លោក គឺគ្មានអ្វីដែលមានតម្លៃក្នុងលោកនេះអាចប្រៀបផ្ទឹមស្មើបាននោះឡើយ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណចំពោះ **សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់ឱកាសឲ្យពួកខ្ញុំបានក្រេបយកចំណេះដឹង វិជ្ជាជីវៈ និងខិតខំយកចិត្តទុកដាក់ផ្តល់នូវពុទ្ធិល្អយ៉ាងពិតប្រាកដសម្រាប់យើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រនេះ។

និងសូមថ្លែងអំណរគុណចំពោះលោកគ្រូ **កេត សុជាតិ** ដែលជាគ្រូដឹកនាំការសរសេរសារណាមួយនេះ តែងតែផ្តល់ចំណេះដឹង របៀបនៃការបំពេញការងារ បទពិសោធន៍ល្អៗ ការផ្តល់នូវដំបូន្មាន យោបល់ និងជួយកែសម្រួលចំពោះខ្លឹមសារដែលពួកយើងខ្ញុំបានសរសេរឲ្យក្លាយជាសៀវភៅមួយក្បាលប្រកបដោយអត្ថន័យ និងមានខ្លឹមសារ។

ជាទីបញ្ចប់ពួកខ្ញុំសូមប្រសិទ្ធិពរជ័យជូនលោកអ្នកមានគុណទាំងអស់ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់គ្រប់រូប ឲ្យជាប់នូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជោគជ័យគ្រប់ភារកិច្ចទាំងអស់ ជួបតែសំណាងល្អ សុខភាពល្អ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** រយៈពេល៤(បួន)ឆ្នាំរួចមក ខ្ញុំក៏ដូចជាមិត្តរួមក្រុមទទួលបាននូវចំណេះដឹងដែលទាក់ទងនឹងវិស័យគតិយុត្តយ៉ាងទូលំទូលាយ។ នៅក្នុងចំណោមមុខវិជ្ជា និងមេរៀនដែលបានសិក្សាកន្លងមក ព្រមទាំងទទួលបានការចង្អុលង្ហាញ ការណែនាំយ៉ាងយកចិត្តទុកដាក់ពីសាស្ត្រាចារ្យណែនាំ ដែលមានបទពិសោធន៍ខ្ពស់ទាក់ទងទៅនឹងវិស័យច្បាប់ យើងខ្ញុំទាំងពីរនាក់មានចំណាប់អារម្មណ៍ លើកយកប្រធានបទ "**សុំកូនពេញលេញ**" មកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សារបស់ខ្ញុំទាំងពីរអ្នក។

មូលហេតុដែលនាំឲ្យក្រុមស្រាវជ្រាវរបស់ខ្ញុំជ្រើសរើសប្រធានបទនេះមកសរសេរ គឺខ្ញុំទាំងពីរមានបំណងចង់បណ្តុះគំនិតមិត្តអ្នកអានចូលរួមការពារ និងលើកស្ទួយផលប្រយោជន៍កុមារតាមរយៈសារណាមួយនេះ។ម្យ៉ាងទៀតដោយមានការចង្អុលបង្ហាញពីសាស្ត្រាចារ្យណែនាំផងនោះ និងយោងទៅតាមស្ថានភាពសង្គមតរៀងមកដល់បច្ចុប្បន្នឃើញថា ប្រជាជនកម្ពុជាមួយចំនួនតែងតែធ្វើការសុំកូនដោយប្រើតាមវិធីយកលុយជាថ្នូរប្តូរយកកូនអ្នកដែលមានជីវភាពខ្វះខាតមកចិញ្ចឹម ដោយមិនបានបំពេញលក្ខខណ្ឌគតិយុត្ត ទាំងអស់នេះហើយដែលបង្កឲ្យវិវាទកើតឡើង។

ការលើកយកប្រធានបទនេះមកចងក្រងជាសៀវភៅនេះបាន គឺពឹងផ្អែកលើចំណេះដឹង ការណែនាំពីសាស្ត្រាចារ្យ ព្រមទាំងឯកសារពាក់ព័ន្ធជាច្រើនដទៃទៀតដែលមានស្រាប់ ដើម្បីជាប្រទីបក្នុងការស្រាយ ចម្ងល់ខ្លួនឯង និងទុកជាឯកសារបំភ្លឺដល់បងប្អូនសិស្សនិស្សិតក្រោយៗ ក៏ដូចជាប្រជាពលរដ្ឋខ្មែរ បានយល់ដឹងកាន់តែច្បាស់ពីបញ្ហាសុំកូនពេញលេញទៅតាមវិធានច្បាប់។

នៅក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និងជាអ្នកចងក្រងឯកសារនេះ សូមការអភ័យទោស និងអធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលបានកើតឡើងដោយអចេតនាទៅលើអក្ខរាវិរុទ្ធ ពាក្យពេជ្រខ្លឹមសារ និងអត្ថន័យ ព្រោះថាទោះជាមានការផ្ទៀងផ្ទាត់ច្រើនលើកច្រើនដងយ៉ាងណា និងការយកចិត្តទុកដាក់ខ្លាំងប៉ុណ្ណាក្តី ក៏នៅមានការភ្លាត់ ភ្លេចភ្លាំង បង្កឲ្យមានកំហុសដោយមិនអាចជៀសផុតបាន។ ដូចនេះខ្ញុំទាំងពីរអ្នកមានតែសូមការអធ្យាស្រ័យពីបងប្អូនមិត្តអ្នកអាន និងបើកចិត្តទទួលយកការរិះគន់ក្នុងន័យស្ថាបនាទាំងអស់ដើម្បីអភិវឌ្ឍខ្លួន ព្រមទាំងទុកជាបទពិសោធន៍។

## មាតិកា

**ទំព័រ**


**សេចក្តីផ្តើម**............................................................................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅ និងលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ**

**ផ្នែកទី១៖លក្ខខណ្ឌគ្រឹះនៃការបង្កើតសុំកូនពេញលេញ**.......................................... ៥

១.១.លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្តាយចិញ្ចឹម.......................................................................... ៥

១.២.លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្តាយបង្កើត.......................................................................... ៧

១.៣.លក្ខខណ្ឌពាក់ព័ន្ធនឹងកុមារដែលនឹងត្រូវក្លាយជាកូនសុំ.................................................... ៩

**ផ្នែកទី២៖លក្ខខណ្ឌទម្រង់នៃការបង្កើតសុំកូនពេញលេញ**...................................... ១១

២.១.ការដាក់ពាក្យសុំ........................................................................................................ ១១

២.២.ការពិនិត្យពាក្យសុំ...................................................................................................... ១២

២.៣.អំឡុងពេលសាកល្បងចិញ្ចឹម ..................................................................................... ១៣

**ផ្នែកទី៣៖ការវិនិច្ឆ័យសេចក្តី និងការចេញដីកាសម្រេច**.......................................... ១៤

៣.១.ការពិនិត្យលើភាពចាំបាច់នៃការបង្កើតសុំកូន.................................................................. ១៤

៣.២.ការចេញសេចក្តីសម្រេច............................................................................................. ១៦

**ជំពូកទី ២**

**អានុភាពក្រោយដីកាសម្រេចសុំកូនពេញលេញចូលជាស្ថាពរ**

**ផ្នែកទី១៖អានុភាពលើទំនាក់ទំនងញាតិនិងទ្រព្យសម្បត្តិ**........................................ ១៨

១.១.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះ កូនសុំ........................................... ១៨

១.២.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះឪពុកម្តាយបង្កើត.............................. ១៩

១.៣.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះឪពុកម្តាយចិញ្ចឹម.............................. ១៩

**ផ្នែកទី២៖ការចុះបញ្ជីអត្រានុកូលដ្ឋាន**...................................................................... ២០

២.១.ការចុះបញ្ជី និងការកែប្រែអាត្រានុកូលដ្ឋានកំណើតរបស់កូនសុំ......................................... ២០

២.២.ការរក្សាការសម្ងាត់អត្រានុកូលដ្ឋានកំណើតរបស់កូនសុំ.................................................. ២១

**ផ្នែកទី៣៖សិទ្ធិដឹងអំពីកំណើតខ្លួន**............................................................................ ២១

៣.១.ការដាក់ពាក្យសុំទៅតុលាការ...................................................................................... ២១

៣.២.ការជួបប្រាស្រ័យជាមួយឪពុកម្តាយបង្កើត និងបងប្អូនញាតិលោហិត.................................. ២២

# ជំពូកទី៣
# ការកាត់កាលសុំកូនពេញលេញ

**ផ្នែកទី១៖នីតិវិធីនៃការកាត់កាល**........................................................................ ២៣

១.១.លក្ខខណ្ឌទម្រង់........................................................................................ ២៣

១.២.លក្ខខណ្ឌសារធាតុ.................................................................................... ២៤

**ផ្នែកទី២៖ការវិនិច្ឆ័យ និងសេចក្តីសម្រេច**.................................................................. ២៥

២.១.ភាពចាំបាច់នៃការសុំកាត់កាល......................................................................... ២៥

២.២.ការចេញសេចក្តីសម្រេចកាត់កាល...................................................................... ២៥

**ផ្នែកទី៣៖អានុភាពនៃការកាត់កាល**........................................................................ ២៦

៣.១.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះឪពុកម្តាយបង្កើត.............................. ២៦

៣.២.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះឪពុកម្តាយចិញ្ចឹម............................. ២៧

៣.៣.អានុភាពទៅលើឋានៈបុគ្គល និងទ្រព្យសម្បត្តិ ចំពោះកូនសុំ.......................................... ២៧

**សេចក្តីសន្និដ្ឋាន**................................................................................................ ២៩

**អនុសាសន៍**...................................................................................................... ៣០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

មនុស្សគ្រប់រូបសុទ្ធតែចង់រស់នៅមានភាពសុខស្រួល មិនថាបុគ្គលណា មានឋានៈប៉ុណ្ណាក្តី មិនថាក្មេង ឬ ចាស់គឺសុទ្ធតែត្រូវការភាពកក់ក្តៅពីអ្នកដែលជិតស្និតបំផុតដែលគេហៅថា គ្រួសារ។ ក្នុងការបង្កើតគ្រួសារមួយ ត្រូវធ្វើឡើងដោយការរៀបអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី និងក្នុងគោលបំណងចំបងមួយ នៃអាពាហ៍ពិពាហ៍នោះគឺបង្កើតកូនសម្រាប់បន្តវង្សត្រកូលរបស់ខ្លួន។ ប៉ុន្តែគ្រប់ក្រុមគ្រួសារទាំងអស់មិនប្រាកដថា នឹងអាចសម្រេចនូវគោលបំណងក្នុងការបង្កើតកូនបានទេ ដោយសារតែភាគីណាមួយអសមត្ថភាពក្នុងការមានកូន។ ចំណែកឯប្រជាជនខ្លះទៀត មានកូនច្រើន ប៉ុន្តែមានជីវភាពក្រីក្រ បែកបាក់គ្រួសារ គ្មានមុខរបរពិតប្រាកដ ការរស់នៅពោរពេញដោយកង្វះខាត ហើយអ្នកដែលប៉ះទង្គិចខ្លាំងជាងគេនោះគឺ កុមារ។ កុមារ គឺងាយរងគ្រោះណាស់ ភាគច្រើនកើតឡើងលើ កុមារកំព្រា កុមារដែលត្រូវបានបោះបង់ចោល កុមារដែលខ្វះការថែរក្សា ឬ ការយកចិត្តទុកដាក់ ពីឪពុកម្តាយបង្កើត។ ដោយហេតុអស់ទាំងនេះហើយទើបអ្នកច្បាប់បានបង្កើតរបបមួយ ហៅថារបបសុំកូន។ របបនៃការសុំកូនមានចែងនៅក្នុងក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ១៩៦៧ ក៏បានបញ្ញត្តិអំពីសុំកូននេះ ក្រោយមករបបនៃការសុំកូន ត្រូវបានគេកែប្រែបន្ថែមទៀតនៅក្នុងឆ្នាំ១៩៨៩ យើងក៏មានច្បាប់ពិសេស គឺច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ។ តាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ របបសុំកូនខុសពីរបបសុំកូននៅក្នុងក្រមរដ្ឋប្បវេណីចាស់ ព្រោះថាវាបានបង្កើតឡើងត្រឹមកិច្ចសន្យារវាងភាគីប៉ុណ្ណោះ ដោយមិនចាំបាច់ធ្វើតាមផ្លូវតុលាការទេ។ ប៉ុន្តែដើម្បីឲ្យការសុំកូនមួយមានការការពារពីតម្រាផ្លូវច្បាប់ មានអានុភាពច្បាស់លាស់ ភាពជាដាច់ខាតគឺត្រូវធ្វើតាមរយៈតុលាការ ដូច្នេះហើយទើបគេបានពីឡើងពីច្បាប់ទាំងពីរខាងលើ ចម្រាញ់បញ្ចូលគ្នា និងវិភាគឡើងវិញ ហើយសម្រេចក្រោយមកក៏បង្កើតបានក្រមរដ្ឋប្បវេណីមួយទៀត ក្នុងឆ្នាំ២០០៧។ ក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តិឲ្យប្រើនៅឆ្នាំ ២០០៧ នេះ បានចែង អំពីការសុំកូន ផងដែរ ហើយត្រូវបានគេបែងចែកជាពីរប្រភេទ សុំកូនពេញលេញ សុំកូនធម្មតា ក្នុងការសុំកូននីមួយៗ គឺមានភាពលំបាកដូចគ្នា គឺពាក់ព័ន្ធនឹងនីតិវិធីរបស់តុលាការ និងអាជ្ញាធរទៀតផង ហេតុនេះហើយ នាំឲ្យមានភាពទូលំទូលាយ និងស្មុគស្មាញពេក ទើបពួកខ្ញុំសុំលើកយកតែប្រធានបទ "សុំកូនពេញលេញ" មកធ្វើការសិក្សាស្រាវជ្រាវនៅក្នុងសារណាមួយនេះ។

ការបង្កើតឲ្យមានប្រព័ន្ធសុំកូននេះឡើង ដើម្បីឲ្យមានសន្តតិជន នៃទ្រព្យសម្បត្តិរបស់គ្រួសារឪពុកម្តាយចិញ្ចឹម ហេតុនេះតាមរយៈកូនសុំគេអាចទទួលបាននូវសន្តតិជន ដែលជាអ្នកបន្តសន្តតិកម្មរបស់ឪពុកម្តាយចិញ្ចឹម។ សុំកូនក៏មានគោលបំណងបង្កើតអ្នកមានកម្លាំងការងារ និងមើលថែរក្សាគ្រួសារឪពុកម្តាយចិញ្ចឹមដែរ ហេតុនេះ តាមរយៈសុំកូនឪពុកម្តាយចិញ្ចឹម ដែលពុំមានកូនអាចទទួលបានកូន ដើម្បីទទួលការមើលថែពីកូននៅពេលចាស់ទៅ។ លើសពីនេះទៅទៀត សុំកូនមានប្រយោជន៍ដល់កុមារយ៉ាងខ្លាំងគឺកុមារត្រូវមានអ្នកផ្តល់អាហារ

កិច្ច ឬមើលថែខ្លួន មួយវិញទៀតកុមារងាយទទួលរងនូវអំពើអបាយមុខជាច្រើន ដូចជាអំពើហិង្សា ការធ្វើទារុណកម្ម ។ល។

**ដើម្បីបង្កើតសុំកូនពេញលេញបានតើមានលក្ខខណ្ឌអ្វីខ្លះ?** ហើយ **តើនីតិវិធីនៃការសុំកូននេះមានដំណើរយ៉ាងណាខ្លះ?** ចុះនៅពេលដែលការសុំកូន ត្រូវបានបង្កើត វិញនោះ **តើការសុំកូនមានអានុភាពយ៉ាងដូចម្ដេចខ្លះ?** ហើយម្យ៉ាងទៀតនៅពេលដែលទំនាក់ទំនងនោះមានការបាក់បែកដោយសារអំពើហិង្សា ឬ ការមិនមើលថែ **តើការកាត់កាលសុំកូនអាចធ្វើបានដែរឬទេ ដោយរបៀបណាខ្លះ?**

យើងខ្ញុំធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ ការសុំកូនពេញលេញ ក្នុងគោលបំណងចង់យល់ដឹងលំអិតអំពីការសុំកូននេះមានដំណើរការយ៉ាងមិចខ្លះ ហើយណាមួយចង់ចែកចាយជាចំណេះដឹងទៅអ្នកដែលចង់សុំកូនគេមកចិញ្ចឹម សម្រាប់ពួកគាត់ដែលចង់បានកូនត្រឹមត្រូវតាមលក្ខណៈគតិយុត្ត ដូចញាតិដែលបានកំណត់ដោយច្បាប់ និងមួយវិញទៀតនៃបំណងរបស់ពួកខ្ញុំ គឺការការពារកុមារដោយសារកុមារជាទំពាំងស្នងឫស្សីមួយដ៏សំខាន់នាពេលអនាគត យើងគួរតែមើលថែពួកគេឲ្យបានម៉ត់ចត់ និងដោយយកចិត្តទុកដាក់ ជៀសវាងពីអំពើអាក្រក់ផ្សេងៗផងដែរ។

ចំពោះប្រធានបទដែលពួកខ្ញុំធ្វើការស្រាវជ្រាវនេះ គឺសិក្សាតែក្នុងរង្វង់នៃការសុំកូនពេញលេញតែប៉ុណ្ណោះ ដោយមិនបានធ្វើការពិភាក្សាពី ការសុំកូនធម្មតា និងអន្តរប្រទេស នោះទេ។

ដោយសារណាមួយនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះការសុំកូននៅប្រទេសកម្ពុជាពីព្រោះក្នុងសារណាមួយក្បាលនេះបានបង្ហាញពីដំណើរការនៃនីតិវិធី និងលក្ខខណ្ឌមួយចំនួនដែលទាក់ទងនឹង ការសុំកូនពេញលេញ នៅកម្ពុជា។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹងគំនិតប្រជាពលរដ្ឋខ្មែរ និងនិស្សិតជំនាន់ក្រោយៗទៀត ឲ្យយល់ដឹងពីអានុភាពគតិយុត្ត និងបញ្ឈប់ការសុំកូនដែលមិនមានការទទួលស្គាល់ពីច្បាប់ ផងដែរ។

ការតាក់តែងសារណានេះអាចធ្វើឡើងបានជោគជ័យដោយ ពឹងផ្អែកទៅលើកត្តាចម្បងមួយចំនួនដូចជាឯកសារគតិយុត្តមួយចំនួនរួមមាន រដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ច្បាប់គោលនានា ព្រមទាំងសៀវភៅបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធផ្សេងៗដែលទទួលបានពីបណ្ណាល័យ និងសារណាបញ្ចប់ការសិក្សាខ្លះៗរបស់សិស្សច្បងជំនាន់មុន។ មិនតែប៉ុណ្ណោះក៏មានការផ្ដល់ជាមតិយោបល់ពីសំណាក់សាស្ត្រចារ្យណែនាំសារណា និងការសាកសួរពីលោក លោកស្រីចៅក្រម ព្រះរាជអាជ្ញាដែលជាអ្នកអនុវត្តជាក់ស្ដែង។

នៅក្នុងសារណានេះ ត្រូវបានបែងចែកជា ៣ជំពូកធំៗ ដូចខាងក្រោម៖

**ជំពូកទី១ ៖ សញ្ញាណទូទៅ និងលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ** នៅក្នុងជំពូកនេះពួកខ្ញុំនឹងធ្វើការបកស្រាយពីនិយមន័យ លក្ខខណ្ឌ និងការចេញដីកាសម្រេច ជាដើម។

**ជំពូកទី២៖ អានុភាពក្រោយដីកាសម្រេចស្នុំកូនពេញលេញចូលជាស្ថាពរ** សម្រាប់ជំពូកនេះវិញ គឺពន្យល់ពី ក្រោយពេលដីកាសម្រេចស្នុំកូនរបស់តុលាការបានចូលជាស្ថាពរហើយ នោះអានុភាពនៃស្នុំកូនពេញលេញនេះមានដំណើរយ៉ាងដូចម្តេចខ្លះ ។

**ជំពូកទី៣៖ ការកាត់កាលស្នុំកូនពេញលេញ** នៅក្នុងជំពូកចុងក្រោយគឺនិយាយពីការកាត់កាល ឬ ការបញ្ចប់នូវស្នុំកូនពេញលេញ ប្រាប់ពីរបៀបនៃការដាក់ពាក្យបណ្តឹង លក្ខខណ្ឌមួយចំនួន និងអានុភាពនៃការកាត់កាល។

# ជំពូកទី១

# សញ្ញាណទូទៅ និងលក្ខខណ្ឌនៃការបង្កើតសុំក្លូនពេញលេញ

# ជំពូកទី ១

## សញ្ញាណទូទៅ និងលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

ក្រមរដ្ឋប្បវេណី គឺជាច្បាប់មួយដែលបានបង្កើតនូវសិទ្ធិ និងទំនាក់ទំនងញាតិភាពរវាងឪពុកម្ដាយបង្កើត និងកូនបង្កើត ឲ្យមានចំណងគត្តិយុត្តរវាងគ្នាទៅវិញទៅមក ប៉ុន្តែក្រៅពីទំនាក់ទំនងរវាងឪពុកម្ដាយបង្កើត និងកូនបង្កើត ក្រមរដ្ឋប្បវេណី ក៏បានបង្កើតឲ្យមានរបបមួយ ដែលអនុញ្ញាតិឲ្យបុគ្គល គ្មានទំនាក់ទំនងញាតិលោហិតជាមួយនឹងគ្នា អាចក្លាយជាញាតិ និងមានចំណងគត្តិយុត្តរវាងគ្នាទៅវិញទៅមកបាន ដែលរបបមួយនោះ ត្រូវបានគេកំណត់ថា ជា **ការសុំកូន** ។

ការសុំកូន ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណី ភាគទី៥ គន្តីទី៧ ស្តីពីញាតិ ជំពូកទី៤ ផ្នែកទី២ ដែលបានកំណត់ពីការសុំកូន ប្រភេទនៃការសុំកូន លក្ខខណ្ឌ រួមទាំងអានុភាពនៃការសុំកូននីមួយៗ។

ការសុំកូន ត្រូវបានបែងចែកជា **២ប្រភេទ** គឺ៖

- សុំកូនពេញលេញ
- សុំកូនធម្មតា

ការបង្កើតសុំកូនទាំងពីរប្រភេទនេះ មានលក្ខណៈស្មុគស្មាញ និងមានលក្ខខណ្ឌតាមផ្លូវច្បាប់កំណត់យ៉ាងតឹងរឹង គឺគោលបំណងដើម្បីការពារផលប្រយោជន៍កុមារ និងបង្កើតនៅគ្រួសារមួយដ៏កក់ក្តៅសម្រាប់ក្មេង ។

ក្រោយពីបានធ្វើការសិក្សាទៅលើរបបគតិយុត្តមួយនេះ ឃើញថាវាពិតជាមានភាពលំបាក និងធំទូលាយយ៉ាងខ្លាំងក្នុងការបកស្រាយ នឹងលើកយកមកធ្វើជាប្រធានបទ ទើបយើងខ្ញុំ សម្រេចចិត្តធ្វើការស្រាយតែទៅលើរបបនៃការសុំកូនមួយប្រភេទ គឺការ **សុំកូនពេញលេញ** ដើម្បីឲ្យការបកស្រាយមានភាពលំអិត និងច្បាស់លាស់។ តែចំណុចសំខាន់ជាងនេះ តើការសុំកូននេះ ត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច និងត្រូវអនុវត្តដោយរបៀបណាដើម្បីឲ្យមានអានុភាព និងត្រឹមត្រូវតាមច្បាប់។ ដូច្នេះ ដើម្បីឲ្យប្រធានបទនេះ មានភាពកាន់តែល្អ និងច្បាស់យើងខ្ញុំទាំងពីរនាក់សុំលើកបង្ហាញពីច្បាប់នីតិវិធី ២ប្រភេទទៀត ដែលនឹងត្រូវយកមកធ្វើការបកស្រាយ បញ្ចូលក្នុងប្រធានបទនេះ ផងដែរគឺ ជាច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង និងច្បាប់នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលទើបតែអនុម័តឲ្យប្រើជាផ្លូវការក្នុងឆ្នាំ ២០១០។

**សុំកូនពេញលេញ** ដែលជាការបង្កើតចំណងញាតិលោហិតតាមផ្លូវច្បាប់ ព្រមទាំងទទួលបាននូវឋានៈសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត ជាមួយឪពុកម្តាយបង្កើត។ ការបង្កើតសុំកូនពេញលេញ ចាំបាច់ត្រូវតែមានអន្តរាគមន៍ពីតុលាការក្នុងការសម្រេចបង្កើត ទើបទំនាក់ទំនងនេះមានអានុភាពតាមផ្លូវច្បាប់។

អនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ការបង្កើតសុំកូនពេញលេញ គឺត្រូវតែឆ្លងកាត់នីតិវិធីតុលាការ ដោយតុលាការដើរតួជាអ្នកពិនិត្យនូវលក្ខខណ្ឌសារធាតុ និង

ចេញដីកាសម្រេច។ ការពិនិត្យលក្ខខណ្ឌមានភាពចាំបាច់ណាស់ ដោយតុលាការត្រូវតែផ្ទៀងផ្ទាត់ឲ្យបានច្បាស់លាស់ជាមួយក្រមរដ្ឋប្បវេណី មុននឹងសម្រេចឲ្យបង្កើតទំនាក់ទំនងសុំកូនដែលលក្ខខណ្ឌនោះរួមមានលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

## ផ្នែកទី១៖ លក្ខខណ្ឌគ្រឹះនៃការបង្កើតសុំកូនពេញលេញ

**សុំកូនពេញលេញ** គឺជារបបគតិយុត្តមួយ ដែលបង្កើតធ្វើឡើងក្នុងគោលបំណងផ្ដល់នូវការការពារផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំ សំដៅឲ្យមានការបង្កើតជាគ្រួសារថ្មីមួយដល់កុមារ បន្ថែមពីនេះ ការបង្កើតសុំកូន ក៏មានសារប្រយោជន៍ចំពោះឪពុកម្ដាយចិញ្ចឹមផងដែរ ដោយសារច្បាប់បានបង្កើតសិទ្ធិ និងឋានៈរបស់កូនសុំ ដូចគ្នានឹងកូនបង្កើត ដូច្នេះហើយឪពុកម្ដាយចិញ្ចឹម ដែលគ្មានកូនបន្តវង្សត្រកូល បន្តសន្តតិកម្ម និងគ្មានកូនផ្ដល់អាហារកាតព្វកិច្ចពេលខ្លួនមានវ័យចំណាស់ ក៏អាចអាស្រ័យផលប្រយោជន៍ពីរបបមួយនេះ បានដូចគ្នាផងដែរ។

អាស្រ័យហេតុនេះ ដើម្បីអាចការពារផលប្រយោជន៍របស់កូនសុំ និងឪពុកម្ដាយសុំ ក្រមរដ្ឋប្បវេណីបានកំណត់អំពីលក្ខខណ្ឌគ្រឹះ ពោលគឺ លក្ខខណ្ឌសារធាតុ ដែលកំណត់អំពីលក្ខណៈសម្បត្តិរបស់ឪពុកម្ដាយចិញ្ចឹមជាចំណុចសារវន្ត និងភាពចាំបាច់ក្នុងការបង្កើតសុំកូន ដែលតុលាការត្រូវពិនិត្យឲ្យបានម៉ត់ចត់ ព្រមទាំងពិនិត្យលើលក្ខខណ្ឌពាក់ព័ន្ធនឹងកូនសុំ ដែលក្រមរដ្ឋប្បវេណីបានកំណត់។

### ១.១.លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្ដាយចិញ្ចឹម

បុគ្គល ដែលមានគោលបំណងចង់បង្កើតសុំកូន ត្រូវតែជាបុគ្គល ដែលមានលទ្ធភាព អាចចិញ្ចឹមបីបាច់ និងមើលថែទាំកូនសុំបានយ៉ាងល្អ និងអាចផ្ដល់ភាពកក់ក្ដៅ ដូចគ្នាទៅនឹងឪពុកម្ដាយបង្កើត និងកូនបង្កើត។

កូនសុំ នឹងត្រូវទៅរស់នៅជាមួយនឹងឪពុកម្ដាយចិញ្ចឹម គឺក្នុងនាមជាក្រុមគ្រួសារថ្មីមួយ ដែលឪពុកម្ដាយចិញ្ចឹមត្រូវមានករណីយកិច្ចចំពោះកូនសុំនោះ ហេតុនេះ ឪពុកម្ដាយចិញ្ចឹមត្រូវមានលក្ខណៈសម្បត្តិ ឬ ត្រូវបំពេញនូវលក្ខខណ្ឌដូចជា៖

#### ១.១.១.ស្ថានភាពឋានៈបុគ្គលរបស់ឪពុកម្ដាយចិញ្ចឹម

ក្រមរដ្ឋប្បវេណី បានកំណត់ថា បុគ្គលដែលអាចក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមបាន ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[1] ពីព្រោះគោលបំណងចម្បងនៃការបង្កើតសុំកូនពេញលេញ គឺជាការផ្ដល់គ្រួសារដ៏ពេញលេញ និងមានលំនឹងគ្រប់គ្រាន់មួយសម្រាប់កូនសុំ ដែលក្នុងគ្រួសារនោះត្រូវមានទាំងឪពុកចិញ្ចឹម និងម្ដាយចិញ្ចឹម។ អាស្រ័យហេតុនេះ បុគ្គលដែលមិនមានសហព័ទ្ធមិនអាចបង្កើតសុំកូនពេញលេញបានឡើយ។

[1] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០០៨ កថាខណ្ឌទី១

### ១.១.២.អាយុរបស់ឪពុកម្តាយចិញ្ចឹម

ដោយសារ ការបង្កើតសុំកូនពេញលេញ គឺជាការផ្តល់គ្រួសារដ៏ពេញលេញ ដូច្នេះអាយុរបស់ឪពុកម្តាយចិញ្ចឹម ក៏ជាលក្ខខណ្ឌចម្បង ដែលតុលាការត្រូវពិនិត្យពិចារណាផ្ទៀងផ្ទាត់ឲ្យបានល្អិតល្អន់។ ដូចនេះ ទើបក្រមរដ្ឋប្បវេណី បានកំណត់លក្ខខណ្ឌច្បាស់លាស់អំពីអាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹម និងគម្លាតអាយុអប្បបរមារវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ។

ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី **២៥ (ម្ភៃប្រាំ)** ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច **២០ (ម្ភៃ) ឆ្នាំ**[2]។ បន្ថែមពីការកំណត់ពីអាយុអប្បរមារបស់ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ក្រមរដ្ឋប្បវេណី ក៏បានកំណត់ផងដែរពីគម្លាតអប្បបរមានៃអាយុរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលត្រូវមានគម្លាតគ្នា ២០ (ម្ភៃ)ឆ្នាំ។

**ឧទាហរណ៍៖** លោក **ចេត** និង នាង **សាយ** ពួកគាត់បានរៀបអាពាហ៍ពិពាហ៍ ជាប្តីប្រពន្ធនឹងគ្នា។ លោក **ចេត** គាត់មានអាយុ **៣៥ឆ្នាំ** រីឯនាង **សាយ** គាត់មានអាយុ **៣០ឆ្នាំ**។ ពួកគេក៏បានពិភាក្សាគ្នា ឬ សហការគ្នាសម្រេចចិត្តចង់សុំកូនឈ្មោះ **បញ្ញា** យកមកចិញ្ចឹមដោយសុំកូនពេញលេញ ហើយក្នុងអំឡុងពេលនោះ **បញ្ញា** គេមានអាយុទើបតែ **៥ឆ្នាំ**។ ដូច្នេះ ក្នុងករណីនេះ ពួកគេអាចធ្វើការសុំកូនបាន ពីព្រោះគម្លាតរវាងអាយុរបស់លោក **ចេត** និងនាង **សាយ** ជាមួយអាយុរបស់ **បញ្ញា** គឺមានគម្លាតគ្នា **៣០ឆ្នាំ** សមស្របទៅតាមច្បាប់កំណត់ ។

ការកំណត់ឲ្យឪពុកម្តាយចិញ្ចឹម ត្រូវបំពេញលក្ខខណ្ឌគម្លាតអប្បបរមាក្នុងការសុំកូនពេញលេញ ពីព្រោះនៅពេលដែលអាយុរបស់ឪពុកចិញ្ចឹម និងម្តាយចិញ្ចឹម ក្មេងពេក នោះលទ្ធភាព និងបទពិសោធន៍នៃការថែរក្សាកូននៅមានកម្រិតខ្សោយ និងនៅតិចពេក ដែលនាំអោយកូនមិនអាចទទួលបានការថែរទាំដែលត្រឹមត្រូវ ម៉្យាងវិញទៀតពួកគេមិនអាចផ្តល់នូវគ្រួសារដែលល្អប្រសើរ ជាងឪពុកម្តាយបង្កើតបានឡើយ ហេតុនេះហើយ ទើបច្បាប់មានការតឹងរឹងចំពោះលក្ខខណ្ឌនៃអាយុរបស់ឪពុកម្តាយ ដែលមានបំណងសុំកូនពេញលេញនេះ។

### ១.១.៣.គោលការណ៍សហការរបស់ឪពុកម្តាយចិញ្ចឹម

ក្នុងការបង្កើតសុំកូនពេញលេញ ត្រូវតែធ្វើឡើងដោយមានការសហការគ្នារវាងប្តីប្រពន្ធ (ឪពុកម្តាយចិញ្ចឹម) មានន័យថា ប្តី ឬ ប្រពន្ធ តែម្ខាងមិនអាចធ្វើការសុំកូនបានទេ[3]។ ប្តីប្រពន្ធ ដែលមានបំណងសុំកូនត្រូវមានឆន្ទៈរួមគ្នា សហការគ្នា និងដាក់ពាក្យសុំរួមគ្នា ក្នុងការបង្កើតទំនាក់ទំនងសុំកូន ដែលអាចហៅថាជា គោលការណ៍សហការគ្នារវាងប្តីប្រពន្ធក្នុងការបង្កើតសុំកូនពេញលេញ។ ច្បាប់បង្កើតឲ្យមានគោលការណ៍សហការនេះ គឺដោយសារចង់បង្កើតគ្រួសារ ដែលកក់ក្តៅសម្រាប់ក្មេង មិនមែនជាគ្រួសារដែលមានតែឪពុកស្រលាញ់តែ

---

[2] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០០៩

[3] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០០៨ កថាខណ្ឌទី២

ម្ខាង ឬម្តាយស្រលាញ់តែម្ខាងទេ។ បន្ថែមពីនេះ ដោយសារការសុំកូន គឺជាការចាប់ចងទំនាក់ទំនងញាតិរវាង ឪពុកម្តាយចិញ្ចឹម និងកូនសុំ នឹងអាចផ្តល់នូវការបន្តលើសន្តតិកម្មរវាងគ្នាទៅវិញទៅមក ដូច្នេះហើយ គោលការណ៍សហការ គឺជាគោលការណ៍មួយដ៏សំខាន់បំផុត។

**ឧទាហរណ៍ ៖ ក** និង **ខ** ជាប្តីប្រពន្ធ។ ក្នុងករណីដែល **ក** យក **អ** ដែលជាកូនរបស់ **គ** និង **ឃ** ជាកូនសុំពេញលេញ នោះ **ក** មិនអាចក្លាយជាឪពុកម្តាយចិញ្ចឹមតែម្នាក់ឯងបានឡើយ ហើយ **ក** និង **ខ** មានភាពចាំបាច់ត្រូវក្លាយជាឪពុកម្តាយចិញ្ចឹមជាមួយគ្នា។ ក្នុងករណីដែល **ក** មិនមានសហព័ទ្ធ **ក** មិនអាចធ្វើការសុំកូនពេញលេញបានឡើយ។ មូលហេតុ គឺដោយសារតែសុំកូនពេញលេញជាប្រព័ន្ធដែលបង្កើតឲ្យមានទំនាក់ទំនងដូចនឹងឪពុកម្តាយ និងកូនពិតប្រាកដដើម្បីកូនសុំ។ ពោលគឺដោយសារតែវានឹងល្អជាងសម្រាប់កូនសុំ ដែលកូនសុំតែម្នាក់មានឪពុកម្តាយចិញ្ចឹម២នាក់។

ជាបដិបញ្ញត្តិ គោលការណ៍នេះត្រូវបានលើកលែង ចំពោះករណីដូចខាងក្រោម៖

**-ករណីសុំកូនរបស់សហព័ទ្ធ ៖**

ដែលប្តីប្រពន្ធតែម្ខាងក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត សុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្តីប្រពន្ធទេ[4]។ ក្នុងករណីនេះ ប្រសិនបើសហព័ទ្ធតែម្ខាងចង់សុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះគឺពុំចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ ពោលគឺអនាគតកូនចិញ្ចឹមត្រូវជាកូនចុងនោះ សុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្តីប្រពន្ធទេ។

ឧទាហរណ៍៖ លោក **ក** និង លោកស្រី **ខ** បានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នា តែលោកស្រី **ខ** បានមានកូនម្នាក់ជាមួយប្តីមុន ឈ្មោះ **អ** ។ លោក **ក** ដែលជាឪពុកចុង បានមានបំណងចង់សុំ **អ** ជាកូនសុំ ករណីនេះ លោក **ក** មិនចាំបាច់មានការសហការក្នុងការសុំកូនលោកស្រី **ខ** ឬមិនចាំបាច់ដាក់ពាក្យជាមួយលោកស្រី **ខ** ទៅតុលាការ ដើម្បីបង្កើតសុំកូននោះទេ ។

## ១.២.លក្ខខណ្ឌពាក់ព័ន្ធនឹងឪពុកម្តាយបង្កើត

### ១.២.១.ការបង្ហាញឆន្ទៈយល់ព្រម

ដើម្បីអាចបង្កើតសុំកូនពេញលេញបាន ការបង្ហាញឆន្ទៈយល់ព្រមចំពោះការបង្កើតសុំកូនពេញលេញពីសំណាក់ឪពុកម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលនឹងក្លាយជាកូនសុំនោះជាការចាំបាច់។[5] ដោយសារតែការសុំកូនពេញលេញ គឺជាការផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និង មានគោលដៅយកកូនសុំនោះចូលទាំងស្រុងក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះ ចាំបាច់ត្រូវតែមានការយល់ព្រមពី

[4] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០០៨ កថាខណ្ឌទី២

[5] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១១ កថាខណ្ឌទី១

ឪពុកម្តាយបង្កើតដែលមានទំនាក់ទំនងផលប្រយោជន៍យ៉ាងជ្រាលជ្រៅជាមួយនឹងកុមារនោះ[6]។ ប្រសិនបើមានឪពុកម្តាយបង្កើតរបស់កុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ តុលាការត្រូវសាកសួរអំពីឆន្ទៈយល់ព្រមពីសំណាក់ឪពុកម្តាយបង្កើត។

**ជាបដិបញ្ញត្តិ ការបង្ហាញឆន្ទៈយល់ព្រមពីឪពុកម្តាយបង្កើត មិនចាំបាច់ឡើយ បើក្នុងករណីមួយចំនួនដូចជា[7]៖**

-ករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ៖ ការបង្ហាញឆន្ទៈរបស់ឪពុកម្តាយបង្កើត គឺជាករណីចាំបាច់បំផុត សម្រាប់តុលាការ ក្នុងការសម្រេចពី ការបង្កើតសុំកូន តែបើឪពុកម្តាយបង្កើត មិនអាចបង្ហាញឆន្ទៈបាន ដូចជាមិនដឹងថា ពួកគាត់មានទីលំនៅនៅទីណាពិតប្រាកដ និងមិនអាចទាក់ទងបាន ឬ មានវិបត្តិផ្លូវចិត្ត និងវិបត្តិរាងកាយ (វិបល្លាសស្មារតី ឬក្លាយជាជនជីវព្រឹក) ក្នុងករណីនេះការបង្ហាញឆន្ទៈរបស់ឪពុកម្តាយបង្កើត គឺមិនតម្រូវឡើយ។

-ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ៖ ដោយសារអំពើហិង្សាក្នុងគ្រួសារ នាំឲ្យកុមារទទួលផលប៉ះពាល់ អាចមានអារម្មណ៍ពាក់ព័ន្ធគ្នាជាមួយនឹងអាកប្បកិរិយា ដូចជា ភាពភ័យខ្លាចពេលឃើញឪពុកម្តាយឈ្លោះប្រកែកគ្នាម្តងៗ, គ្មានអំណាចឥទ្ធិពល និង គិតថាខ្លួនមានពិរុទ្ធ ដោយសារខ្លួនពុំមានលទ្ធភាពបញ្ឈប់ អំពើហិង្សាដែលខ្លួនបានឃើញជាក់ស្តែងនោះបាន, បាត់បង់ការផ្តោតអារម្មណ៍រៀនសូត្រនៅសាលារៀន, អាចប្រព្រឹត្តអំពើហិង្សា ដោយធ្វើតាមអ្វីៗ ដែលបានសង្កេតឃើញនៅផ្ទះ, ចិត្តមិនស្ងប់, យល់សុបិនអាក្រក់ ដេកពុំលក់, ក្រៀមក្រំ និង ធ្លាក់ទឹកចិត្ត ជាដើម អំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុច្រើនដែលធ្វើអោយកុមាររត់ចេញពីផ្ទះ ហើយក៏អាចជាបញ្ហានាំអោយអាជ្ញាធរនានា ដកសិទ្ធិអំណាចមេបា និងផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែរក្សា ថែទាំកុមារជំនួសវិញផងដែរ។

-ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ៖

-ហេតុផ្សេងៗទៀត ដែលបំពានដល់ផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរករណី៖

- អំពើកេងប្រវ័ញ្ចផ្លូវភេទ ដូចជា ក្នុងករណីយកកុមារ ធ្វើពេស្យាចារ ឬ ការពាក់ព័ន្ធក្នុងអាជីវកម្មរូបអាសអាភាស ប្រើប្រាស់កុមារ ដោះដូរជាមួយ នឹងប្រាក់កាស ឬ របស់របរ ផ្សេងៗជាដើម ។

[6] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥ គន្ថីទី៧ មាត្រា ១០១១ កថាខណ្ឌទី១

[7] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១១ កថាខណ្ឌទី២

- ការយកកុមារ ឲ្យធ្វើការងារច្រើនម៉ោងក្នុងមួយថ្ងៃៗ ដើម្បីទទួលបានប្រាក់កម្រៃតិចក្រោមលក្ខខណ្ឌការងារ ដែលអាចបង្កគ្រោះថ្នាក់ ដល់ការអភិវឌ្ឍន៍រូបរាងកាយ និងផ្លូវចិត្តរបស់កុមារ ដែលរារាំងកុមារមិនអោយទទួលបានការអប់រំរៀនសូត្រ។

ដូចបានលើកឡើងខាងលើ មានករណីជាច្រើនដែលតុលាការអាចសម្រេចបង្កើតសុំពេញលេញ ដោយគ្មានការយល់ព្រមពីឪពុកម្តាយបង្កើតបាន ដូចជាករណីដែលឪពុកម្តាយបង្កើត មិនអាចធ្វើការបង្ហាញឆន្ទៈដោយសារបញ្ហាស្មារតី ឬ ដោយសារពួកគាត់មានទីលំនៅមិនពិតប្រាកដ និងមិនអាចទាក់ទងបាន។ ដូចគ្នាផងដែរ ប្រសិនបើឪពុកម្តាយបង្កើត មិនយល់ព្រមឲ្យមានការបង្កើតសុំកូនពេញលេញ តែការបដិសេធនោះបានធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំ ឬបណ្តាលឲ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារយ៉ាងធ្ងន់ធ្ងរ ក្នុងករណីនោះ តុលាការនឹងតម្កល់ឧត្តមប្រយោជន៍របស់កុមារជាធំ ហើយធ្វើការចេញដីកាសម្រេចបង្កើតសុំកូនពេញលេញ ដោយមិនចាំបាច់មានការយល់ព្រមរបស់ឪពុកម្តាយបង្កើតឡើយ។

### ១.២.២.លក្ខខណ្ឌពាក់ព័ន្ធនឹងឋានៈបុគ្គលរបស់ឪពុកម្តាយបង្កើត

ការបង្កើតអោយមានរបបសុំកូន គឺដើម្បីការពារផលប្រយោជន៍ និងការបង្កើតក្រុមគ្រួសារថ្មី ដ៏ល្អសម្រាប់កុមារជាចម្បង ដូច្នេះហើយបានជាច្បាប់បញ្ញតិយ៉ាងតឹងរឹងថា ឪពុកម្តាយបង្កើត មិនអាចយល់ព្រមប្រគល់កូនទៅឲ្យបុគ្គលណាមួយបានទេ បើឪពុកម្តាយបង្កើតមិនមែនកំពុងស្ថិតក្នុងលក្ខខណ្ឌដូចជា ស្ថានភាពឪពុកម្តាយបង្កើតមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ឬ ឪពុកម្តាយបង្កើត មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ[៨]។

## ១.៣. លក្ខខណ្ឌពាក់ព័ន្ធនឹងកុមារដែលនឹងត្រូវក្លាយជាកូនសុំ

ដោយយោងតាមទម្លាប់ប្រទេសកម្ពុជា កំណត់នៃក្រមរដ្ឋប្បវេណីចាស់ឆ្នាំ១៩២០ និង បញ្ញតិច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ក៏បានកំណត់ពីរបបនៃការសុំកូនផងដែរ រួមទាំងចំនួនកុមារដែលត្រូវក្លាយជាកូនសុំ គឺគេអាចសុំកូនបានតែ ២លើកប៉ុណ្ណោះ ដោយក្នុងម្តងសុំបានតែមួយទេ។ បើកូនសុំនោះមានមួយណាស្លាប់ គេអាចសុំកូនម្នាក់ទៀតបាន[៩]។ ផ្ទុយមកវិញ បើយើងក្រឡេកមកមើលទៅក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧វិញ យើងមិនបានឃើញមានមាត្រាណាមួយកំណត់ពីចំនួនកូនសុំឡើយ។

[៨] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១២ មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

[៩] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ មាត្រា១១

ដូច្នេះ បើយើងធៀបច្បាប់ទាំង២ វាលេចឡើងនូវបញ្ហាថា តើតុលាការនឹងអនុញ្ញាតឲ្យមានការសុំកូនបានប៉ុន្មាននាក់ បើច្បាប់ដែលកំពុងអនុវត្តន៍មិនបានចែងដូច្នេះ។ តែទោះបីជាតាមក្រមរដ្ឋប្បវេណីថ្មីមិនបានបញ្ញតិឲ្យជាក់ច្បាស់ពីចំនួនកូនក៏ដោយ ប៉ុន្តែច្បាប់នេះបានផ្តល់ឆន្ទានុសិទ្ធិទៅតុលាការដើម្បីពិនិត្យ និងពិចារណាអោយបានល្អិតល្អន់ពីលក្ខខណ្ឌផ្លូវច្បាប់ មុននឹងឈានដល់ការសម្រេចសេចក្តី។

**១.៣.១. លក្ខខណ្ឌពាក់ព័ន្ធនឹងអាយុកុមារ**

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ **(ប្រាំបី) ឆ្នាំ**[10] ដោយហេតុថាសុំកូនពេញលេញ គឺជារបបគតិយុត្តមួយដែលបង្កើតឡើងដើម្បីធានានូវក្រុមគ្រួសារមួយដ៏មានឧត្តមផលប្រយោជន៍ និងការពារសិទ្ធជាមូលដ្ឋានរបស់កុមារ ជាពិសេស ជាការផ្តល់ឱកាសដល់កុមារតូចៗ ដើម្បីទទួលបាននូវការថែទាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់ឪពុកម្តាយចិញ្ចឹម និងធ្វើឲ្យកុមារ មានអារម្មណ៍មួយទទួលស្គាល់ថា នេះជាក្រុមគ្រួសារពិតជាឪពុកម្តាយពិតរបស់ខ្លួន ។ ហេតុនេះហើយ ទើបច្បាប់កម្រិតជាគោលការណ៍ថា មានតែកុមារដែលមានអាយុតិចជាង ៨ **(ប្រាំបី)** ឆ្នាំទេ ទើបអាចក្លាយជាកូនសុំបាន។

ទោះបីជាមានបញ្ញតិចែងជាគោលការណ៍យ៉ាងដូច្នេះ តែក៏មានការបកស្រាយមួយចំនួន ពីលើគោលការណ៍នៃអាយុរបស់កុមារដែលជាកូនសុំ ថាគប្បីគួរតុលាការអនុញ្ញាតិឲ្យមានការបង្កើតការសុំកូនសម្រាប់កុមារអាយុលើសពី **៨ឆ្នាំ** បានផងដែរ មូលហេតុ ដោយសារមានគ្រួសារជាច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា បានសុំកូន ដែលមានភាពលំបាកពីឪពុកម្តាយបង្កើត មកចិញ្ចឹមតាំងពីក្មេងកើតមកម្ល៉េះ ដូច្នេះបើយើងមានភាពតឹងរឹងលើអាយុរបស់កុមារខ្លាំងពេក អាចបណ្តាលឲ្យមានការលំបាកដល់កុមារ ។

**ឧទាហរណ៍ទី១៖** លោក **កូវីត** និងនាង **កូរ៉ូណា** បានបង្កើតចំណងអាពាហ៍ពិពាហ៍ជាមួយនឹងគ្នាអស់រយៈជាច្រើនឆ្នាំ ប៉ុន្តែអ្នកទាំងពីរពុំអាចបង្កើតបុត្របាន។ ក្រោយមកប្តីប្រពន្ធទាំងពីរមានបំណងចង់ធ្វើការសុំកូនមកចិញ្ចឹមតាមរយៈសុំកូនពេញលេញ។ អ្នកទាំងពីរចង់សុំកុមារីម្នាក់ឈ្មោះ **បុប្ផា** យកមកចិញ្ចឹម បន្ទាប់ពួកគេបានដាក់ពាក្យសុំកូនតាមរយៈការសុំកូនពេញលេញទៅតុលាការ។ **បុប្ផា** មានអាយុ **៧ឆ្នាំ** ហើយ ដូចនេះនៅពេលដាក់ពាក្យសុំ លោក **កូវីត** និងនាង **កូរ៉ូណា** ត្រូវភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់នាងផងដែរ។

**ឧទាហរណ៍ទី២ (ករណីលើកលែង)៖** ផ្ទុយពីករណីខាងលើ ប្រសិនបើលោក **កូវីត** និងនាង **កូរ៉ូណា** បានសុំ កុមារី **បុប្ផា** តាំងពីកើត តែមិនបានបំពេញនីតិវិធីសុំកូនត្រឹមត្រូវតាមផ្លូវច្បាប់ រហូតដល់នាង មានអាយុ **០៩ឆ្នាំ** ទើបលោក **កូវីត** និងនាង **កូរ៉ូណា** បានយល់ពីច្បាប់ ហើយមានបំណងចង់ដាក់ពាក្យ សុំកូនពេញលេញ ទៅតុលាការ។ បន្ទាប់មកសម្រាប់នីតិវិធីតុលាការនៃការសុំកូនពេញលេញ បានប្រើពេលវេលាអស់រយៈពេលជាង **១(មួយ)**

[10] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១០

**ឆ្នាំ** ដូច្នេះបានន័យថា ទាំងមុនពេលដាក់ពាក្យសុំ និងនៅក្នុងអំឡុងពេលប្រើប្រាស់នីតិវិធីតុលាការ កុមារី **បុប្ផា** មានអាយុលើសពី **៩(ប្រាំបួន) ឆ្នាំ** ទៀត។

**សំនួរៈ** តើក្នុងករណីនេះ លោក កូវីត និងនាង កូរ៉ូណា បានបំពេញនូវលក្ខខណ្ឌនៃអាយុរបស់កូនដូចមានចែងក្នុងមាត្រា ១០១០ នៃក្រមរដ្ឋប្បវេណីដែរឬទេ?

### ១.៣.២.លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍កុមារ

ស៊ុំកូនពេញលេញ អាចបង្កើតបានលុះត្រាតែជាករណីមានភាពលំបាកយ៉ាងខ្លាំងចំពោះកូន ឬ ឪពុកម្ដាយបង្កើត មានភាពមិនសមរម្យ ក្នុងការចិញ្ចឹមបីបាច់ និងថែរក្សាកូន ឬ មានស្ថានភាពពិសេស ផ្សេងៗទៀត ដែលចាំបាច់ ដើម្បីផលប្រយោជន៍របស់កូនសុំនោះ។

## ផ្នែកទី២៖ លក្ខខណ្ឌទម្រង់នៃការបង្កើតស៊ុំកូនពេញលេញ

ការបង្កើតស៊ុំកូនពេញលេញ ត្រូវធ្វើឡើងតាមរយៈសេចក្ដីសម្រេច ហេតុនេះការបង្កើតស៊ុំកូនពេញលេញ ត្រូវមានអន្តរាគមន៍ពីតុលាការដែលមានសមត្ថកិច្ច ដែលតុលាការត្រូវគោរពតាមនីតិវិធីដែលកំណត់ក្នុង **ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង** ក្នុងការបង្កើតស៊ុំកូនពេញលេញ ដោយផ្អែកតាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ដោយហេតុថាការបង្កើតទំនាក់ទំនងគតិយុត្តនេះ ឆន្ទៈរបស់គូភាគីពុំទាន់អាចមានអានុភាពតាមផ្លូវច្បាប់សម្រាប់បង្កើតទំនាក់ទំនងឋានៈបុគ្គលឡើយ។ ក្រោយពីពាក្យសុំ ត្រូវបានដាក់ដោយត្រឹមត្រូវហើយ តុលាការចាត់ការលើនីតិវិធីដោយអនុលោមទៅតាមច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង និងត្រូវសម្រេចសេចក្ដីក្រោមទម្រង់ជា **ដីកាសម្រេច** ដោយផ្អែកទៅលើលក្ខខណ្ឌដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង។

### ២.១. ការដាក់ពាក្យសុំ

ដើម្បីបង្កើតស៊ុំកូនពេញលេញបាន គឺត្រូវធ្វើតាមរយៈពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមត្រូវដាក់ពាក្យសុំរួមគ្នាដោយសហការរវាងប្ដីប្រពន្ធ ទៅតុលាការដែលមានសមត្ថកិច្ច នោះគឺសាលាដំបូងដែលមានសមត្ថកិច្ចលើលំនៅដ្ឋានរបស់អ្នកដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹម[11] ឬ អាចយកភាគីឪពុកម្ដាយបង្កើត ឬ អ្នកមានសិទ្ធិអាណាព្យាបាលទូទៅ ជាភាគីម្ខាងទៀត។ ក្នុងករណីដែលប្ដី ឬប្រពន្ធតែម្ខាង ជាអ្នកដាក់ពាក្យសុំ បង្កើតស៊ុំកូនទៅតុលាការ នោះតុលាការត្រូវលើកចោលពាក្យសុំដោយដីកាសម្រេច ព្រោះជាពាក្យសុំដែលផ្ទុយនឹងច្បាប់។

[11] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីនៃរដ្ឋប្បវេណីមិនមែនបណ្ដឹង ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា៤

ពាក្យសុំបង្កើតសុំកូនពេញលេញ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ ហើយនៅក្នុងពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម[12]៖

ក- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងៗទៀតរបស់តុលាការ ដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

**ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់** អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះ ក្រឡាបញ្ជី ត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនេះ ត្រូវបានកំណត់ថាជាពាក្យសុំ។

បន្ថែមពីលើនេះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញនៅក្នុងពាក្យសុំរបស់ខ្លួន ពីអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចជា៖

- អង្គហេតុដែលបញ្ជាក់ថាខ្លួន និងកូនសុំបានបំពេញតាមគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ
- អង្គហេតុដែលបញ្ជាក់ថាឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនកូនសុំបានយល់ព្រមចំពោះការបង្កើតសុំកូនពេញលេញ
- អង្គហេតុដែលបញ្ជាក់ថា មានស្ថានភាពចាំបាច់ពិសេស ក្នុងការបង្កើតសុំកូនពេញលេញដើម្បីជាផលប្រយោជន៍របស់កូនសុំជាដើម ។ល។

## ២.២. ការពិនិត្យពាក្យសុំ

ពេលទទួលបានពាក្យសុំ តុលាការត្រូវពិនិត្យពាក្យសុំថា បានសរសេរនូវចំណុចដែលច្បាប់តម្រូវហើយឬនៅ បើមិនទាន់សរសេរ ឬ សរសេរមិនត្រឹមត្រូវ តុលាការត្រូវបង្គាប់ឲ្យភាគីអ្នកដាក់ពាក្យសុំ កែតម្រូវពាក្យសុំដោយទុករយៈពេលកំណត់មួយសមរម្យ។ បើអ្នកដាក់ពាក្យសុំ មិនព្រមកែតម្រូវតាមការបង្គាប់របស់តុលាការ តុលាការត្រូវលើកពាក្យសុំចោលដោយ **ដីកាសម្រេច**។ អ្នកដាក់ពាក្យសុំ មានសិទ្ធិប្ដឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំ ក្នុងអំឡុងពេលដែលច្បាប់បានកំណត់។ បន្ថែមពីនេះនៅពេលដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធដាក់ពាក្យសុំចំនួន **៥.០០០ (ប្រាំពាន់) រៀល**[13]។ ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឲ្យបង់ពន្ធនោះ។

[12] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីនៃរដ្ឋប្បវេណីមិនមែនបណ្ដឹង ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា២៦
[13] ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីនៃរដ្ឋប្បវេណីមិនមែនបណ្ដឹង ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា២២

ប្រសិនបើ អ្នកដាក់ពាក្យសុំនៅតែមិនព្រមបង់ពន្ធនោះទេ តុលាការត្រូវលើកពាក្យសុំចោលដោយ **ដីកាសម្រេច**។ ក្រៅពីពន្ធដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធតាមការកំណត់របស់តុលាការ ដើម្បីអាចឲ្យតុលាការធ្វើការបញ្ជូនឯកសារ ការពិនិត្យភស្តុតាង ឬធ្វើសកម្មភាពផ្សេងទៀតដែលចាំបាច់សម្រាប់នីតិវិធី។

**២.៣. អំឡុងពេលសាកល្បងចិញ្ចឹម**

ដោយសារតែ ស្មុំកូនពេញលេញ គឺជាប្រព័ន្ធបង្កើតឲ្យមានអានុភាពខ្លាំង ហើយលក្ខខណ្ឌនៃការបង្កើត និងលក្ខខណ្ឌកាត់កាលក៏មានភាពតឹងរឹង ដូច្នេះតុលាការចាំបាច់ត្រូវសម្រេចឲ្យបានហ្មត់ចត់ថា តើឪពុកម្តាយចិញ្ចឹមនោះពិតជាមានភាពសាកសមក្នុងការយកកូនសុំនោះទៅចិញ្ចឹមបានដែរឬទេ? ឬ តើឪពុកម្តាយចិញ្ចឹមសមត្ថភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនសុំនោះបានល្អដែររឺទេ?

ដើម្បីឈានដល់ការសម្រេចសេចក្តីក្នុងការបង្កើតស្មុំកូនពេញលេញ តុលាការ ត្រូវកំណត់អំឡុងពេលមួយសមរម្យ ដើម្បីអនុញ្ញាតិឲ្យឪពុកម្តាយចិញ្ចឹមនោះ យកកុមារដែលជាកូនសុំ ទៅរស់នៅជាមួយគ្នាដូចជាគ្រួសារតែម្តង ដែលអំឡុងពេលនោះត្រូវបានកំណត់ថាជាអំឡុងពេលសាកល្បង គឺជាអំឡុងពេល ដែលអាចឲ្យតុលាការធ្វើការពិចារណាមុននឹងវិនិច្ឆ័យ អំពីភាពអាច ឬ មិនអាច ក្នុងការបង្កើតស្មុំកូនពេញលេញ។

មានន័យថា អំឡុងពេលសាកល្បងនឹងចាប់ផ្តើមអនុវត្តក្រោយពេលអ្នកសុំបានដាក់ពាក្យសុំបង្កើតស្មុំកូនទៅតុលាការ មិនមែនកើតឡើងមុនការដាក់ពាក្យសុំទៅតុលាការនោះទេ។ ការបង្កើតអំឡុងពេលសាកល្បងចិញ្ចឹម ដើម្បីពិនិត្យថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរឬទេ? ហើយតើមានបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរឬទេ? ឬថា តើមានភាពចុះសម្រុងគ្នារវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមដែរឬយ៉ាងណា?

នៅក្នុងអំឡុងពេលសាកល្បង តុលាការ ត្រូវពិចារណាលើស្ថានភាពរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានធ្វើការគ្រប់គ្រងមើលថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច០៦ (ប្រាំមួយ) ខែ ឬ អាចលើសពីនេះ បើតុលាការយល់ឃើញថាគួរបន្ថែម។

ពាក់ព័ន្ធនឹងសកម្មភាពនាអំឡុងពេលនៃការសាកល្បងនេះ ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត នៅតែបន្តធ្វើជាអ្នកអាណាព្យាបាលរបស់កុមារ លើកលែងតែកុមារនោះរស់នៅក្នុងមណ្ឌលដែលគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលប្រធាននាយកដ្ឋានសុខុមាលភាពកុមារ គឺជាអ្នកអាណាព្យាបាលរបស់កុមារ និងត្រូវផ្តល់នូវសេវានានា ដើម្បីបង្កើនឱកាសឲ្យរយៈពេលអន្តរកាលនេះមានជោគជ័យឈានទៅរកស្មុំកូនអចិន្ត្រៃយ៍។ ប្រសិនបើកុមារ និង គ្រួសារមានការរស់នៅចុះសម្រុងគ្នាល្អ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវជួយគ្រួសារ

ដើម្បីទទួលបានការសម្រេចជាស្ថាពរចុងក្រោយទៅលើការសុំកូន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរកើតឡើង ហើយការសុំកូនមានដំណើរការមិនល្អនោះ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍ផ្សេងទៀតសម្រាប់កុមារ។"(**ប្រការ ២៨ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ** )

ដើម្បីការពារផលប្រយោជន៍កូនសុំ ការផ្តល់គ្រួសារដ៏ល្អមួយដល់គេ ដើម្បីជៀសផុតពីការរំលោភបំពាន និងគេចផុតពីភាពលំបាកនានាដែលកើតឡើងជាមួយឪពុកម្តាយចិញ្ចឹម គេត្រូវតែបង្កើតឲ្យមានការសាកល្បងចិញ្ចឹម។ គេត្រូវធានាថា ឪពុកម្តាយចិញ្ចឹមពិតជាជនដែលអាចផ្តល់ភាពកក់ក្តៅ និង ចិញ្ចឹមបីបាច់កូននោះក្នុងគោលបំណងសុច្ចរិត និងពិតជាអាចផ្តល់ភាពជាគ្រួសារដ៏ល្អដល់កូននោះពិតមែន។

ក្នុងសារណានេះ យើងខ្ញុំសុំធ្វើការបង្ហាញជូន អំពីការស្រាវជ្រាវពីវិធីសាស្ត្រនៃការសាកល្បងចិញ្ចឹមកូនសុំដែលបានអនុវត្តជាក់ស្តែងក្នុងប្រទេសជប៉ុន តុលាការ ប្រទេសជប៉ុន បានប្រើប្រាស់អំឡុងពេលសាកល្បងចិញ្ចឹម ដោយកំណត់អំឡុងពេលយ៉ាងតិច០៦(ប្រាំមួយ)ខែ ដូចប្រទេសកម្ពុជាដែរ ប៉ុន្តែតុលាការប្រទេសជប៉ុនបានបង្កើតអ្នកត្រួតពិនិត្យដែលជាមន្ត្រីនៅក្នុងតុលាការ និង មន្ត្រីទាំងនោះត្រូវបានតែងតាំងដោយតុលាការ ដើម្បីធ្វើការតាមដាន និង តាមឃ្លាំមើល រាល់សកម្មភាពចិញ្ចឹមរបស់ឪពុកម្តាយ អ្នកត្រួតពិនិត្យភាគច្រើនជាអ្នកបានរៀនបញ្ចប់ការសិក្សាផ្នែកចិត្តសាស្ត្រ ទើបអាចធ្វើការវាស់ស្ទង់លើសកម្មភាពនេះបាន ការវាយតម្លៃដែលមានដូចជា ការថែរក្សា ការចិញ្ចឹមបីបាច់កូន ការផ្តល់ការយកចិត្តទុកដាក់ ផ្តល់ការអប់រំល្អ និងការរួមទាំងការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ ។

បន្ថែមពីនោះ អ្នកត្រួតពិនិត្យដែលបានចាត់តាំងដោយតុលាការ ត្រូវពិនិត្យទៅលើ បរិស្ថានរស់នៅរបស់ឪពុកម្តាយចិញ្ចឹម ថាតើ មានស្ថានភាពត្រឹមត្រូវ និងសមរម្យអាចចិញ្ចឹមកូនបានដែរឬទេ? បរិយាកាសជុំវិញលំនៅដ្ឋានល្អឬទេ?

បន្ទាប់ពីពិនិត្យតាមដានហើយ អ្នកត្រួតពិនិត្យ ត្រូវសរសេររបាយការណ៍ស្តីពីសកម្មភាពទាំងនោះ នៅក្នុងអំឡុងពេលសាកល្បងចិញ្ចឹម ជូនទៅចៅក្រមដើម្បីធ្វើការពិចារណា និងវិនិច្ឆ័យសេចក្តី ។

## ផ្នែកទី៣៖ ការវិនិច្ឆ័យសេចក្តី និងការចេញដីកាសម្រេច

### ៣.១.ការពិនិត្យលើភាពចាំបាច់នៃការបង្កើតសុំកូន

ក្រោយពីបានទទួលពាក្យសុំ និងបានពិនិត្យឃើញថាពាក្យមានលក្ខណៈត្រឹមត្រូវហើយ តុលាការត្រូវធ្វើការ វិនិច្ឆ័យលើពាក្យសុំ ដើម្បីចេញសេចក្តីសម្រេច។ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយឆន្ទានុសិទ្ធរបស់ខ្លួន ដែល

ជាការស្រាវជ្រាវអង្គហេតុ និងការពិនិត្យភស្តុតាងនានា[14]។ នៅក្នុងសំណុំរឿងសុំកូនពេញលេញ អង្គហេតុដែលតុលាការចាំបាច់ត្រូវស្រាវជ្រាវ ពិនិត្យ និងផ្ទៀងផ្ទាត់ មុននឹងឈានដល់ការសម្រេចសេចក្តីមានដូចជា៖

១.ក្នុងករណីនៃការសុំកូនដោយសហការរវាងប្តីប្រពន្ធ តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា អ្នកដាក់ពាក្យសុំមានសហព័ទ្ធ ហើយបានដាក់ពាក្យសុំដោយសហការ។

២.ក្នុងករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធតែម្ខាងទៀតនោះ តុលាការត្រួតពិនិត្យអង្គហេតុដែលបញ្ជាក់អំពីចំណុចនេះដោយហេតុថា នេះជាករណីអញ្ញត្រកម្មនៃគោលការណ៍សុំកូនពេញលេញដោយសហការ។

៣.តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា ឪពុកម្តាយចិញ្ចឹមមានអាយុចាប់ពី**២៥ឆ្នាំឡើង**ទៅ និងមានគម្លាតអាយុច្រើនជាងកូនសុំ**យ៉ាងតិច២០ឆ្នាំ**។

៤.តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់ថា កូនសុំមានអាយុ**តិចជាង ៨ឆ្នាំ**។

៥. តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់**អំពីការយល់ព្រមពីឪពុកម្តាយបង្កើត**របស់កូនសុំ។

៦.ក្នុងករណីដែល**គ្មានការយល់ព្រមពីឪពុកម្តាយបង្កើត** តុលាការត្រូវពិនិត្យអង្គហេតុដែលបញ្ជាក់អំពីករណីដែលឪពុកម្តាយបង្កើតនោះមិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ឬ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងទៀតដែលបំពានផលប្រយោជន៍កុមារដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរ។

៧.តុលាការត្រូវពិនិត្យទៅលើអង្គហេតុដែលបញ្ជាក់ថា មានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យក្នុងការគ្រប់គ្រងមើលថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត ព្រមទាំងមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍កុមារនោះ។ អង្គហេតុទាំងអស់ខាងលើ គឺជាលក្ខខណ្ឌគតិយុត្តដែលក្រមរដ្ឋប្បវេណី តម្រូវក្នុងការបង្កើតសុំកូនពេញលេញ ហើយដើម្បីអាចបញ្ជាក់ពីភាពត្រឹមត្រូវ និងពិតប្រាកដ ឬអត្ថិភាពនៃអង្គហេតុខាងលើបាន តុលាការចាំបាច់ត្រូវតែធ្វើការពិនិត្យភស្តុតាងជាឯកសារផ្សេងៗ ដែលអ្នកដាក់ពាក្យសុំបានដាក់ជូនតុលាការ ឬ តុលាការតម្រូវឲ្យដាក់។ ឯកសារទាំងនោះមានដូចជា ឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ ឯកសារបញ្ជាក់ពីអត្តសញ្ញាណ ប្រវត្តិរូបកូនសុំ និង ឯកសារបញ្ជាក់ពីការយល់ព្រមរបស់ឪពុកម្តាយបង្កើតជាដើម។

ក្រៅពីការពិនិត្យភស្តុតាងជាឯកសារ តុលាការអាចធ្វើការសាកសួរភាគីដែលពាក់ព័ន្ធ ឬជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់។ ជាលក្ខណៈពិសេស នៅក្នុងសំណុំរឿងសុំកូនពេញលេញ តុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ដោយហេតុថារឿងក្តីសុំកូនពេញលេញ ចាំបាច់ត្រូវ

[14] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីនៃរដ្ឋប្បវេណីមិនមែនបណ្តឹង ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា២៧

រក្សានូវការសម្ងាត់ផ្ទាល់ខ្លួនយ៉ាងខ្លាំង ហើយមិនចាំបាច់មានភាពចំពោះមុខ និងសាធារណៈភាពនោះទេ។ អាស្រ័យហេតុនេះ តុលាការមិនបាច់បើកការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ពោលគឺតុលាការអាចគ្រាន់តែធ្វើការសាកសួរភាគី ដើម្បីផ្តល់ឱកាសឲ្យភាគីអាចចូលរួមនីតិវិធីនេះជាការគ្រប់គ្រាន់ហើយ។

### ៣.២.ការចេញសេចក្តីសម្រេច

បន្ទាប់ពីបានធ្វើការវិនិច្ឆ័យតាមរយៈការពិនិត្យអង្គហេតុ និង ការពិនិត្យភស្តុតាងចប់សព្វគ្រប់តុលាការត្រូវពិចារណាលើស្ថានភាព នៃការចិញ្ចឹមសាកល្បងទៅលើបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍យ៉ាងតិច **៦ (ប្រាំមួយ) ខែ**[15] ដើម្បីឲ្យដឹងថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ ឬចុះសម្រុងគ្នា និងអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរឬយ៉ាងណា។ ទោះបីជាយ៉ាងនេះក្តី តុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីរយៈពេលសាកល្បងនេះ។

ជាចុងក្រោយ តុលាការត្រូវចេញ **ដីកាសម្រេច** ដែលអាចជាដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញ ឬដីកាសម្រេចលើកចោលពាក្យសុំ[16]។ តុលាការ ត្រូវចេញដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញក្នុងករណីដែលតុលាការបានពិចារណាឃើញថា ភាគីពាក់ព័ន្ធបានបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់តម្រូវ និងមានមូលដ្ឋានវិនិច្ឆ័យគ្រប់គ្រាន់ដើម្បីបង្កើតសុំកូនពេញលេញ។

ផ្ទុយទៅវិញ យោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង តុលាការត្រូវចេញដីកាសម្រេចអំពីពាក្យសុំនៃសុំកូនពេញលេញ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់អង្គហេតុ និងភស្តុតាងរួចមក ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនៃសុំកូនពេញលេញ មិនបានបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១.លក្ខខណ្ឌសម្រាប់ឪពុកម្តាយចិញ្ចឹម តាមមាត្រា១០០៨ និងមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី

២.លក្ខខណ្ឌសម្រាប់កូនសុំ តាមមាត្រា១០១០ នៃក្រមរដ្ឋប្បវេណី

៣.ការបង្ហាញឆន្ទៈយល់ព្រមពីសំណាក់ឪពុកម្តាយបង្កើត តាមមាត្រា១០១១ នៃក្រមរដ្ឋប្បវេណី

៤.មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ តាមមាត្រា១០១២ នៃក្រមរដ្ឋប្បវេណី

ប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនៃសុំកូនពេញលេញនេះមិនបានបំពេញនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងឡាយដែលបានរៀបរាប់ពីខាងលើ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំ និងទុកសិទ្ធិឲ្យភាគីអ្នកដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងជំទាស់។

---

[15] ក្រមរដ្ឋប្បវេណី ដែលត្រូវប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៣

[16] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីនៃរដ្ឋប្បវេណីមិនមែនបណ្តឹង ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ មាត្រា២ និងមាត្រា៨

ដីកាសម្រេចអំពីសុំកូនពេញលេញ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវសរសេរ អំពីសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមទទួលបន្ទុកត្រូវចុះហត្ថលេខាលើដីកាសម្រេចនេះ។ ដីកាសម្រេចអំពីសុំកូនពេញលេញ ត្រូវជូនដំណឹងទៅជនដែលត្រូវទទួលដីកាសម្រេចនេះ ដែលរួមមាន អ្នកដាក់ពាក្យសុំ កុមារដែលនឹងក្លាយជាកូនសុំ និងឪពុកម្តាយបង្កើត។ តែបើជាដីកាសម្រេចលើកចោលពាក្យសុំការជូនដំណឹងនឹងត្រូវធ្វើចំពោះតែ អ្នកដាក់ពាក្យសុំប៉ុណ្ណោះ។

ដីកាសម្រេចអំពីសុំកូនពេញលេញត្រូវបានចូលជាស្ថាពរ នៅពេលអំឡុងពេលសម្រាប់ប្តឹងជំទាស់បានកន្លងហួស ឬ ពេលដែលតុលាការនៃបណ្តឹងជំទាស់ដែលសាលាឧទ្ធរណ៍បានចេញដីកាសម្រេចអំពីពាក្យបណ្តឹងជំទាស់ នេះបើយោងតាមមាត្រា ៣៧ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ដើម្បីអាចប្រើប្រាស់បានតាមផ្លូវច្បាប់ ក្រោយការចូលជាស្ថាពរនៃដីកាសម្រេចអំពីសុំកូនពេញលេញ បណ្តាភាគីដែលពាក់ព័ន្ធត្រូវសុំបញ្ជាក់អំពីការចូលស្ថាពរនៃដីកាសម្រេចនេះផងដែរ។

# ជំពូកទី ២

# អានុភាពក្រោយដីកាសម្រេចសុំក្ខូនពេញលេញចូលជាស្ថាពរ

# ជំពូកទី២

# អានុភាពស្មុំកូនពេញលេញក្រោយដីកាសម្រេចចូលជាស្ថាពរ

ក្រោយពីដីកាសម្រេចស្មុំកូនពេញលេញរបស់តុលាការបានចូលជាស្ថាពរហើយ នោះអានុភាពនៃស្មុំកូនពេញលេញនឹងកើតមានចំពោះគូភាគី រួមមាន អានុភាពចំពោះឪពុកម្តាយបង្កើត និងកូនសុំ និងអានុភាពចំពោះឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលអានុភាពចម្បងដ៏សំខាន់គឺ ការបញ្ចប់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត តែការបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើតពុំមានអានុភាពប្រតិសកម្មឡើយ ពោលគឺពុំមានអានុភាពទៅលើអតីតកាលឡើយ វាមានអានុភាពឆ្ពោះទៅមុខ គិតចាប់ពីថ្ងៃដែលបានបញ្ចប់។

ក្រោយអំពីដីកាសម្រេចបង្កើតស្មុំកូនពេញលេញបានចូលជាស្ថាពរ នោះនឹងបង្កើតអានុភាពនៃទំនាក់ទំនងស្មុំកូនចំពោះបុគ្គលដែលពាក់ព័ន្ធដូចជា កូនសុំ ឪពុកម្តាយចិញ្ចឹម ញាតិរបស់ឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត រួមទាំងញាតិរបស់ឪពុកម្តាយបង្កើតផងដែរ។

## ផ្នែកទី១៖ អានុភាពលើទំនាក់ទំនងញាតិ និងទ្រព្យសម្បត្តិ

### ១.១.អានុភាពចំពោះកូនសុំ

#### ១.១.១.អានុភាពលើទំនាក់ទំនងញាតិ

ក្រោយការស្មុំកូន នោះទំនាក់ទំនងឋានៈបុគ្គល ឬហៅថាទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំ (ពីមុនជាកូនបង្កើត) ត្រូវបញ្ចប់ទាំងស្រុង ការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំត្រូវរលត់តាមផ្លូវច្បាប់[17]។ បន្ថែមពីនេះទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយបង្កើត ជាមួយនឹងកូនក៏ត្រូវរលត់ដូចគ្នាផងដែរ។ ផ្ទុយមកវិញ បើក្នុងករណីដែលសហព័ទ្ធម្ខាងបានស្មុំកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធដែលត្រូវជាឪពុកបង្កើត ឬ ម្តាយបង្កើត មិនរលត់ទេ គឺបន្តអត្ថិភាពនៃទំនាក់ទំនងញាតិនេះជាដរាប មានន័យថា កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម នឹងមានសិទ្ធិ និង ករណីយកិច្ចដូចកូនបង្កើត។

#### ១.១.២.អានុភាពចំពោះទ្រព្យសម្បត្តិ

ក្រៅពីទំនាក់ទំនងស្មុំកូនពេញលេញត្រូវបានបង្កើតតាមរយៈអានុភាពនៃដីកាសម្រេច ដែលចូលជាស្ថាពរ ទំនាក់ទំនងលើទ្រព្យសម្បត្តិរបស់កូនសុំត្រូវបានបង្កើតឡើង។ អាស្រ័យហេតុនេះ កូនសុំត្រូវទទួលបានសិទ្ធិធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹម ក្នុងឋានៈជាសន្តតិជនលំដាប់ទី១។ បន្ថែមពីនេះ កូនសុំមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ច។

[17] មាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ១.២.អានុភាពចំពោះឪពុកម្តាយបង្កើត

### ១.២.១.អានុភាពលើទំនាក់ទំនងញាតិ

ក្រោយស្មុំកូនបានបង្កើត នោះទំនាក់ទំនងឋានៈបុគ្គល ឬ ហៅថាទំនាក់ញាតិរវាងឪពុកម្តាយបង្កើត និង កូនសុំ ត្រូវបញ្ចប់ទាំងស្រុង។ ការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និង កូនត្រូវរលត់តាមផ្លូវច្បាប់។ បន្ថែមពីនេះទៅទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយបង្កើត ជាមួយនឹងកូនសុំក៏ត្រូវរលត់ដូចគ្នាផងដែរ។ ផ្ទុយមកវិញ បើក្នុងករណីដែលសហព័ទ្ធម្ខាងបានស្មុំកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ នោះទំនាក់ទំនងញាតិរវាងកូនសុំនោះ និងសហព័ទ្ធដែលត្រូវជាឪពុកបង្កើត ឬ ម្តាយបង្កើតមិនរលត់ទេ គឺបន្តអត្ថិភាពនៃទំនាក់ទំនងញាតិនេះជាដរាប។

### ១.២.២.អានុភាពចំពោះទ្រព្យសម្បត្តិ

ផ្សេងពីការបញ្ចប់ទំនាក់ទំនងឋានៈបុគ្គល ទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្តាយបង្កើត និងកូនត្រូវបានកាត់ផ្តាច់ផងដែរ។ អាស្រ័យហេតុនេះ កូនគ្មានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយបង្កើត ហើយឪពុកម្តាយបង្កើតក៏លែងមានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់កូនបង្កើតដែរ។ ពោលគឺឪពុកម្តាយបង្កើត និងកូនលែងក្លាយជាសន្តតិជនទៀតហើយ។ មិនតែប៉ុណ្ណោះចំពោះសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ញាតិលោហិតផ្សេងទៀតរបស់ឪពុកម្តាយបង្កើតក៏ត្រូវរលត់ដែរ។

## ១.៣.អានុភាពចំពោះឪពុកម្តាយចិញ្ចឹម

### ១.៣.១.អានុភាពលើទំនាក់ទំនងញាតិ

ផ្ទុយពីឪពុកម្តាយបង្កើត ក្រោយស្មុំកូនពេញលេញបង្កើតអានុភាព នោះទំនាក់ទំនងឋានៈបុគ្គល ឬ ហៅថាទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំកូនត្រូវបានបង្កើតឡើងតាមការសន្មតរបស់ច្បាប់។ ហើយកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកម្តាយចិញ្ចឹម។ លើសពីនេះទៅទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយចិញ្ចឹមជាមួយនឹងកូនក៏ត្រូវបង្កើតឡើងដូចគ្នាផងដែរ។ ហើយក្នុងករណីនេះ កូនសុំត្រូវបានទទួលឋានៈ សិទ្ធិ និងករណីកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។ ម្យ៉ាងទៀត កូនសុំក៏អាចផ្លាស់ប្តូរនាមត្រកូលមកដាក់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមបានផងដែរ ហេតុនេះ ឈ្មោះថ្មីរបស់កូនសុំ និង ឪពុកម្តាយចិញ្ចឹមនឹងត្រូវបញ្ចូលក្នុងសំបុត្រកំណើតថ្មីដែលចេញដោយមេឃុំ ឬ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋានទៅតាមបែបបទនៃការចុះសំបុត្រកំណើត។

ក្រោយពីស្មុំកូនត្រូវបានបង្កើត បើទោះបីជាឪពុកម្តាយចិញ្ចឹមលែងលះគ្នា ក៏អានុភាពនៃស្មុំកូនពេញលេញដែលបានកើតឡើងមិនរលត់ឡើយ ព្រោះថាលក្ខខណ្ឌដែលកំណត់អំពីការស្មុំកូនដោយសហការគ្នារវាង

សហព័ទ្ធ គឺជាលក្ខខណ្ឌសម្រាប់តែបង្កើតសុំកូនពេញលេញតែប៉ុណ្ណោះ មិនមែនជាលក្ខខណ្ឌសម្រាប់បន្ត ទំនាក់ទំនងសុំកូនពេញលេញឡើយ។ ដូចច្នេះហើយ បើកូនសុំនៅជាអនីតិជននៅឡើយកូនសុំនោះត្រូវស្ថិត ក្រោមអំណាចមេបាទោលរបស់ឪពុក ឬ ម្ដាយ ណាម្ខាងទៅតាមការពិភាក្សារបស់ឪពុកម្ដាយ ឬ តាមការ សម្រេចរបស់តុលាការ។

### ១.៣.២.អានុភាពលើទ្រព្យសម្បត្តិ

បើទំនាក់ទំនងឋានៈបុគ្គលត្រូវបានបង្កើត នោះទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្ដាយចិញ្ចឹម និង កូនសុំត្រូវបានបង្កើតជាស្វ័យប្រវត្តិផងដែរ។ អាស្រ័យហេតុនេះ កូនសុំមានសិទ្ធិពេញលេញធ្វើសន្តតិកម្មលើ ទ្រព្យសម្បត្តិរបស់ឪពុកម្ដាយចិញ្ចឹម ហើយឪពុកម្ដាយចិញ្ចឹម ហើយឪពុកម្ដាយក៏មានសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យ សម្បត្តិរបស់កូនសុំដែរ។ ពោលគឺឪពុកម្ដាយចិញ្ចឹម និង កូនសុំត្រូវក្លាយជាសន្តតិជនទៅតាមករណីនៃលំដាប់ សន្តតិកម្មរៀងៗខ្លួន។ បន្ថែមពីនេះ ឪពុកម្ដាយចិញ្ចឹម និង ញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមក៏មានសិទ្ធិ ទាមទារអាហារកាតព្វកិច្ចពីកូនសុំផងដែរ។

## ផ្នែកទី២៖ ការចុះបញ្ជីអត្រានុកូលដ្ឋាន

### ២.១.ការចុះបញ្ជី ឬ ការកែប្រែអត្រានុកូលដ្ឋានកំណើតរបស់កូនសុំ

អានុភាពចម្បងនៃការបង្កើតការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម រួមទាំងញាតិរបស់ឪពុកម្ដាយចិញ្ចឹម និងកាត់ផ្ដាច់ទាំងស្រុង នូវទំនាក់ទំនងរវាងកូន ជាមួយ ឪពុកម្ដាយបង្កើត និងញាតិរបស់ឪពុកម្ដាយបង្កើត ។ ការណ៍នេះមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្ដាយ បង្កើត និងកូនត្រូវរលត់តាមផ្លូវច្បាប់។ បន្ថែមពីនេះទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្ដាយបង្កើត ដូចជា លោកតា និងលោកយាយ ជាអាទិ៍ជាមួយនឹងកូនក៏ត្រូវរលត់ដូចគ្នា ផងដែរ។

ដោយសារតែមូលហេតុនេះ ឪពុកម្ដាយចិញ្ចឹម ត្រូវធ្វើការកែប្រែបញ្ជីកំណើតរបស់កូនសុំជាថ្មី ដោយភ្ជាប់ ទៅជាមួយនឹងដីកាសម្រេចបង្កើតសុំកូនរបស់តុលាការ។[18] ថ្វីត្បិតតែក្រមរដ្ឋប្បវេណី ពុំបានបញ្ញត្តិអំពីនីតិវិធីនៃការ ចុះបញ្ជីអត្រានុកូលដ្ឋានរបស់កូនសុំ ក្រោយដីកាសម្រេចបង្កើតសុំកូនពេញលេញចូលជាស្ថាពរក៏ដោយ ក៏នៅ មានលិខិតបទដ្ឋានដទៃទៀតបានកំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលម្អិត នៅក្នុងអនុក្រឹត្យស្ដីពីអត្រានុកូលដ្ឋានដែរ។ ក្នុងនោះដីកាសម្រេចបង្កើតសុំកូនពេញលេញ នឹងក្លាយជាមូលដ្ឋាន គតិយុត្តយ៉ាងសំខាន់សម្រាប់កូនសុំ និងឪពុកម្ដាយចិញ្ចឹមក្នុងការរៀបចំ និងកែប្រែអត្រានុកូលដ្ឋានកំណើតថ្មី ដូច ជា ការធ្វើសំបុត្រកំណើតថ្មី និងសៀវភៅគ្រួសារថ្មីជាអាទិ៍។

[18] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៨ កថាខណ្ឌទី១

ពេលបង្កើតស្មុំកូនហើយ កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនស្មុំកូនក៏បាន។ ឪពុកម្តាយចិញ្ចឹមដែលបានស្មុំកូន ត្រូវទៅចុះបញ្ជីកំណើតថ្មីឲ្យកូនសុំនោះ ដែលបញ្ជីកំណើតថ្មី ត្រូវយកលេខចុះបញ្ជីពីសំបុត្រកំណើតចាស់របស់ក្មេង ដោយអាចធ្វើការផ្លាស់ប្តូរឈ្មោះ និងនាមត្រកូល របស់កូនសុំ និងឈ្មោះឪពុកម្តាយចិញ្ចឹម តែមិនត្រូវសរសេរចូលពីអំពីការស្មុំកូនឡើយ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាសំបុត្រកំណើតចាស់ ដោយបិទស្រោមសំបុត្រទុកតម្កល់ជាឯកសារនៅការិយាល័យរបស់ខ្លួន។

សំបុត្រកំណើតថ្មីរបស់កូនសុំ ត្រូវបញ្ចូលឈ្មោះឪពុកម្តាយចិញ្ចឹមក្នុងសំបុត្រកំណើតថ្មី ដែលចេញឲ្យដោយមន្ត្រីអត្រានុកូលដ្ឋាន គឺ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានរបស់ឪពុកម្តាយចិញ្ចឹម។

### ២.២.ការរក្សាការសម្ងាត់អត្រានុកូលដ្ឋានកំណើតរបស់កូនសុំ

ព័ត៌មានដែលទាក់ទងនឹងការស្មុំកូនពេញលេញ គឺជាការសម្ងាត់ នៅក្នុងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីស្មុំកូនឡើយ។[19] ការធ្វើដូច្នេះ គឺដើម្បីរក្សាការសម្ងាត់ពីការស្មុំនេះ ព្រោះពុំចង់ឲ្យមានហានិភ័យ ដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្តាយបង្កើត ដែលធ្វើឲ្យស្ថានភាពគ្រួសារកូនសុំ មានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវបរិស្ថានរីកចម្រើនលូតលាស់ដែលមានលំនឹងសម្រាប់កុមារ។ បញ្ជីអត្រានុកូលដ្ឋាន និងសំបុត្រកំណើតថ្មី របស់កូនសុំ ដែលធ្វើឡើងដោយការបង្កើតស្មុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះរបស់ឪពុកម្តាយបង្កើត ឬចំណុចស្តីពីស្មុំកូនឡើយ ហើយត្រូវចុះថាឪពុកម្តាយចិញ្ចឹម គឺជាឪពុកម្តាយបង្កើត។

## ផ្នែកទី៣៖ សិទ្ធិដឹងអំពីកំណើតខ្លួន

### ៣.១.ការដាក់ពាក្យសុំទៅតុលាការ

ស្មុំកូនពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឲ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីស្មុំកូនបាន។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ។ ចំពោះការរក្សាទុកសំណុំរឿង និងវិធីទាមទារឲ្យបង្ហាញជាអាទិ៍ ត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិរបស់តុលាការ[20]។

គោលបំណងត្រឹមត្រូវ មានដូចខាងក្រោម៖

-ធ្វើការបញ្ជាក់ ដោយសារតែមានបញ្ហាដោយភាគីដែលនឹងរៀបអាពាហ៍ពិពាហ៍កាលពិតជាបងប្អូនបង្កើត ឬ សាច់ញាតិ។

-ធ្វើការបញ្ជាក់ថា តើឪពុកម្តាយបង្កើតមានជម្ងឺតំណរពូជដែរឬទេ?

---

[19] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៨ កថាខណ្ឌទី២

[20] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៩

**គោលបំណងមិនត្រឹមត្រូវ មានដូចខាងក្រោម៖**

-ទាមទារប្រាក់ពីឪពុកម្ដាយបង្កើត។

### ៣.២.ការជួបប្រាស្រ័យជាមួយឪពុកម្ដាយបង្កើត និងបងប្អូនញាតិលោហិត

នៅក្នុងប្រទេសមួយចំនួន ការអនុញ្ញាតិឲ្យកូនសុំ បានស្គាល់គ្នាជាមួយឪពុកម្ដាយបង្កើត បងប្អូនបង្កើត ឬញាតិខាងឪពុកម្ដាយបង្កើត ត្រូវបានគេបើកទូលាយ ពេលដែលកូនសុំមានអាយុ ដល់វ័យនីតិភាព។ ក្រៅពីនេះ ក៏មានប្រព័ន្ធរៀបចំឲ្យមានការជួបមុខផ្ទាល់រវាងកូនសុំដែលដល់នីតិជន និងឪពុកម្ដាយបង្កើត បងប្អូនបង្កើត ឬញាតិខាងឪពុកម្ដាយបង្កើតផងដែរ ប្រសិនបើមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីគ្រួសាររបស់កូនសុំ។

# ជំពូកទី៣
# ការកាត់កាលស្មុំកូនពេញលេញ

# ជំពូកទី៣

# ការកាត់កាលស្មុំកូនពេញលេញ

ការកាត់កាលស្មុំកូនពេញលេញ គឺជាការបញ្ចប់ទំនាក់ទំនង រវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម និង ទំនាក់ទំនងញាតិភាពរវាងកូនសុំ និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម បូករួមទាំងការកាត់ផ្តាច់ទំនាក់ទំនង សិទ្ធ និងកាតព្វកិច្ច ដូចជា អាហារកាតព្វកិច្ច និងសន្តតិកម្ម។

បើយើងពិនិត្យមើលលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌសារធាតុ នៃការបង្កើតស្មុំកូនពេញលេញ មានភាព ស្មុគស្មាញ និងតានតឹងជាងស្មុំកូនធម្មតា ព្រោះស្មុំកូនពេញលេញ សំដៅដល់ការបង្កើតទំនាក់ទំនងញាតិភាព ជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ដោយអនុញ្ញាតិឲ្យកាត់ផ្តាច់ទំនាក់ទំនង ញាតិភាពជាមួយឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើតទាំងស្រុង ដូច្នេះហើយចំណងមួយ នេះ បើមានចេតនាចង់បញ្ចប់ ក៏មិនអាចបញ្ចប់ដោយងាយស្រួលបាននោះឡើយ។

**សំនួរ៖ តើការកាត់កាលស្មុំកូនពេញលេញ ត្រូវគោរពលក្ខខណ្ឌទម្រង់ និងលក្ខខណ្ឌសារធាតុយ៉ាងដូច ម្តេច?**

## ផ្នែកទី១៖ នីតិវិធីនៃការកាត់កាល

### ១.១. លក្ខខណ្ឌទម្រង់

#### ១.១.១.សមត្ថកិច្ចតុលាការ

ការកាត់កាលស្មុំកូនពេញលេញ គឺចាំបាច់ត្រូវធ្វើឡើងតាមរយៈបណ្តឹងទាមទារឲ្យកាត់កាល ដែលតម្រូវ ឲ្យមានការដាក់ជាពាក្យបណ្តឹង ទៅតាមផ្លូវតុលាការ ដោយអនុលោមតាម ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹង ឋានៈបុគ្គល។[21]

តុលាការ ដែលមានសមត្ថកិច្ច ក្នុងការទទួលពាក្យបណ្តឹងកាត់កាលស្មុំកូន គឺជាតុលាការ នៃលំនៅដ្ឋាន របស់កូនស្មុំ ចំពោះសេចក្តីសម្រេចអំពីការកាត់កាលត្រូវ ហើយដើម្បីធ្វើការកាត់កាលឲ្យត្រូវទៅតាមលក្ខណៈបែប គតិយុត្តនោះ យើងគួរបំពេញនូវលក្ខខណ្ឌដូចខាងក្រោយ៖

#### ១.១.២. បុគ្គលដែលមានសិទ្ធិសុំឲ្យកាត់កាល

ការកាត់កាលស្មុំកូនពេញលេញ មិនមែនសុទ្ធតែអាចធ្វើឡើងដោយបុគ្គលគ្រប់រូបបានឡើយ ព្រោះការ កាត់កាល នាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កុមារដែលជាកូនសុំ ដូច្នេះហើយបានជាច្បាប់បានបញ្ញតិ យ៉ាងច្បាស់ពីអ្នកដែលអាចមានសិទ្ធិ ដាក់ពាក្យបណ្តឹងសុំកាត់កាលស្មុំកូននេះបាន បុគ្គលមានសិទ្ធិនោះ ត្រូវតែ

[21] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១ មាត្រា ៣ ចំណុច ជ

ជាអ្នកដែលបានគិតគូរយ៉ាងល្អិតល្អន់ពីផលប្រយោជន៍របស់កូនសុំ និងជាអ្នកដែលមានទំនាក់ទំនង ការពារសិទ្ធិរបស់កូនសុំ បុគ្គលទាំងនោះមានដូចជាៈ

-ក្នុងករណីកូនសុំ ជាដើមចោទ នោះឪពុកម្តាយចិញ្ចឹមជាសហចុងចម្លើយ[22]។

-ក្នុងករណីឪពុកម្តាយបង្កើត ជាដើមចោទ នោះឪពុកម្តាយចិញ្ចឹម ជាចុងចម្លើយ[23]។

-ក្នុងករណីតំណាងអយ្យការ ជាដើមបណ្តឹង នោះឪពុកម្តាយចិញ្ចឹមជាសហចុងចម្លើយ។[24]

## **១.២. លក្ខខណ្ឌសារធាតុ**

ចំពោះស្មុំកូនពេញលេញ ការកាត់កាល់ចាំបាច់ត្រូវធ្វើឡើងតាមផ្លូវតុលាការ ដោយធ្វើជាពាក្យបណ្តឹងទាមទារឲ្យកាត់កាល់ ហើយអំពីការសម្រេចអំពីការកាត់កាល់ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ ដើម្បីធ្វើការកាត់កាលបាន លុះត្រាតែតុលាការយល់ឃើញថា ការកាត់កាល់សុំកូនពេញលេញនេះ មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កុមារ និងករណីមួយចំនួនដូចជាៈ

**ក.** មានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផលផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ[25]។ នៅពេលដែលឪពុកម្តាយចិញ្ចឹមប្រើអំពើហិង្សាវាយដំ ធ្វើទារុណកម្ម យ៉ាងសាហាវទៅលើកុមារគឺពិតជាមានផលប៉ះទង្គិចខ្លាំងណាស់ ក្នុងករណីឪពុកម្តាយចិញ្ចឹមមិនអាចបន្តចិញ្ចឹមកូនស្មុំបានទៀតឡើយ ។

**ខ.** បើឪពុកម្តាយបង្កើត អាចគ្រប់គ្រងថែរក្សាដោយសមរម្យបាន[26]។ ក្នុងករណីដែលឪពុកម្តាយបង្កើតមានស្ថានភាពគ្រួសារមួយដែលល្អប្រសើរជាងពីមុន ឬ មានជីវភាពធូរធា អាចមានលទ្ធភាពនៅក្នុងការគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនបានដោយខ្លួនឯងវិញ។

អ្នកដែលមានសិទ្ធ ដាក់ពាក្យបណ្តឹងសុំទាមទារឲ្យមានកាត់កាល់បាន មានតែកូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ ប៉ុណ្ណោះ។[27] ឪពុកម្តាយចិញ្ចឹម មិនអាចដាក់ពាក្យសុំឲ្យកាត់កាលកូនសុំបាននោះទេ ព្រោះថា ស្មុំកូនពេញលេញ គឺបង្កើតឡើងដើម្បីផលប្រយោជន៍កូន។

[22] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១ មាត្រា ៧ ចំណុច ១
[23] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១ មាត្រា ៧ ចំណុច ២
[24] ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១ មាត្រា ៧ ចំណុច ៣
[25] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៦ ចំណុច ក
[26] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៦ ចំណុច ខ
[27] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៦

## ផ្នែកទី២៖ ការវិនិច្ឆ័យ និងសេចក្តីសម្រេច

### ២.១.ភាពចាំបាច់នៃការសុំកាត់កាល

ដូចបានរៀបរាប់ខាងលើ ការកាត់កាលស្មុំកូន មិនមែនជាករណីធម្មតាទេ វាជាចំណុចមួយដែល តុលាការ ត្រូវធ្វើការវិនិច្ឆ័យយ៉ាងលម្អិតបំផុត ហើយបើការសុំកាត់កាលកូនសុំ មិនបានបង្ហាញពីភាពចាំបាច់ ឬ អត្ថប្រយោជន៍សម្រាប់កូនសុំទេ តុលាការនឹងមិនអនុញ្ញាតិឲ្យមានការកាត់កាលឡើយ។ ម៉្យាងវិញទៀតទោះបីជា មានលក្ខខណ្ឌគ្រប់គ្រាន់តាមច្បាប់កំណត់ក៏ដោយ តែការពិចារណារបស់តុលាការ លើករណីនេះនៅតែជាកត្តាច ម្បង។

ដូច្នេះដើម្បីឲ្យមានភាពច្បាស់លាស់ ពីមូលហេតុនៃការសុំកាត់កាល តុលាការអាចធ្វើការពិនិត្យភស្តុ តាងផ្សេងៗដោយឆន្ទានុសិទ្ធិបាន។

### ២.២.ការចេញសេចក្តីសម្រេចកាត់កាល

មុនចេញសេចក្តីសម្រេច តុលាការ ដែលទទួលបានពាក្យបណ្តឹងសុំកាត់កាល ត្រូវធ្វើការពិនិត្យភស្តុតាង ដោយតុលាការ អាចធ្វើការសាកសួរភាគីដើមចោទ (ឳពុកម្តាយ, កូនសុំ និងតំណាងអយ្យការ) ការសាកសួរ ភាគីសហចុងចម្លើយ (ឳពុកម្តាយចិញ្ចឹម) រួមទាំងសាក្សី និងការស្វែងរកភស្តុតាងផ្សេងៗទៀត ដែលអាចបង្ហាញពី ភាពចាំបាច់ក្នុងការសម្រេចសេចក្តី។ ពេលដែលតុលាការបានពិចារណា និងពិនិត្យសំណុំរឿងបានល្អិតល្អន់ ហើយ តុលាការ អាចចេញជាសេចក្តីសម្រេច ដោយផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការដូចជា៖

- **ករណីមានមូលហេតុត្រឹមត្រូវ**

បើតុលាការ យល់ឃើញថា ពាក្យបណ្តឹងសុំកាត់កាលមានមូលហេតុត្រឹមត្រូវ និងមានភាពចាំបាច់ សម្រាប់កូនសុំ នោះតុលាការ នឹងចេញសាលក្រមទទួលស្គាល់ការទាមទារ ដែលមានសេចក្តីសម្រេច កាត់កាល ស្មុំកូនពេញលេញរវាងកូនសុំ និងឳពុកម្តាយចិញ្ចឹម។

សាលក្រមនេះ នឹងមានអានុភាពនៅពេលផុតបណ្តឹងឧទ្ធរណ៍ រយៈពេល០១ខែ គិតចាប់ពីថ្ងៃដែលភាគី បានទទួលដំណឹងពីសេចក្តីសម្រេចនេះ។

- **ករណីមានមូលហេតុមិនត្រឹមត្រូវ**

បើតុលាការ យល់ឃើញថា ពាក្យបណ្តឹងសុំកាត់កាលមិនមានមូលហេតុត្រឹមត្រូវ និងមិនមានភាព ចាំបាច់សម្រាប់កូនសុំ នោះតុលាការ នឹងចេញសាលក្រមបដិសេធការទាមទារ ដែលមានសេចក្តីសម្រេច ច្រាន ចោលការសុំកាត់កាលស្មុំកូនពេញលេញរវាងកូនសុំ និងឳពុកម្តាយចិញ្ចឹម។

សាលក្រមនេះ នឹងមានអានុភាពនៅពេលផុតបណ្តឹងឧទ្ធរណ៍ រយៈពេល០១ខែ គិតចាប់ពីថ្ងៃដែលភាគី បានទទួលដំណឹងពីសេចក្តីសម្រេចនេះ។

## ផ្នែកទី៣៖ អានុភាពនៃការកាត់កាលសុំកូនពេញលេញ

នៅពេលដែលការសុំកូនពេញលេញត្រូវបានរលត់ ដោយសាលក្រមរបស់តុលាការ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបានបញ្ចប់ រីឯញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ នឹងត្រូវបានបង្កើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់[28]។

អានុភាពនៃការកាត់កាលសុំកូន បាននាំឲ្យមានទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកបង្កើត និង ម្តាយបង្កើតត្រូវតភ្ជាប់ឡើងវិញដោយស្វ័យប្រវត្តិ គឺបានន័យថា នៅពេលដែលសាលក្រមបានចូលជាស្ថាពរ អ្វីៗនឹងត្រលប់ទៅជាសភាពដើមវិញ ដូចមុនពេលដែលការសុំកូនពេញលេញត្រូវបានបង្កើត ដែលបានរៀបរាប់ដូចខាងក្រោម។

**គួរកត់សម្គាល់ ៖**

**តើអានុភាពនៃការកាត់កាលសុំកូន មានអានុភាពប្រតិសកម្មដែរឬទេ? ហើយវាមានអានុភាពដូចម្តេចចំពោះឪពុកម្តាយចិញ្ចឹម , កូនសុំ និងឪពុកម្តាយបង្កើត?**

### ៣.១.អានុភាពចំពោះឪពុកម្តាយបង្កើត

#### ៣.១.១.អានុភាពទៅលើឋានៈបុគ្គល

ដោយសារតែការសុំកូនពេញលេញ ត្រូវបានបញ្ចប់ដោយសាលក្រមរបស់តុលាការ អានុភាពនៃញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវបានកើតឡើងវិញ ដោយស្វ័យប្រវត្តិ គិតចាប់ពីថ្ងៃកាត់កាល់នោះ។ ម្យ៉ាងទៀតកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបា របស់ឪពុកម្តាយបង្កើតវិញ។ បន្ថែមពីនេះទៀត កូនសុំក៏អាចផ្លាស់ប្តូរនាមត្រកូល មកដាក់នាមត្រកូល របស់ឪពុកម្តាយបង្កើតបានផងដែរ ហេតុនេះហើយសំបុត្រកំណើតចាស់របស់កូនសុំ ដែលបានរក្សាទុកដោយមន្ត្រីអត្រានុកូលដ្ឋានមុនបង្កើតសុំកូន អាចត្រូវបានយកមកប្រើប្រាស់វិញ។

#### ៣.១.២.អានុភាពទៅលើទ្រព្យសម្បត្តិ

ផ្សេងពីការបង្កើតទំនាក់ទំនងឋានៈបុគ្គល ទំនាក់ទំនងលើទ្រព្យសម្បត្តិរវាងឪពុកម្តាយបង្កើត និងកូននឹងត្រូវបានតភ្ជាប់វិញផងដែរ ព្រមទាំងសិទ្ធិធ្វើសន្តតិកម្មលើទ្រព្យសម្បត្តិរបស់ញាតិលោហិតផ្សេងទៀតរបស់ឪពុកម្តាយបង្កើត ពោលគឺឪពុកម្តាយបង្កើត និងកូន ក្លាយជាសន្តតិជនម្តងទៀត។

[28] ក្រមរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ១០១៧

## ៣.២.អានុភាពចំពោះឪពុកម្តាយចិញ្ចឹម

### ៣.២.១.អានុភាពទៅលើឋានៈបុគ្គល

ក្រោយពីស្មុំកូនពេញលេញ បានរំលាយហើយនោះ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ក៏ដូចជាញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ទាំងស្រុង គឺមានន័យថា ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនត្រូវរលត់តាមផ្លូវច្បាប់ បន្ថែមពីនេះទៀត ទំនាក់ទំនងញាតិលោហិតផ្សេងៗទៀតរបស់ឪពុកម្តាយចិញ្ចឹម ជាមួយនឹងកូនសុំ ក៏ត្រូវរលត់ដូចគ្នាផងដែរ ហើយកូនសុំត្រូវមិនស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកម្តាយចិញ្ចឹមទៀតនោះទេ។

### ៣.២.២.អានុភាពទៅលើទ្រព្យសម្បត្តិ

ក្រៅពីអានុភាពលើទំនាក់ទំនងញាតិភាព អានុភាពលើទ្រព្យសម្បត្តិ ក៏មានអានុភាពកើតឡើងដែរ មានន័យថា កូនសុំ លែងជាបុគ្គលដែលមានសិទ្ធិក្នុងការបន្តសន្តិតិកម្មលើទ្រព្យសម្បត្តិ របស់ឪពុកម្តាយចិញ្ចឹម និងញាតិរបស់ឪពុកម្តាយចិញ្ចឹមទៀតហើយ ចំណែកឯឪពុកម្តាយចិញ្ចឹម និងញាតិរបស់ឪពុកម្តាយចិញ្ចឹម ក៏មិនអាចធ្វើសន្តតិកម្មលើមត៌ករបស់កូនសុំវិញបានដូចគ្នា។

## ៣.៣.អានុភាពចំពោះកូនសុំ

### ៣.៣.១.អានុភាពទៅលើឋានៈបុគ្គល

នៅពេលស្មុំកូនពេញលេញបានរំលាយ ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត និងញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត ត្រូវបានកើតឡើងវិញដោយស្វ័យប្រវត្តិ កូនសុំត្រូវស្ថិតក្រោមរបបអំណាចមេបារបស់ឪពុកម្តាយបង្កើត ។ ដោយក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំបានចែងពីការប្រើប្រាស់នាមត្រកូលរបស់កូនសុំឡើយ ថាអាចបន្តប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬត្រូវប្តូរទៅនាមត្រកូល មុនពេលបង្កើតស្មុំកូនពេញលេញវិញឬយ៉ាងទេ។ ដោយឡែកតាមបញ្ញត្តិនៃស្មុំកូនធម្មតា បានកំណត់យ៉ាងច្បាស់ថា ក្រោយកាត់កាល ស្មុំកូនធម្មតា កូនសុំអាចបន្តប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬត្រូវប្តូរទៅនាមត្រកូល មុនពេលបង្កើតស្មុំកូនវិញក៏បាន។

ប៉ុន្តែបើកូនសុំ នៅបន្តប្រើនាមត្រកូលឪពុកម្តាយចិញ្ចឹម នោះសំបុត្រកំណើតថ្មីរបស់កូនសុំ និងត្រូវចុះបញ្ជី ដោយយកឪពុកម្តាយបង្កើត ដាក់បញ្ចូលក្នុងសំបុត្រកំណើតថ្មីវិញហើយមេឃុំ ឬ ចៅសង្កាត់ដែលជាមន្ត្រីអត្រានុកូលដ្ឋាននឹងបំពេញបែបបទនៃការចុះសំបុត្រកំណើត។

### ៣.៣.២.អានុភាពទៅលើទ្រព្យសម្បត្តិ

ក្រៅពីទំនាក់ទំនងស្មុំកូនពេញលេញ ត្រូវបានបញ្ចប់តាមរយៈអានុភាពនៃសាលក្រមចូលជាស្ថាពរទំនាក់ទំនងលើទ្រព្យសម្បត្តិរបស់កូនសុំ ត្រូវបានបង្កើតឡើងវិញ ជាមួយឪពុកម្តាយបង្កើត រួមទាំងញាតិលោហិតរបស់

ឪពុកម្តាយបង្កើតផងដែរ។ បន្ថែមពីនេះ កូនសុំមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ច និងទទួលបាន សិទ្ធិធ្វើសន្តតិកម្មទៅលើទ្រព្យសម្បត្តិរបស់ឪពុកម្តាយបង្កើត ក្នុងឋានៈជាសន្តតិជនលំដាប់ទី១ រីឯឪពុកម្តាយបង្កើតនិងញាតិរបស់ឪពុកម្តាយបង្កើត ក៏មិនអាចធ្វើសន្តតិកម្មលើមត៌ករបស់កូនវិញបានដូចគ្នា។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវបកស្រាយប្រធានបទខាងលើ ខ្ញុំ យល់ឃើញថា ប្រធានបទពាក់ពន្ធ័នឹងការស្មុំកូននេះ ពិតជាមានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ រួមទាំងសម្រាប់សង្គមទាំងមូលផងដែរ។ ការបង្កើតឱ្យមានរបបស្មុំកូន ក្នុងច្បាប់របស់ប្រទេសកម្ពុជា ពិតជាមានភាពចាំបាច់ណាស់ ដើម្បីគាំពារចំពោះកុមាររងគ្រោះជាច្រើន ដែលរង់ចាំការជួយសង្គ្រោះ ហើយក៏ជាឱកាសល្អសម្រាប់ក្រុមគ្រួសារមួយចំនួន ដែលត្រូវការនូវកុមារ ដើម្បីចូលរួមបំពេញនូវគ្រួសារមួយដ៏ពេញលេញ និងមានសុភមង្គល។

មុនពេលជ្រើសរើសយកប្រធានបទនេះ ខ្ញុំ គ្រាន់តែយល់មួយផ្នែកថា ការបង្កើតស្មុំកូន ជាប្រធានបទមួយល្អ និងគួរឱ្យចាប់អារម្មណ៍ ប៉ុន្តែពេលដែល ខ្ញុំបានសិក្សា លម្អិតលើប្រធានបទនេះហើយ ឃើញថា ការស្មុំកូន មិនមែនជារបបគត្តិយុត្តធម្មតាទេ វាជារបបមួយដែលមានភាពលំបាក និងស្មុគស្មាញបំផុត ដូច្នេះហើយ ប្រទេសកម្ពុជា គប្បីត្រូវកំណត់ឱ្យបានច្បាស់ ពីនីតិវិធីអនុវត្ត ដោយពឹងផ្អែកលើច្បាប់សារធាតុ និងផ្តោតសំខាន់ជាមួយការរស់នៅជាក់ស្តែងក្នុងសង្គមជាកត្តាចម្បង។

ជាចុងក្រោយ ខ្ញុំ សង្ឃឹមយ៉ាងមុតមាំថា ការសរសេរសារណា ពីប្រធានបទមួយនេះ ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ និងចំណេះដឹង ដ៏ច្រើន សម្រាប់អ្នកសិក្សាទូទៅ ក្នុងការសិក្សាស្រាវជ្រាវ និងជាពន្លឺ ដើម្បីជម្រុញឲ្យសិស្សានុសិស្សទាំងអស់បានក្រេបជញ្ជក់ និងសិក្សាបន្ថែម។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងធ្វើសេចក្តីសន្និដ្ឋានជារួម លើប្រធានបទ "ស្មុំកូនពេញលេញ" ទាំងមូលរួចមក ក្នុងនាមពួកខ្ញុំជានិស្សិតផ្នែកនីតិសាស្រ្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងជាប្រជាពលរដ្ឋកម្ពុជា ពួកខ្ញុំសូមផ្តល់អនុសាសន៍ខ្លះៗ ក្នុងគោលបំណងចង់ឱ្យសិស្ស-និស្សិត ព្រមទាំងប្រជាពលរដ្ឋទាំងអស់ បានយល់ដឹងបន្ថែមពីច្បាប់ និងនីតិវិធីនៃការស្មុំកូនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ជាពិសេសការស្មុំកូនដែលមានលក្ខណៈពេញលេញទៅតាមវិធានច្បាប់។ ដោយសង្កេតឃើញថា បញ្ហាស្មុំកូននៅប្រទេសកម្ពុជា នៅតែជាបញ្ហាចោទយ៉ាងធ្ងន់ធ្ងរឈានទៅដល់ការបង្កើតឲ្យមានវិវាទរវាងកូនសុំនឹងម្តាយចិញ្ចឹម កូនសុំនឹងម្តាយបង្កើត ម្តាយបង្កើតនឹងម្តាយចិញ្ចឹមជាដើម។ល។

ទន្ទឹមនឹងនេះក្រសួងស្ថាប័ន និងអាជ្ញាធរដែលពាក់ព័ន្ធទាំងអស់ គួរគប្បីចាត់វិធានការផ្សព្វផ្សាយ ក៏ដូចជាចែករំលែកនូវរាល់ការយល់ដឹងអំពីវិធានច្បាប់នានាឲ្យបានទូលំទូលាយនៅតាមមូលដ្ឋានជនបទដូចជា គួរតែបញ្ចូលច្បាប់សំខាន់ៗនានា ក្នុងកម្មវិធីសិក្សាថ្នាក់បឋមភូមិ និងទុតិយភូមិដើម្បីឲ្យប្អូនៗជាសិស្សបានយល់ចាប់ពីថ្នាក់កម្រិតមធ្យមមក។ មិនតែប៉ុណ្ណោះផ្សព្វផ្សាយតាមបណ្តាញសង្គម ឬតាមរយៈទូរទស្សន៍ វិទ្យុ កាសែតព្រមទាំងជម្រុញ ឲ្យមានការពន្យល់ និងបកស្រាយឲ្យបានច្បាស់លាស់ពីបញ្ហាស្មុំកូន។ ម្យ៉ាងវិញទៀត អាជ្ញាធរមានសមត្ថកិច្ច គួរខិតខំស្វែងរកដំណោះស្រាយ ដើម្បីបញ្ឈប់ការជួញដូរកុមារ ការកេងប្រវ័ញ្ចផលប្រយោជន៍កុមារតាមរយៈរូបភាពនៃការស្មុំកូន ដើម្បីឲ្យប្រជាជនយើងបានយល់ដឹងពីការស្មុំកូនដែលលក្ខណៈត្រឹមត្រូវ តាមវិធានច្បាប់របស់ប្រទេសកម្ពុជា ក្នុងគោលបំណងប្រកាន់ខ្ជាប់ការគោរព និងការការពារឧត្តមប្រយោជន៍របស់កុមារ ការទប់ស្កាត់និងបង្ការនូវរាល់វិវាទទាំងឡាយណាដែលកើតឡើងតាមរយៈការស្មុំកូនជាដើម។

ជាចុងក្រោយនេះ ប្រជាពលរដ្ឋទាំងអស់គ្នា គប្បីនាំគ្នាគោរពច្បាប់ដែលមានចែងក្នុងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា និងជួយការពារផលប្រយោជន៍ និងសិទ្ធិកុមារ ជៀសវាងការប្រើអំពើហិង្សា ឬទារុណកម្ម ឬបង្កើតការស្មុំកូនក្នុងគោលបំណងទុច្ចរិត នាពេលអនាគត។

# ឯកសារយោង

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួនណាត
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១១
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី
- ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ
- មេរៀន ភាគ ៣ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១៧
- http://lovingkhmer.blogspot.com/ ( នីតិវិធីសុំកូនពេញលេញ)
- http://ciclg.com/ (យល់ដឹងផ្នែកច្បាប់ ការកាត់កាលកូន)

# ឧបសម្ព័ន្ធ

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២

## សុំកូន

### កថាភាគទី ១

### សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្ដាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្ដាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្ដីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.–** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

**មាត្រា ១០១៦.–** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.-** អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.-** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ ។

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្ដីពីសុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទបញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២

## សុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ៥ : គន្ថីទី ៧

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០១០

## ផ្នែកទី ២ សុំកូន

### កថាភាគទី ១ សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

(កំណត់)

មាត្រានេះបញ្ញត្តអំពីសុំកូនពេញលេញដែលកើតឡើងតាមសេចក្តីសម្រេចរបស់តុលាការ ក្រោមល័ក្ខខ័ណ្ឌយ៉ាងតឹងរ៉ឹងដែលតម្រូវឱ្យមានការពាក់ព័ន្ធពីតុលាការ ដោយខុសពីសុំកូនធម្មតាដែលជាសុំកូនតាមទម្រង់កិច្ចសន្យា និង កើតឡើងតាមការព្រមព្រៀងសុំកូន និង ការដាក់ពាក្យសុំចុះបញ្ជីសុំកូន ។ សុំកូនតាមទម្រង់កិច្ចសន្យា គឺជាករណីដែលភាគច្រើនទំនាក់ទំនងត្រូវបានចង ដោយពិចារណាទៅលើ "ស្ថានភាពរបស់មនុស្សពេញវ័យ" ប៉ុន្តែ ប្រព័ន្ធសុំកូនពេញលេញរបស់កម្ពុជា កំណត់យកអនីតិជនដែលមានស្ថានភាពគ្រួសារមិនអំណោយផលធ្វើជាកម្មវត្ថុ ដោយតម្រូវឱ្យមានការស្រាវជ្រាវ និង វិនិច្ឆ័យដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍របស់កុមារ ហើយសុំកូនប្រភេទនេះ មានគោលបំណងបង្កើតឡើងនូវទំនាក់ទំនងមួយដែលដូចគ្នាទៅនឹងទំនាក់ទំនងនៃឪពុកម្តាយ និង កូនបង្កើតដូច្នេះដែរ ។

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា សុំកូនពេញលេញមានសុពលភាព តែក្នុងករណីដែលមានការប្រកាសរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាលប៉ុណ្ណោះ ។ ដោយឡែកមាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក៏ទាមទារឱ្យមានការពិចារណាជាអតិបរមាលើឧត្តមប្រយោជន៍របស់កុមារ ដោយអាជ្ញាធរមានសមត្ថកិច្ចដែរ ។ សុំកូនពេញលេញ កើតឡើងតាមទម្រង់នៃការផ្តាច់ទំនាក់ទំនងចាស់ ដោយសាលក្រមរបស់សាលាដំបូង (tribunal de grande instance) ក្នុងករណីប្រទេសបារាំង ឬ តុលាការអាណាព្យាបាល (Vormundshaftsgericht) ក្នុងករណីប្រទេសអាល្លឺម៉ង់ ដោយដីកាសម្រេចរបស់តុលាការអនីតិជន ក្នុងករណីនៃប្រទេសអ៊ីតាលី និង ដោយដីកាសម្រេចរបស់តុលាការក្នុងករណីសហរដ្ឋអាមេរិក និង ប្រទេសអង់គ្លេស ។ មាត្រា ៨១៧-២ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា សុំកូនពិសេស (ពេញលេញ) ត្រូវបង្កើតឡើងតាមសេចក្តីសម្រេចរបស់តុលាការគ្រួសារ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៤ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប, មាត្រា ២១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៨១៧-២ នៃ

ក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១-២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥២ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "សុំកូនគឺជាកិច្ចសន្យាមួយយ៉ាងឧឡារិកដែលចងបុគ្គលពីរ គឺម្នាក់ ហៅថា ឪពុកសុំ ហើយម្នាក់ទៀត ហៅថា កូនសុំ ឱ្យមានចំណងទាក់ទងគ្នាដូចជាបុត្តភាពមានខាន់ស្លាដែរ" ។

មាត្រា ១០៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ : "សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា" ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

(កំណត់)

សុំកូនពេញលេញគឺជាការផ្តល់នូវគ្រួសារដែលមានឪពុកម្តាយ និង មានលំនឹងគ្រប់គ្រាន់ ដល់កុមារដែលអភ័ព្វ ដូច្នេះមាត្រានេះបានអនុម័តយកគោលការណ៍សុំកូនដោយសហការរវាងប្តីប្រពន្ធ ។ ក៏ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ពោលគឺករណីដែលអនាគតកូនចិញ្ចឹមត្រូវជាកូនចុងនោះ សុំកូនមិនចាំបាច់ត្រូវមានការសហការរវាងប្តីប្រពន្ធទេ ។

មាត្រា ៦ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ទុកលទ្ធភាពឱ្យច្បាប់របស់ប្រទេសនីមួយៗកំណត់ល័ក្ខខ័ណ្ឌថា ត្រូវទទួលស្គាល់សុំកូន តែចំពោះករណីដែលប្តី និង ប្រពន្ធសុំដោយសហការគ្នាប៉ុណ្ណោះ ឬ ទទួលស្គាល់សុំកូនដោយសហព័ទ្ធតែម្ខាងដោយគ្រាន់តែទទួលការយល់ព្រមរបស់សហព័ទ្ធម្ខាងទៀត ។ តាមច្បាប់អង់គ្លេស ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ (កថាខណ្ឌទី ៣ នៃមាត្រា ១៧៤១) កថាខណ្ឌទី ១ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៣៤៦ នៃក្រមរដ្ឋប្បវេណីបែលហ្ស៊ិក ក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក និង មាត្រា ៩៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់រុស្ស៊ី អ្នកនៅលីវក៏ត្រូវបានទទួលស្គាល់ថា មានលក្ខណសម្បត្តិជាឪពុក ឬ ម្តាយចិញ្ចឹមដែរ ។ ផ្ទុយទៅវិញ ច្បាប់អ៊ីតាលី និង មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន អនុម័តយកគោលការណ៍សុំកូនដោយការសហការរវាងប្តីប្រពន្ធ ។ ក្រៅពីនេះ ប្រទេសមួយចំនួនទៀតដែលកំណត់យកគោលការណ៍សុំកូនដោយសហការរវាងប្តី និង ប្រពន្ធ មានដូចជាប្រទេសស្វីស ដាណឺម៉ាក និង ស៊ុយអែត ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៣ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៨ និង មាត្រា ៤៤ នៃច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់អ៊ីតាលី

មាត្រា ៣២០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "ស្ត្រីគ្មានប្តីអាចសុំកូនគេចិញ្ចឹមបានដែរ" ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

(កំណត់)

អាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹមកំណត់ត្រឹម ២៥ ឆ្នាំ ហើយគម្លាតរវាងអាយុនៃឪពុកម្តាយចិញ្ចឹម និង អាយុរបស់កូនសុំ ដើម្បីឱ្យមើលទៅសមជាឪពុកម្តាយ និង កូន គឺ ២០ ឆ្នាំ ។

មាត្រានេះបានបញ្ញត្តនូវអាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹម និង គម្លាតអាយុសមរម្យរវាងឪពុកម្តាយ និង កូន ដោយបានសិក្សាអំពីទំនៀមទម្លាប់របស់កម្ពុជា ដោយសារមានការចាំបាច់តម្រូវឱ្យមានភាពចាស់ទុំទាំងផ្នែកស្មារតី និង រាងកាយ ដើម្បីបីបាច់ថែរក្សាដាក់ស្នែងនូវទារក ឬ កូនក្មេង ។

កិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់យកអាយុលើសពី ២១ ឆ្នាំ និង ក្រោម ៣៥ ឆ្នាំ ធ្វើជាបទដ្ឋាននីតិកម្មទាក់ទងនឹងអាយុអប្បបរមា ។ ប៉ុន្តែ នីតិកម្មនៃបណ្តាប្រទេសផ្សេងៗកំណត់យកខុសៗគ្នា ឧទាហរណ៍ដូចជាការកំណត់យកអាយុអប្បបរមា ១៨ ឆ្នាំ (ជាអាយុឈានដល់នីតិភាពដែលកំណត់ដោយរដ្ឋកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសាររបស់ប្រទេសរុស្ស៊ី និង ច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី) អាយុលើសពី ២១ ឆ្នាំ (ច្បាប់ស្តីពីសុំកូនក្នុងតំបន់រដ្ឋធានីសហព័ន្ធអូស្ត្រាលី) អាយុលើសពី ២៥ ឆ្នាំ (មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់អាយុលើសពី ២៥ ឆ្នាំ ប៉ុន្តែ ដោយយោងតាមទំនាក់ទំនងជាមួយនឹងគោលការណ៍សុំកូនដោយសហការរវាងប្តីប្រពន្ធផងនោះ បើសហព័ទ្ធម្ខាងមានអាយុលើសពី ២៥ ឆ្នាំ សហព័ទ្ធម្ខាងទៀតមានអាយុលើសពី ២០ ឆ្នាំ គឺជាការគ្រប់គ្រាន់ រីឯក្រមរដ្ឋប្បវេណីបារាំង តម្រូវឱ្យមានអាយុលើសពី ២៨ ឆ្នាំ ហើយត្រូវមានគម្លាតអាយុលើសពី ១៥ ឆ្នាំឡើងទៅ ។ ចំណែកឯក្រមរដ្ឋប្បវេណីបែលហ្ស៊ិកក៏ទាមទារឱ្យមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងហោចណាស់ ១៥ ឆ្នាំ ។ ក្រៅពីនេះ នៅមានមាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ច្បាប់ស្តីពីសុំកូនដាណឺម៉ាក ក្រមរដ្ឋប្បវេណីអេស្ប៉ាញ ជាអាទិ៍) ។ម្យ៉ាងទៀត ដោយហេតុថា គោលបំណងនៃសុំកូនពេញលេញ គឺការបីបាច់ថែទាំកុមារ ដូចគ្នាទៅនឹងឪពុកម្តាយ និង កូនបង្កើត ដូច្នេះ ទើបមានប្រទេសជាច្រើនទាមទារឱ្យមានគម្លាតអាយុប្រហែលចាប់ពី ១០ ទៅ ១៨ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៤ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៣-១-១ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៣៤៥ និង មាត្រា ៣៦៨ នៃក្រមរដ្ឋប្បវេណីបែលហ្ស៊ិក, មាត្រា ១៧៤៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា : "បុរសត្រូវមានអាយុជាង ២៥ ឆ្នាំ. ត្រូវបងកូនសុំ ២០ ឆ្នាំយ៉ាងតិច និង ត្រូវគ្មានកូនសោះ ទើបអាចសុំកូនគេចិញ្ចឹមបាន" ។

មាត្រា ១០៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា "ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស" ។

## មាត្រា ១០១០.- អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

(កំណត់)

ទាក់ទងនឹងចំនួនកូនសុំ យោងតាមទម្លាប់របស់កម្ពុជា សេចក្តីព្រាងដំបូងនៃក្រមនេះបានកំណត់ថា "(១) ឪពុកម្តាយចិញ្ចឹម អាចសុំកូនបាន ត្រឹម ២ (ពីរនាក់)" ប៉ុណ្ណោះ ។ សេចក្តីព្រាងនោះត្រូវបានរៀបចំឡើង ដោយមានមូលហេតុថា ដើម្បីឱ្យមានការបីបាច់ថែរក្សាកូនសុំឱ្យដូចជាកូនបង្កើត ចាំបាច់ត្រូវកម្រិតចំនួនកុមារដែលជាកូនសុំតាមសុំកូនពេញលេញ ។ ចំពោះសុំកូនអន្តរប្រទេស កូនសុំត្រូវបានកំណត់ត្រឹមមួយនាក់ប៉ុណ្ណោះ (អនុក្រឹត្យ លេខ ២៥ អនក្រ.បក ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាទៅចិញ្ចឹមជាកូននៅបរទេស ខែ មីនា ឆ្នាំ ២០០១) ។ ម្យ៉ាងវិញទៀត តាមរយៈការបង្កើតសុំកូនដើម្បីកសាងទំនាក់ទំនងដែលយកឪពុកម្តាយចិញ្ចឹមមកជាមេបាតែមួយគូ ដូចគ្នាជាមួយនឹងទំនាក់ទំនងជាមួយកូនបង្កើត កូនសុំនោះគួរមានអាយុក្រោមអាយុចូលរៀន ។ សុំកូនពេញលេញ គឺជាប្រព័ន្ធដែលផ្តល់ឪពុកម្តាយដល់កុមារតូចដែលត្រូវការបីបាច់ថែរក្សា ដូច្នេះ មាត្រានេះ ជាគោលការណ៍ កម្រិតតែចំពោះកុមារដែលមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំប៉ុណ្ណោះ ។

កថាខណ្ឌទី ១ មាត្រា ១២ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ហាមឃាត់ការកម្រិតដោយបញ្ញត្តិច្បាប់លើចំនួនកូនសុំដោយឪពុកម្តាយចិញ្ចឹមតែមួយ ហើយកថាខណ្ឌទី ២ នៃមាត្រាដដែលបញ្ញត្តថា "ជនដែលមានបំណងសុំកុមារធ្វើជាកូនសុំ មិនត្រូវហាមឃាត់សុំកូននោះដោយបញ្ញត្តិច្បាប់ ដោយសំអាងថា ជននោះមានកូនខាន់ស្លារួច ឬ កូនខាន់ស្លានឹងកើតមកនៅពេលខាងមុខឡើយ" មានន័យថា ហាមឃាត់ផងដែរចំពោះការដាក់ល័ក្ខខ័ណ្ឌលើលក្ខណសម្បត្តិរបស់ឪពុកម្តាយចិញ្ចឹមថា ត្រូវតែគ្មានកូន ។ ក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏មិនមានកម្រិតចំនួនកូនសុំដែរ ។ មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសកម្ពុជា កម្រិតចំនួនកូនសុំត្រឹមម្នាក់ប៉ុណ្ណោះ ប៉ុន្តែ មាត្រា ១១០ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ បានកំណត់យកចំនួនត្រឹម ២ នាក់ ។

មាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប កំណត់ថា កូនសុំត្រូវជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ នៅលីវ ឬ មិនដែលរៀបអាពាហ៍ពិពាហ៍ ។ ចំពោះសុំកូនធម្មានុរូបកម្ម (ដែលក្លាយជាកូនមានខាន់ស្លា) នៅប្រទេសបារាំង ពីមុនកំណត់អាយុក្រោម ៥ ឆ្នាំ ប៉ុន្តែ បច្ចុប្បន្នគឺកំណត់អាយុក្រោម ១៥ ឆ្នាំ ។ ម្យ៉ាងទៀត ច្បាប់ស្តីពីសុំកូនជាអនីតិជនរបស់ប្រទេសអ៊ីតាលី ឆ្នាំ ១៩៨៣ កំណត់ថា កុមារដែលអាចក្លាយជាកម្មវត្ថុនៃសុំកូន ត្រូវតែជាអនីតិជន ប៉ុន្តែ

ពីមុន បានកំណត់យកអាយុក្រោម ៨ ឆ្នាំ ។ មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន កំណត់ថា ជាគោលការណ៍ កូនសុំត្រូវមានអាយុក្រោម ៦ ឆ្នាំ នៅពេលដាក់ពាក្យសុំសុំកូន ប៉ុន្តែ ក្នុងករណីដែលកុមារមានអាយុក្រោម ៨ ឆ្នាំ ហើយកុមារនោះបានទទួលការបីបាច់រក្សាពីឪពុកម្តាយចិញ្ចឹមតាំងពីមុនពេលគ្រប់អាយុ ៦ ឆ្នាំ នេះ ជាករណីលើកលែង ទោះបីជាកុមារមានអាយុ ៨ ឆ្នាំ ក៏មិនមានបញ្ហាអ្វីដែរ ។ ច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់កម្ពុជា ដែលត្រូវបាន តាក់តែងឡើងឆ្នាំ ២០០៩ កំណត់អាយុក្រោម ៨ ឆ្នាំ នៅពេលដាក់ពាក្យសុំសុំកូន (កថាខណ្ឌទី ២ នៃមាត្រា ៤) ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៥ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦៧ នៃក្រម រដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣១៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "គេអាចសុំបានតែកូនមួយនាក់ប៉ុណ្ណោះ, ប្រសិនបើកូនដែលសុំមក នោះវា ស្លាប់ទៅ ហើយគ្មានកូនទៀតទេ គេអាចសុំកូនមួយនាក់ទៀតបាន" ។

មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំនោះត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

មាត្រា ១១០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិន បើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។ កូនចិញ្ចឹមត្រូវមានអាយុតិចជាង ៨ ឆ្នាំ" ។

## មាត្រា ១០១១.- ការយល់ព្រមរបស់ឪពុកម្តាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

(កំណត់)

សុំកូនពេញលេញ គឺជាការផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត និង មានគោលដៅយកកូនសុំនោះចូលទាំងស្រុង ក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះ ចាំបាច់ត្រូវតែមានការយល់ព្រមពីឪពុកម្តាយបង្កើតដែលមានទំនាក់ទំនងផល ប្រយោជន៍យ៉ាងជ្រាលជ្រៅជាមួយនឹងកុមារនោះ ។ ប៉ុន្តែ ក្នុងករណីដែលមានស្ថានភាពពិបាកនឹងទទួលការយល់ព្រមពី ឪពុកម្តាយបង្កើត ឬ ក្នុងករណីដែលការជំទាស់របស់ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារដែល នឹងក្លាយជាកូនសុំនោះ ការយល់ព្រមពីឪពុកម្តាយបង្កើត មិនចាំបាច់ឡើយ ។

កថាខណ្ឌទី ១ មាត្រា ៥ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប បញ្ញត្តថា ចំពោះកូនមានខាន់ស្លា ចាំបាច់ត្រូវមាន

ការយល់ព្រមពីឪពុកម្តាយ ហើយចំពោះកូនឥតខាន់ស្លា ចាំបាច់ត្រូវមានការយល់ព្រមពីម្តាយ ហើយក្នុងករណីដែលគ្មានឪពុកម្តាយ ចាំបាច់ត្រូវមានការយល់ព្រមពីជនដែលអនុវត្តអំណាចមេបាជំនួស ឬ អ្នកអាណាព្យាបាល ឬ ស្ថាប័នដែលអាចជំនួសអ្នកទាំងនេះបាន ។ កថាខណ្ឌទី ៣ នៃមាត្រាដដែលចែងអនុញ្ញាតឱ្យមានការចែងក្នុងច្បាប់ថា មិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយចំពោះសុំកូនឡើយ ក្នុងករណីដែលឪពុកម្តាយត្រូវបានដកហូតអំណាចមេបា ឬ សិទ្ធិបីបាច់ថែរក្សាគ្រប់គ្រងកូន ។

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ក៏ទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដែរ ( មាត្រា ១៧៤៥) ប៉ុន្តែ ក្នុងករណីដែលឪពុកម្តាយមិនអាចបង្ហាញឆន្ទៈបានជាបន្តឥតដាច់ ឬ ករណីដែលលំនៅឋានរបស់ឪពុកម្តាយមិនច្បាស់លាស់ មិនចាំបាច់មានការយល់ព្រមឡើយ ។ ក្រមរដ្ឋប្បវេណីបារាំងក៏បញ្ញត្តដែរថា ក្នុងករណីដែលសុខភាព និង ស្មារតីរបស់កុមារប្រឈមមុខនឹងគ្រោះថ្នាក់ ហើយឪពុកម្តាយមិនអើពើ ការមិនយល់ព្រមគឺជាការបំពានលើសិទ្ធិយល់ព្រម ដូច្នេះ ក៏មិនចាំបាច់តម្រូវឱ្យមានការយល់ព្រមដែរ ( មាត្រា ៣៤៧ និង មាត្រា ៣៤៨-២) ។ មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុនទាមទារឱ្យមានការយល់ព្រមពីឪពុកម្តាយដើម្បីបង្កើតសុំកូន ហើយក៏ចែងលើកលែងនូវករណីដែលមិនចាំបាច់មានការយល់ព្រមដែរ ។

ម្យ៉ាងទៀត ប្រសិនបើកំណត់អាយុរបស់កូនដែលអាចត្រូវបានសុំបានខ្ពស់ (ដោយវិសោធនកម្មនៃមាត្រា ១១០០) នៅប្រទេសបារាំង ចាំបាច់ត្រូវមានការយល់ព្រមពីក្មេងដែលមានអាយុលើសពី ១៣ ឆ្នាំ (កថាខណ្ឌទី ៣ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង) រីឯរដ្ឋកាលីហ្វ័រញ៉ា តម្រូវឱ្យមានការយល់ព្រមពីក្មេងអាយុលើសពី ១២ ឆ្នាំ (មាត្រា ៨៦០២ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ហើយប្រទេសកម្ពុជាក៏ដូចគ្នាដែរ ទាក់ទងនឹងទស្សនៈដែលការពារសិទ្ធិបញ្ចេញទស្សនៈរបស់ក្មេង (មាត្រា ១២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ) ចាំបាច់ត្រូវមានវិធានការផ្សេងៗនានា ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៦ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៤៨ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៧ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ៣២១ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុក និង ម្តាយមានខាន់ស្លា ឬ ឥតខាន់ស្លានៃកូនដែលឱ្យគេសុំនោះ ឬ បើគ្មានឪពុកម្តាយទេ, ជនជាអាណាព្យាបាលនៃកូននោះត្រូវឱ្យសេចក្តីព្រមព្រៀងរបស់ខ្លួនក្នុងកិច្ចសន្យាសុំកូននោះ" ។

មាត្រា ១១២ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "ដើម្បីឱ្យការសុំកូនសំរេចទៅបាន ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។ បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់" ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាង

ខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

( កំណត់ )

មាត្រានេះបញ្ញត្តអំពីមូលដ្ឋានសារធាតុដើម្បីវិនិច្ឆ័យក្នុងករណីដែលតុលាការបង្កើតសុំកូន ។ ប្រសិនបើតុលាការយល់ឃើញថា មិនសមរម្យឱ្យឪពុកម្ដាយគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្ដាយបាត់ខ្លួន ឬ មានវិបត្តិផ្នែករាងកាយដែលធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឬ ឪពុកម្ដាយដែលធ្វើបាប ឬ បោះបង់កូនចោល ហើយយល់ឃើញថា ដើម្បីផលប្រយោជន៍កុមារ ចាំបាច់ត្រូវតែបញ្ចប់ញាតិភាពជាមួយឪពុកម្ដាយនោះ ហើយបង្កើតសុំកូនជាមួយឪពុកម្ដាយចិញ្ចឹម ទើបតុលាការអាចសម្រេចឱ្យបង្កើតសុំកូនបាន ។

មាត្រា ៨ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប កំណត់ថា អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការប្រកាសសុំកូនបាន តែក្នុងករណីដែលបានជឿជាក់ថា សុំកូននោះនឹងធានាដល់ផលប្រយោជន៍របស់កុមារប៉ុណ្ណោះ ដោយសង្កត់ធ្ងន់ជាពិសេសថា តាមការប្រកាសសុំកូននេះ នឹងផ្ដល់ឱ្យកុមារនូវគ្រួសារដែលមានស្ថិរភាព និង ភាពសុខដុមរមនា ។ មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ក៏បញ្ញត្តដែរថា ប្រព័ន្ធសុំកូនត្រូវធានាថា ឧត្ដមប្រយោជន៍របស់កុមារត្រូវស្ថិតក្នុងការពិចារណាខ្ពស់បំផុត ។ កថាខណ្ឌទី ១ មាត្រា ៣៥៣ នៃក្រមរដ្ឋប្បវេណីបារាំង កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វ៊ីស ច្បាប់អង់គ្លេស និង កថាខណ្ឌ C មាត្រា ១៣ នៃក្រមឯកភាពស្ដីពីសុំកូនរបស់អាមេរិក ក៏ទាមទារឱ្យសុំកូនឆ្លើយតបដោយជាក់លាក់ទៅនឹងសុខុមាលភាពកុមារ និង ឧត្ដមប្រយោជន៍របស់កុមារដែរ ។

មាត្រានេះក៏យកលំនាំដូចគ្នាតាមមាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៤៧ នៃក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧ មាត្រា ៨ និង មាត្រា ២៥ នៃច្បាប់ស្ដីពីសុំកូនជាអនីតិជនរបស់អ៊ីតាលីដែលចែងថា អាចបង្កើតសុំកូនបានចំពោះកូនដែលត្រូវបានបោះបង់ ដែលមិនអាចទទួលបានការបីបាច់ថែរក្សាឱ្យបានសមរម្យពីឪពុកម្ដាយ ឬ កុមារដែលត្រូវការពារជាចាំបាច់ ។

( មាត្រាពាក់ព័ន្ធ )

មាត្រា ៨១៧-៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៣-១ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ១ មាត្រា ១៧៤១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ២១ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ

## មាត្រា ១០១៣.- អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយ

ជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

(កំណត់)

មាត្រានេះបានបញ្ញត្តអំពីអំឡុងពេលកំណត់មួយនៃការសាកល្បងចិញ្ចឹម ដើម្បីពិនិត្យមើលជាក់ស្តែងថា តើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរ ឬទេ ហើយតើអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំដែរ ឬទេ និងថា តើមានភាពចុះសម្រុងគ្នារវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមដែរ ឬយ៉ាងណា ។

មាត្រា ១៧ នៃកិច្ចព្រមព្រៀងស្តីពីសុំកូនអឺរ៉ុប ចែងថា អាជ្ញាធរមានសមត្ថកិច្ចត្រូវពិនិត្យមើលស្ថានភាពគ្រប់គ្រងថែរក្សាកូនសុំដោយឪពុកម្តាយចិញ្ចឹមថា តើសុំកូនឆ្លើយតបនឹងផលប្រយោជន៍របស់កុមារដែរ ឬទេ ក្នុងអំឡុងពេលសមរម្យចាំបាច់ដើម្បីឱ្យអាចវាយតម្លៃបានគ្រប់គ្រាន់ ។ មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង និង មាត្រា ១២ នៃក្រមឯកភាពស្តីពីសុំកូនរបស់អាមេរិក ជាដើម បានកំណត់អំឡុងពេលជាគោលការណ៍ ចំនួន ៦ ខែ ប៉ុន្តែ ប្រទេសអ៊ីតាលីកំណត់ ១ ឆ្នាំ រីឯមាត្រា ២៦៤ នៃក្រមរដ្ឋប្បវេណីស្វីស កំណត់ ២ ឆ្នាំ ហើយមាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ កំណត់អំឡុងពេលសមរម្យ ។ ក៏ប៉ុន្តែ ប្រសិនបើមានកំណត់ហេតុនៃស្ថានភាពគ្រប់គ្រងថែរក្សាកុមារតាំងពីដើមមក នៅក្នុងមណ្ឌលពិគ្រោះស្តីពីកុមារ ជាអាទិ៍ ហើយតុលាការអាចយកឯកសារទាំងនោះមកធ្វើជាធនធានសម្រាប់ការវិនិច្ឆ័យបាន នោះតុលាការអាចប្រើប្រាស់ឯកសារបាន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ១ មាត្រា ៣៤៥ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

(កំណត់)

របបសុំកូនពេញលេញមានគោលបំណងចិញ្ចឹមកុមារដែលបានសុំ ឱ្យដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះ កូនសុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម ។ បានសេចក្តីថា ការចូលជ្រៀតជ្រែក ឬ ការរំខានមិនសមស្របពីឪពុកម្តាយបង្កើត ដូចជា ការទាមទារយកកូនវិញ ឬ ការទាមទារចរចាជួបកូន

ជាដើម ត្រូវហាមឃាត់ ហើយអំពើតាមទំនើងដូចជាការទាមទារអាហារកាតព្វកិច្ចពីកូន នៅពេលដែលកូននោះពេញវ័យជាដើម ក៏ចាំបាច់ត្រូវដាក់ការរឹតត្បិតផងដែរ ។ ហេតុដូច្នេះ មាត្រានេះបានកំណត់ឱ្យបញ្ចប់ និង ផ្ដាច់ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ តាមរយៈការបង្កើតសុំកូនពេញលេញ ។

ក៏ប៉ុន្តែ ក្នុងករណីដែលសហព័ទ្ធម្ខាងសុំកូនដែលជាកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ដូចជាកូនសុំដែលជាកូនចុងការសុំកូនដោយសហព័ទ្ធតែម្ខាងជាការគ្រប់គ្រាន់ ហើយចំពោះការគ្រប់គ្រងថែរក្សាក្នុងនាមជាឪពុក ឬ ម្ដាយបង្កើតរបស់សហព័ទ្ធម្ខាងទៀត មិនចាំបាច់ឱ្យមានការបញ្ចប់ទំនាក់ទំនងញាតិភាពជាមួយនឹងឪពុក ឬ ម្ដាយបង្កើតនោះ និង ជាមួយញាតិលោហិតរបស់ឪពុក ឬ ម្ដាយបង្កើតនោះឡើយ ។

កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប បានកំណត់ថា សុំកូនបង្កើតឱ្យមានទំនាក់ទំនងគតិយុត្តរវាងកូនសុំ និង ឪពុកម្ដាយចិញ្ចឹម ដូចគ្នានឹងទំនាក់ទំនងរវាងឪពុកម្ដាយ និង កូនមានខាន់ស្លាដែរ ហើយជាមួយគ្នានេះ ក៏រំលត់នូវទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើតផងដែរ ក៏ប៉ុន្តែនៅពេលដែលកូនសុំជាកូនមានខាន់ស្លា ឬ ឥតខាន់ស្លា ឬ កូនសុំរបស់សហព័ទ្ធម្ខាងទៀតរបស់ឪពុក ឬ ម្ដាយចិញ្ចឹមបញ្ញត្តិច្បាប់អាចកំណត់ទុកជាមុនថា សហព័ទ្ធម្ខាងទៀតនោះ ត្រូវប្រកាន់ខ្ជាប់នូវសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនដែលមានចំពោះកូនសុំ ។ រាល់បណ្ដាប្រទេសដែលអនុម័តយកសុំកូនពេញលេញ ឬ សុំកូនដោយផ្ដាច់ទំនាក់ទំនង តែងតែមានបញ្ញត្តិប្រភេទនេះជានិច្ច ( មាត្រា ៣៥៦ ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ និង មាត្រា ២៦៧ នៃក្រមរដ្ឋប្បវេណីស្វីស ជាដើម) ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៦ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៥៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

### មាត្រា ១០១៥.- អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្ដាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ

ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ។

(កំណត់)

មាត្រានេះបញ្ញត្តថា កូនសុំត្រូវបានធ្វើឱ្យដូចជាកូនមានខាន់ស្លាទាំងស្រុង ក្នុងទំនាក់ទំនងរបស់កូនសុំជាមួយនឹងឪពុកម្ដាយចិញ្ចឹម ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើតដែរ ។ បានសេចក្ដីថា កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម (នាមត្រកូលរបស់ក្មេងនៅកម្ពុជា ជាទម្លាប់ គេអនុញ្ញាតឱ្យជ្រើសរើស) ហើយនៅពេលដែលកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្ដាយចិញ្ចឹម ។ ដូចជាកូនបង្កើតដែរ កូនសុំក៏មានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ សន្តតិកម្មពីឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ គឺជាប្រព័ន្ធដែលមានបំណងគ្រប់គ្រងថែរក្សាកូនសុំ ដោយយកក់ក្ដៅ ដូចជាកូនបង្កើត នៅក្នុងគ្រួសាររបស់ឪពុកម្ដាយចិញ្ចឹម ដូច្នេះ ឋានៈរបស់កូនសុំនោះត្រូវបានធានាឱ្យដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ។

កថាខណ្ឌទី ១ មាត្រា ១០ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប បញ្ញត្តថា សុំកូនផ្ដល់ចំពោះឪពុកម្ដាយចិញ្ចឹមនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលឪពុកម្ដាយបង្កើតមានចំពោះកូនមានខាន់ស្លា ក្នុងទំនាក់ទំនងចំពោះកូនសុំ ហើយក៏ផ្ដល់ឱ្យកូនសុំនោះនូវគ្រប់សិទ្ធិ និង ករណីយកិច្ចដែលកូនមានខាន់ស្លាមានចំពោះឪពុកម្ដាយបង្កើត ក្នុងទំនាក់ទំនងរបស់កូនសុំនោះចំពោះឪពុកម្ដាយចិញ្ចឹមដែរ ។ សុំកូនពេញលេញ ក្នុងបណ្ដាប្រទេសដូចជា ប្រទេសអ៊ីតាលី អាល្លឺម៉ង់ បារាំង សហរដ្ឋអាមេរិក (មាត្រា ៨៦១៦ ដល់ មាត្រា ៨៦១៨ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ប្រទេសអង់គ្លេស និង ស្វីស ជាដើម សុទ្ធតែមានបញ្ញត្តិបែបនេះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨០៩ មាត្រា ៨១០ និង កថាខណ្ឌទី ២ មាត្រា ៨១៨ នៃក្រមរដ្ឋប្បវេណីជប៉ុន. មាត្រា ៣៥៥ មាត្រា ៣៥៦ មាត្រា ៣៥៧ និង មាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណីបារាំង

មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "សុំកូននេះមានអានុភាពឱ្យកូននោះ ឆ្លងពីភាពជាកូននៃគ្រួសារមានខាន់ស្លា ឬ ឥតខាន់ស្លាមួយ ទៅជាកូននៃគ្រួសាររបស់អ្នកសុំវិញ" ។

មាត្រា ៣២៦ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "កូនសុំត្រូវយកនាមត្រកូលនៃឪពុកសុំ. កូនសុំត្រូវមានកាតព្វកិច្ច និង ករណីយកិច្ច ចំពោះឪពុកសុំ និង គ្រួសាររបស់ឪពុកសុំ ដូចជាកូនបង្កើតដែរ" ។

មាត្រា ៣២៧ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា : "ឪពុកសុំត្រូវបីបាច់រក្សាកូនសុំ ដូចជាកូនខ្លួនបង្កើតដែរ" ។

មាត្រា ១១៤ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "កូនចិញ្ចឹមត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើត" ។

**មាត្រា ១០១៦.-** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ

តុលាការអាចកាត់កាល់ភាតីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្ដាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក- បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ- បើឪពុកម្ដាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

សុំកូនពេញលេញ មានបំណងផ្ដល់នូវការគ្រប់គ្រងថែរក្សាដូចជាកូនបង្កើត ដូច្នេះ ជាគោលការណ៍ ការកាត់កាល់មិនត្រូវបានទទួលស្គាល់ឡើយ ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបន្តទំនាក់ទំនងសុំកូនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍កុមារ ឬ ក៏ក្នុងករណីដែលអាចរំពឹងបាននូវការគ្រប់គ្រងថែរក្សាដោយគ្រប់គ្រាន់ដោយឪពុកម្ដាយបង្កើត ជាករណីលើកលែង បញ្ញត្តិនេះទទួលស្គាល់ការរំលាយសុំកូនបាន ។

កថាខណ្ឌទី ១ មាត្រា ១៣ នៃកិច្ចព្រមព្រៀងស្ដីពីសុំកូនអឺរ៉ុប កំណត់ថា ក្នុងអំឡុងពេលដែលកូនសុំមិនទាន់ដល់នីតិភាព សុំកូនអាចត្រូវបានលុបចោលបាន តាមការសម្រេចរបស់អាជ្ញាធរតុលាការ ឬ អាជ្ញាធររដ្ឋបាល តែក្នុងករណីដែលមានមូលហេតុធ្ងន់ធ្ងរប៉ុណ្ណោះ ។ បើមើលជាឧទាហរណ៍នៃបញ្ញត្តិច្បាប់របស់បណ្ដាបស្ចឹមប្រទេសដែលមិនទទួលស្គាល់របបកាត់កាល់ មានដូចជាមាត្រា ៣៥៩ នៃក្រមរដ្ឋប្បវេណីបារាំង និង ច្បាប់ប្រទេសអង់គ្លេស ស្វីស អ៊ីតាលី និងស៊ុយអែត ជាដើម ។ ក៏ប៉ុន្តែ មាត្រា ១៧៦០ និង ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១៨ និង មាត្រា ១៩ នៃច្បាប់ស្ដីពីសុំកូនដាណឺម៉ាក និង មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន ជាដើម បានទទួលស្គាល់ការកាត់កាល់ក្នុងករណីដែលមានស្ថានភាពជាក់លាក់មួយ (ដូចជាករណីដែលសមស្របទៅនឹងផលប្រយោជន៍របស់កុមារ ឬ ករណីដែលមានការបំពានករណីយកិច្ចរបស់ឪពុកម្ដាយចិញ្ចឹម ដូចជាការវាយធ្វើបាបដោយហិង្សាដោយឪពុកម្ដាយចិញ្ចឹម ជាដើម) ។ នៅរដ្ឋកាលីហ្វ័រញ៉ា ការលុបចោលដីកាសម្រេចបង្កើតសុំកូនពេញលេញ ដោយយកវិបត្តិក្នុងអភិវឌ្ឍន៍តាំងពីមុនពេលសុំកូន ឬ វិបត្តិផ្នែកស្មារតី ជាដើម មកជាមូលហេតុ ត្រូវបានទទួលស្គាល់ ក្នុងអំឡុងពេល ៥ ឆ្នាំ ហើយរបបលុបចោលនេះមានលក្ខណៈសារធាតុជាការកាត់កាល់ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១០ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៦០ និង មាត្រា ១៧៦៣ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

មាត្រា ១១៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និង គ្រួសារកម្ពុជា : "តុលាការប្រជាជន អាចបដិសេធកិច្ចសន្យា (សុំកូន) បាន តាមពាក្យប្ដឹងសុំរបស់កូនចិញ្ចឹម របស់ជនទាំងឡាយ ឬ របស់អង្គការផ្សេងៗ ដែលធ្វើឡើងដើម្បីផល ប្រយោជន៍របស់កូនចិញ្ចឹមនោះ" ។

## មាត្រា ១០១៧.- អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

(កំណត់)

មាត្រានេះអនុម័តយកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិនូវញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត និង ញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្ដាយបង្កើត ដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូន នៅពេលដែលសុំកូនពេញលេញត្រូវបានរំលាយដោយការកាត់កាល់ ។

នៅក្នុងនីតិកម្មដែលទទួលស្គាល់ការកាត់កាល់ នៅមានការខ្វែងគំនិតគ្នាលើចំណុចថា តើញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត និង គ្រួសាររបស់ឪពុកម្ដាយបង្កើតដែលបានបញ្ចប់ដោយការបង្កើតសុំកូន ត្រូវបានបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិ ឬ យ៉ាងណានោះ ។ ប្រទេសជប៉ុន អាល្លឺម៉ង់ អូស្ត្រាលី និង រុស្ស៊ី ជាដើម ប្រកាន់យកទស្សនៈនៃការបង្កើតឡើងវិញដោយស្វ័យប្រវត្តិ ចំណែកឯប្រទេសដាណឺម៉ាកប្រកាន់យកជំហរផ្សេងៗខុសគ្នា អាស្រ័យទៅតាមអាយុរបស់កុមារ ឬ មូលហេតុនៃការកាត់កាល់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨១៧-១១ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៣៥៩ និង មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ១៧៤៦ និង មាត្រា ១៧៦៥ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

## មាត្រា ១០១៨.- ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្ដីពីសុំកូនឡើយ ។

(កំណត់)

ក្នុងករណីដែលសុំកូនពេញលេញគឺជាការសង្គ្រោះចំពោះកុមារអភ័ព្វ ការបង្ហាញនូវអង្គហេតុនៃសុំកូន អាចបំពានភាពឯកជន ហើយផ្ដល់បច្ច័យអាក្រក់ដល់ការរីកចម្រើនល្អតលាស់ដ៏ល្អរបស់កុមារ ។ ម្យ៉ាងទៀត ការបង្ហាញដូច្នេះ

ក៏នាំឱ្យមានហានិភ័យ ដូចជាការមកជ្រៀតជ្រែកដោយគ្មានការរំពឹងទុកពីសំណាក់ឪពុកម្តាយបង្កើត ដែលធ្វើឱ្យស្ថានភាពគ្រួសារកូនសុំ មានភាពច្របូកច្របល់ ឬ មិនអាចរក្សាបាននូវបរិស្ថានរីកចម្រើនល្អតលាស់ដែលមានលំនឹងសម្រាប់កុមារ ។ ដូច្នេះហើយ មាត្រានេះបានកំណត់ថា បញ្ជីអត្រានុកូលដ្ឋាន និង សំបុត្រកំណើតថ្មី របស់សុំកូនដែលធ្វើឡើងដោយការបង្កើតសុំកូនពេញលេញ មិនត្រូវសរសេរអំពីឈ្មោះរបស់ឪពុកម្តាយបង្កើត ឬ ចំណុចស្តីពីសុំកូនឡើយ ហើយត្រូវចុះថាឪពុកម្តាយចិញ្ចឹម គឺជាឪពុកម្តាយបង្កើត ។

មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង បញ្ញត្តថា សាលក្រម ឬ សាលដីកាដែលប្រកាសបង្កើតសុំកូនពេញលេញត្រូវចុះនៅក្នុងបញ្ជីអត្រានុកូលដ្ឋាននៅកន្លែងកំណើតរបស់កូនសុំ ក្នុងអំឡុងពេល ១៥ ថ្ងៃ តាមពាក្យសុំរបស់ព្រះរាជអាជ្ញា ដោយសរសេរនូវថ្ងៃ និង ម៉ោងកំណើត ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយចិញ្ចឹម ជាអាទិ៍ ដោយមិនចុះអ្វីទាក់ទងនឹងឪពុកម្តាយបង្កើតឡើយ ហើយការចុះបញ្ជីនេះនឹងជំនួសឱ្យសំបុត្រកំណើតរបស់កូនសុំ ។ ក្នុងរដ្ឋកាលីហ្វ័រញ៉ា ក្នុងករណីសុំកូនពេញលេញ សំបុត្រកំណើតថ្មីដែលធ្វើឱ្យឪពុកម្តាយចិញ្ចឹមដូចជាឪពុកម្តាយបង្កើត ត្រូវបានចេញ ហើយសំបុត្រកំណើតចាស់ ត្រូវបានបញ្ចូលក្នុងស្រោមសំបុត្រ និង បិទជិត ហើយបោះត្រា (មាត្រា ៨៦១៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

(មាត្រាពាក់ព័ន្ធ)

កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ, មាត្រា ៣៥៤ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ១០១៩.-** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

(កំណត់)

មាត្រា ៩២០០ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា កំណត់ថា ការមើលឯកសារពាក់ព័ន្ធនឹងការសម្រេចស្តីពីសុំកូន ដូចជាពាក្យសុំនៃសុំកូន លិខិតលះបង់អំណាចមេបា លិខិតយល់ព្រម របាយការណ៍ពីស្ថាប័នសម្របសម្រួលសុំកូន ជាដើម មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមានស្ថានភាពជាពិសេស និង បញ្ជាក់មូលហេតុត្រឹមត្រូវ ។ ក៏ប៉ុន្តែ ប្រព័ន្ធបង្ហាញព័ត៌មានទាក់ទងនឹងកូនសុំ ត្រូវបានរៀបចំដែរ ដោយមានខ្លឹមសារថា ប្រសិនបើមានការយល់ព្រមពីឪពុកម្តាយបង្កើតជាលាយល័ក្ខណ៍អក្សរ និង មានពាក្យសុំរបស់កូនសុំដែលមានអាយុលើសពី ២១ ឆ្នាំ ស្ថាប័នសម្របសម្រួលសុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់ឪពុកម្តាយបង្កើតដល់កូនសុំបាន ហើយប្រសិនបើមានការ

យល់ព្រមពីកូនសុំដែលបានដល់នីតិភាព ស្ថាប័នសម្របសម្រួលសុំកូន ឬ មន្ទីរសង្គមកិច្ចស្រុក ក៏អាចបង្ហាញនូវឈ្មោះ និង អាសយដ្ឋានរបស់កូនសុំដល់ឪពុកម្តាយបង្កើតបានដែរ (មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។ ក្រៅពីនេះ ក៏មានប្រព័ន្ធរៀបចំឱ្យមានការជួបមុខដោយផ្ទាល់រវាងកូនសុំដែលបានដល់នីតិជន និង ឪពុកម្តាយបង្កើត ឬ បងប្អូនបង្កើតផងដែរ ប្រសិនបើមានការយល់ព្រមជាលាយល័ក្ខណ៍អក្សរ (មាត្រា ៩២០៤ និង មាត្រា ៩២០៥ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា) ។

យោងតាមការពិភាក្សា មាត្រានេះមិនកំណត់ឱ្យមានការយល់ព្រមពីឪពុកម្តាយបង្កើតជាល័ក្ខខ័ណ្ឌឡើយ ហើយទទួលស្គាល់នូវសិទ្ធិទាមទារឱ្យបង្ហាញនូវសំណុំរឿងស្តីពីសុំកូនដែលតុលាការរក្សាទុក ក្នុងករណីដែលមានភាពចាំបាច់ក្នុងការព្យាបាលជម្ងឺរបស់កូនសុំដែលបានដល់នីតិភាព ការរៀបអាពាហ៍ពិពាហ៍ ឬ គោលបំណងសមស្របផ្សេងទៀត ។ កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ទទួលស្គាល់សិទ្ធិដឹងអំពីប្រភពកំណើតរបស់ខ្លួនរបស់កុមារ ដូច្នេះ បញ្ហាប្រឈមនៅពេលខាងមុខ គឺការថ្លឹងថ្លែងរវាងសិទ្ធិរបស់ឪពុកម្តាយបង្កើតដែលមិនចង់ឱ្យស្គាល់ ឬ ការទាមទារការរក្សាការសម្ងាត់ ជាមួយនឹងសិទ្ធិរបស់កុមារក្នុងការដឹងអំពីអត្តសញ្ញាណរបស់ខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២០៣ នៃក្រមគ្រួសាររដ្ឋកាលីហ្វ័រញ៉ា, កថាខណ្ឌទី ១ មាត្រា ៧ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

## កថាភាគទី ២ សុំកូនធម្មតា

**មាត្រា ១០២០.-** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

(កំណត់)

មាត្រានេះមានគោលបំណងបង្កើតប្រព័ន្ធសុំកូនធម្មតា (សុំកូនសាមញ្ញ) នៅប្រទេសកម្ពុជា ជាទម្រង់ដែលសម្រួលសុំកូនពេញលេញដែលជារបបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់គ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ហើយកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងជាមួយគ្រួសារឪពុកម្តាយបង្កើតនោះ ។ ប្រព័ន្ធសុំកូនធម្មតានេះត្រូវបានបង្កើតឡើង

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង



# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្ដី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្ដី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្ដីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្ដីភាគី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្ដីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្ដីដែលតុលាការបានចាប់ផ្ដើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្ដីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្ដីដោយរួមគ្នា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី)ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឲ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

**មាត្រា ២៥.- ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន**

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

**មាត្រា ២៦.- របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ**

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

## មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

## មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

## មាត្រា ២៩.- ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

## មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរបាន ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

**មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍**

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី**

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

**មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍**

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។

**មាត្រា ៣៧.- ការចូលជាស្ថាពរ និង ការបង្កើតអានុភាពនៃដីកាសម្រេច**

១- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលកំណត់ក្នុងមាត្រា ៤០ (អំឡុងពេលសម្រាប់ប្តឹងជំទាស់) នៃច្បាប់នេះ ។

២- ការចូលជាស្ថាពរនៃដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបង្អាក់ដោយការប្តឹងជំទាស់ ដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះ ។

៣- ដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវមានអានុភាពឡើយ បើមិនទាន់ចូលជាស្ថាពរទេ ។

**មាត្រា ៣៨.- អានុភាពអនុវត្តនៃដីកាសម្រេច**

ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ ប្រគល់វត្ថុ អនុវត្តករណីយកិច្ចចុះបញ្ជី ឬ ផ្តល់តាវកាលិកផ្សេងទៀតដែលចូលជាស្ថាពរ ត្រូវក្លាយជាលិខិតអនុវត្តដែលកំណត់ក្នុងមាត្រា ៣៥០ (លិខិតអនុវត្ត) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៧
## បណ្តឹងឧបាស្រ័យ

**មាត្រា ៣៩.- បណ្តឹងជំទាស់**

១- បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬ ឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ អាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

២- ក្នុងករណីដែលត្រូវចេញដីកាសម្រេចតាមតែពាក្យសុំប៉ុណ្ណោះ មានតែជនដែលបានដាក់ពាក្យសុំទេ ដែលអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន ។

**មាត្រា ៤០.- អំឡុងពេលសម្រាប់ប្តឹងជំទាស់**

១- ប្រសិនបើជនដែលអាចប្តឹងជំទាស់ បានទទួលនូវការជូនដំណឹងអំពីដីកាសម្រេច បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃបានទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ ។

ROYAUME DU CAMBODGE * MINISTÈRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

# ព្រះរាជក្រម

នស/រកម/០៦១០/០០៧

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** គោលដៅនៃច្បាប់នេះ

ច្បាប់នេះ មានគោលដៅបញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ២.-** គោលបំណងនៃច្បាប់នេះ

ច្បាប់នេះ មានគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**មាត្រា ៣.-** វិសាលភាពនៃច្បាប់នេះ

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់

ROYAUME DU CAMBODGE * LE SECRETARIAT DU PALAIS ROYAL

Kol

អំពីអត្ថិភាពនៃមាតុភាពពីម្តាយ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃស្នុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

ញ- បណ្តឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

## ជំពូកទី ២
## ការចូលរួមរបស់តំណាងអយ្យការ

**មាត្រា ៤._** ការអះអាងអង្គហេតុដោយតំណាងអយ្យការ ជាអាទិ៍

ចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលតំណាងអយ្យការបានចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦ (ការចូលរួមរបស់តំណាងអយ្យការ) នៃក្រមនីតិវិធីរដ្ឋប្បវេណី តំណាងអយ្យការនោះ អាចធ្វើការអះអាងអង្គហេតុ ឬ អាចស្នើសុំឱ្យពិនិត្យភស្តុតាងបាន ។

## ជំពូកទី ៣
## តុលាការ

**មាត្រា ៥._** សមត្ថកិច្ច

១- បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

៣- ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ ។

**មាត្រា ៦._** ការផ្ទេរបណ្តឹងដើម្បីចៀសវាងការយឺតយ៉ាវ

ទោះបីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីចៀសវាងការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ជំពូកទី ៤
## ភាគី

**មាត្រា ៧._** ចុងចម្លើយ

១- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

២- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនេះ ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ ត្រូវក្លាយជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

៣- ក្នុងករណីដែលជនដែលត្រូវក្លាយជាចុងចម្លើយនៃបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ទទួលមរណភាព ហើយគ្មានជនណាត្រូវក្លាយជាចុងចម្លើយទេនោះ តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ ។

**មាត្រា ៨._** សមត្ថភាពក្នុងការធ្វើបណ្តឹង ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្តឹងក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង) និង មាត្រា ៣៣ (បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មានបំណងធ្វើសកម្មភាពបណ្តឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

Ksl

៣- ទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មិនដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចបង្គាប់ឱ្យជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីជាអ្នកតំណាងដោយឆន្ទានុសិទ្ធិបាន ។

៤- ចំនួនទឹកប្រាក់នៃកម្រៃដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ត្រូវបង់ឱ្យមេធាវីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំងជាអ្នកតំណាង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជាចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ។

៥- ក្នុងចំណោមកម្រៃនិងសោហ៊ុយដែលបានបង់ឱ្យទៅមេធាវី ដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី៣ខាងលើនេះ ឬ បង់ឱ្យទៅមេធាវីដែលជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹងបានជ្រើសតាំង ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ត្រូវក្លាយជាប្រាក់ប្រដាប់ក្តី ។

**មាត្រា ៩.–** សិទ្ធិអំណាចរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១- ប្រសិនបើជនដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅសម្រាប់ជននោះអាចប្តឹង ឬ អាចត្រូវបានប្តឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅនោះបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកអាណាព្យាបាលទូទៅនោះ ជាភាគីម្ខាងទៀតនៃបណ្តឹងនោះ ។

២- ក្នុងករណីដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅអាចប្តឹង ឬ អាចត្រូវបានប្តឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅបាន ។

## ជំពូកទី ៥
## ប្រាក់ប្រដាប់ក្តី

**មាត្រា ១០.–** ប្រាក់ប្រដាប់ក្តី

ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្តីដែលតំណាងអយ្យការ ត្រូវទទួលបន្ទុកដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់រដ្ឋ ។

Kol

## ជំពូកទី ៦
## នីតិវិធីនៃបណ្តឹង

**មាត្រា ១១.-** ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ អាចធ្វើដោយបណ្តឹងតែមួយបាន ទោះបីមានបញ្ញត្តិមាត្រា ៧៧ (ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ១២.-** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង បណ្តឹងតប

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៤ នៃមាត្រា ៨៤ (ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង) កថាខណ្ឌទី ១ នៃមាត្រា ៨៦ (បណ្តឹងតប) និង មាត្រា ២៧៦ (ការដាក់ពាក្យបណ្តឹងតប) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ នៅក្នុងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន ហើយចុងចម្លើយអាចប្តឹងតបបានរហូតដល់ពេលចប់ ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ១៣.-** បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត

១- មាត្រា ៩៤ (ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ) កថាខណ្ឌទី ១នៃមាត្រា ៩៦ (ការចាត់ទុកថាបានសារភាព) កថាខណ្ឌទី ២ នៃមាត្រា ១៤០ (ការសាកសួរសាមីភាគី) មាត្រា ១៥៣ (អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍) កថាខណ្ឌទី ៤ នៃមាត្រា ១៥៦ (ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ) មាត្រា ២០០ (សាលក្រមកំបាំងមុខដើមចោទ) កថាខណ្ឌទី ២ នៃមាត្រា ២០១ (សាលក្រមកំបាំងមុខចុងចម្លើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ (គោលការណ៍សម្រេចសេចក្តីដោយភស្តុតាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២- បញ្ញត្តិពីមាត្រា ២២០ (ការផ្សះផ្សាលើបណ្តឹង) ដល់មាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

ROYAUME DU CAMBODGE · LE MINISTRE · PALAIS ROYAL

ព្រះបរមរាជវាំង

Ksl

**មាត្រា ១៤._** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគីមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការត្រូវស្ទួរមតិពីភាគីអំពីអង្គហេតុនោះ ។

**មាត្រា ១៥._** ការបង្គាប់ឱ្យសាមីភាគីមកបង្ហាញខ្លួន ជាអាទិ៍

១- នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីដែលត្រូវបានបង្គាប់ឱ្យមកបង្ហាញខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា១៦._** ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដោយធ្វើជាសាធារណៈ ឬ អាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ ។

**មាត្រា ១៧._** វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

Ksl

**មាត្រា ១៨._** ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

១- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ដើមចោទមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែល ដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការបន្ថែម ឬ ការផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារ ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

២- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ចុងចម្លើយមិនអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលស្តីពីទំនាក់ទំនងឋានៈបុគ្គលដដែលដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការដាក់ពាក្យបណ្តឹងតបក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលក្រម ឬ សាលដីកាដែលបានលើកបណ្តឹងចោលដោយហេតុថាបណ្តឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ។

**មាត្រា ១៩._** មរណភាពរបស់ដើមចោទ

ក្នុងករណីដែលដើមចោទនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាព នៅពេលដែលបណ្តឹងនោះកំពុងត្រូវបានចាត់ការ នោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ។

**មាត្រា ២០._** មរណភាពរបស់ចុងចម្លើយ

១- ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល ត្រូវក្លាយជាចុងចម្លើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើភាគីណាមួយទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកភាគីម្នាក់ទៀតនោះមកធ្វើជាចុងចម្លើយ ។ ក្នុងករណីនេះ បញ្ញត្តិនៃចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើចុងចម្លើយទាំងអស់ទទួលមរណភាព បណ្តឹងនេះត្រូវបន្តនីតិវិធី ដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ ។

៣- ក្នុងករណីដែលចុងចម្លើយនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬ កាត់កាល់ ទទួលមរណភាព នៅពេលដែលបណ្តឹងនេះកំពុងត្រូវបានចាត់ការបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។

ROYAUME DU CAMBODGE ROYAL PALAIS
ក្រុមរាជលេខាធិការ

Kol

## ជំពូកទី ៧
## ការចាត់ចែងរក្សាការពារ

**មាត្រា ២១.**_ ការចាត់ចែងរក្សាការពារ

១- ក្នុងករណីដែលមានពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចបង្គាប់ឱ្យធ្វើការរឹបអូសជាបណ្តោះអាសន្ន ការចាត់ចែងជាបណ្តោះអាសន្ន ឬ ការរក្សាការពារផ្សេងទៀតដែលចាំបាច់ ដែលកំណត់ក្នុងគន្ថីទី ៧ (ការចាត់ចែងរក្សាការពារ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយឆន្ទានុសិទ្ធិបាន ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ៥៣២ (ស្ថាប័នចាត់ចែងរក្សាការពារជាបណ្តោះអាសន្ន) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

២- បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនៃមាត្រា ៥៥៨ (ការលុបចោលដីកាសម្រេចរក្សាការពារ ដោយសារការផ្លាស់ប្តូរស្ថានភាព) និង មាត្រា ៥៥៩ (ការលុបចោលដីកាសម្រេចរក្សាការពារដោយសារស្ថានភាពពិសេស) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ជំពូកទី ៨
## ករណីពិសេសនៃបណ្តឹងស្តីពីទំនាក់ទំនងអាពាហ៍ពិពាហ៍

**មាត្រា ២២.**_ សេចក្តីសម្រេចស្តីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍

១-ប្រសិនបើតុលាការចេញសាលក្រម ឬ សាលដីកាដែលទទួលស្គាល់ការទាមទាររបស់ដើមចោទនៅក្នុងបណ្តឹងទាមទារលុបចោលនូវចំណងអាពាហ៍ពិពាហ៍ ឬ លែងលះគ្នា តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិ ហើយបើមានពាក្យសុំរបស់ភាគី ត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ឬ ការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ។

២-ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ តុលាការអាចបង្គាប់ឱ្យភាគីប្រគល់កូន ឬ បង់ប្រាក់ ឬ ផ្តល់តាវកាលិកផ្សេងទៀត ក្នុងសាលក្រម ឬ សាលដីកា ដែលកំណត់ក្នុងកថាខណ្ឌទី ១ នោះបាន។

៣-បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១៨២ (ចំណុចដែលត្រូវវិនិច្ឆ័យដោយសាលក្រម) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ។

៤-នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីអំពីការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងទាក់ទងនឹងការបីបាច់រក្សាកូន ដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ យោបល់របស់កូនត្រូវបានយកទៅពិចារណា ថ្លឹងថ្លែងសមស្របទៅតាមអាយុ និង សភាពចាស់ទុំរបស់កូននោះ ។

Kol

**មាត្រា២៣.**_ ដីកាសម្រេចបង្គាប់ឱ្យអនុវត្ត

១-ក្នុងករណីដែលមានបុគ្គលណាធ្វេសប្រហែសមិនអនុវត្តនូវករណីយកិច្ចដែលមានគោលបំណងឱ្យបង់ប្រាក់ ឬ ឱ្យផ្ដល់តាវកាលិកនូវទ្រព្យសម្បត្តិផ្សេង ដែលកំណត់ដោយសេចក្ដីសម្រេច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ២២ (សេចក្ដីសម្រេចស្ដីពីការចាត់ចែងបន្ទាប់បន្សំ ជាអាទិ៍) ខាងលើនេះ ប្រសិនបើយល់ឃើញថាសមរម្យ តុលាការដែលបានធ្វើការសម្រេចសេចក្ដីនេះ អាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន ។

២- ដើម្បីបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវស្ដាប់សេចក្ដីថ្លែងការណ៍របស់អ្នកមានករណីយកិច្ចនោះ ។

៣- ប្រសិនបើបុគ្គលដែលត្រូវបានបង្គាប់ឱ្យអនុវត្តករណីយកិច្ច ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានធ្វើតាមការបង្គាប់នោះដោយគ្មានមូលហេតុត្រឹមត្រូវ តុលាការដែលបានបង្គាប់ឱ្យអនុវត្តករណីយកិច្ចនោះ អាចបង្គាប់ឱ្យពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដោយដីកាសម្រេចបាន ។

៤- ចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី ៣ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

## ជំពូកទី ៩
## ករណីពិសេសនៃបណ្ដឹងអំពីទំនាក់ទំនងឪពុកម្ដាយ និង កូន (បុត្តភាព)

**មាត្រា ២៤.**_ ភាគីនៃបណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក ជាអាទិ៍

១- ក្នុងករណីដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាពមុនកំណើតរបស់កូន ឬ ក្នុងករណីដែលជននោះបានទទួលមរណភាពក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ២ នៃមាត្រា ៩៩០ (បណ្ដឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) នៃក្រមរដ្ឋប្បវេណី ដោយមិនបានដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬ ញាតិលោហិតផ្សេងទៀត ក្នុង ៣ (បី) ថ្នាក់របស់ជនដែលត្រូវបានសន្មតថាជាឪពុកអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្ដឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលជនត្រូវបានសន្មតថាជាឪពុកនោះបានទទួលមរណភាព ។

២- ក្នុងករណីដែលជនដែលបានត្រូវសន្មតថាជាឪពុក បានទទួលមរណភាពក្រោយពេលបានដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ជនដែលអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាព ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អាចទទួលបន្តនូវនីតិវិធីនៃបណ្ដឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ)ឆ្នាំ គិតពីថ្ងៃដែលជនដែលត្រូវបានសន្មតថាជាឪពុក បានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា

១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៥.-** ភាគីនៃបណ្តឹងបដិសេធបិតុភាពពីកូន ជាអាទិ៍

១- ក្នុងករណីដែលកូនបានទទួលមរណភាព ដោយមិនបានដាក់ពាក្យបណ្តឹងបដិសេធនូវបិតុភាព មុននឹងក្លាយជានីតិជន ឬ ដោយមិនបានដាក់ពាក្យបណ្តឹង ក្នុងអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី បច្ឆាញាតិផ្ទាល់របស់កូនដែលបានទទួលមរណភាពនោះ អាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពបាន ។ ក្នុងករណីនេះ ត្រូវដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។

២- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងបដិសេធបិតុភាព បច្ឆាញាតិផ្ទាល់របស់កូនដែលទទួលមរណភាពនោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះបាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះបានទទួលមរណភាព ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

**មាត្រា ២៦.-** ភាគីនៃបណ្តឹងទាមទារឱ្យទទួលស្គាល់ ជាអាទិ៍

១- នៅក្នុងបណ្តឹងទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្តឹង ដោយយកឪពុកមកជាចុងចម្លើយ ។ ក្រោយមរណភាពរបស់ឪពុក ត្រូវយកតំណាងអយ្យការមកជាចុងចម្លើយ ។

២- ប្រសិនបើឪពុកដែលជាចុងចម្លើយ ទទួលមរណភាព នៅពេលដែលតុលាការកំពុងចាត់ការបណ្តឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ ។

៣- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្តឹងនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព ទោះបីអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៥ នៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី បានកន្លងផុតក៏ដោយ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាកនិងការទទួលបន្តនូវនីតិវិធីនៃបណ្តឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ២៧.-** គោលការណ៍នៃវិធានការអន្តរកាល

១- ច្បាប់នេះត្រូវអនុវត្តចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យ បណ្តឹងត្រូវបាន

ដាក់ក្រោយពេលដែលច្បាប់នេះត្រូវបានអនុវត្ត ។

២- ចំពោះរឿងក្តីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត ត្រូវអនុលោមតាមកិច្ចការដែលបានធ្វើពីមុនមក ទោះបីមានបញ្ញត្តិស្តីពីការធ្វើវិសោធនកម្មនូវច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ២៨.–** ការមិនអនុវត្តបញ្ញត្តិស្តីពីការហាមមិនឱ្យដាក់ពាក្យបណ្តឹងក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

បញ្ញត្តិនៃមាត្រា ១៨ (ការហាមមិនឱ្យដាក់ពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរ) នៃច្បាប់នេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាលក្រម ឬ សាលដីកានៃរឿងក្តីដែលពាក្យបណ្តឹងត្រូវបានដាក់មុនពេលដែលច្បាប់នេះត្រូវបានអនុវត្ត បានចូលជាស្ថាពរ ។

## ជំពូកទី ១១
## អវសានបញ្ញត្តិ

**មាត្រា ២៩.–** ការអនុវត្តច្បាប់នេះ

ច្បាប់នេះ ត្រូវអនុវត្តចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ។

**មាត្រា ៣០.–** អានុភាពនៃបញ្ញត្តិដែលមានភាពផ្ទុយពីច្បាប់នេះ

បញ្ញត្តិនៃច្បាប់ផ្សេងទៀត ដែលមានអានុភាពនៅពេលច្បាប់នេះត្រូវបានអនុវត្ត ហើយផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងច្បាប់នេះ ចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី០៤ ខែមិថុនាឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ព.ស. ១០០៦.៤៩៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍានា

លេខ: ៤៤០ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

13/3/12

# ច្បាប់

# ស្តីពី

# អាពាហ៍ពិពាហ៍ និងគ្រួសារ

Khmer Law's Association

**មាត្រា ១០៥**- តុលាការប្រជាជន ត្រូវបង្គាប់ឱ្យឪពុក ឬ ម្តាយផ្តល់អាហារកិច្ចឱ្យកូនជាដរាប តាមសមាមាត្រនៃធនធានរបស់ឪពុក ឬ ម្តាយនោះ ។

អាហារកិច្ចនេះ ត្រូវផ្តល់ឱ្យកូនតាមការកំណត់នៃសាលក្រម រហូតដល់កូននោះ មាននីតិភាព ។

ឪពុក ឬ ម្តាយអាចត្រូវរួចពីកាតព្វកិច្ចនេះបាន បើខ្លួនព្រមទទួលយកកូននោះទៅចិញ្ចឹមបីបាច់រក្សា ។

**មាត្រា ១០៦**- សាលក្រមដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា អាចនឹងបង្ខំឱ្យឪពុកសងសោហ៊ុយសំរាលកូន និង ប្រាក់ចំណាយចិញ្ចឹមបីបាច់រក្សាកូនតាំងពីថ្ងៃដែលកូននោះកើតមក ទៅម្តាយនៃកូននោះបាន ។

**មាត្រា ១០៧**- កំណត់ដៃមួយច្បាប់នៃសាលក្រមស្ថាពរដែលកាត់សេចក្តីឱ្យទទួលស្គាល់កូនឥតខាន់ស្លា ត្រូវផ្ញើទៅមន្ត្រីអត្រានុកូលដ្ឋាន នៃទីកន្លែងដែលកូននោះកើត ដើម្បីនិទ្ទេសអំពីបុគ្គភាពនេះ នៅរឹមទំព័រនៃសំបុត្រកំណើត ។

## ផ្នែកទី ៤

## អំពីសុំកូន

**មាត្រា ១០៨**- សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀត ហៅថា កូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុគ្គភាពមានខាន់ស្លា ។

**មាត្រា ១០៩**- ឪពុក ឬ ម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី ២៥ ឆ្នាំ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ ឆ្នាំ ។ ឪពុក ឬ ម្តាយចិញ្ចឹមអាចជាពលរដ្ឋកម្ពុជា ឬ ជនបរទេស ។

**មាត្រា ១១០**- គេអាចសុំកូនបានត្រឹម ២ នាក់ប៉ុណ្ណោះ ។ ប្រសិនបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន ។

-កូនចិញ្ចឹម ត្រូវមានអាយុតិចជាង ៨ ឆ្នាំ ។

**មាត្រា ១១១**- សហព័ទ្ធណាមួយអាចនឹងសុំកូនយកមកចិញ្ចឹមបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។

ក្នុងករណីនេះ កូនចិញ្ចឹមត្រូវទុកជាកូនចិញ្ចឹមរបស់សហព័ទ្ធទាំងពីរនាក់ ។

**មាត្រា ១១២**- ដើម្បីឱ្យការសុំកូនសំរេចទៅបានត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលនៃកូនដែលសុំនោះ ។

បើជាទារកដែលគេបោះបង់ចោល ត្រូវមានការយល់ព្រមពីរដ្ឋអំណាចឃុំ ឬ សង្កាត់ ។

## រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

ក្រុមប្រឹក្សារដ្ឋ

លេខ : ៥៦ ក្រ.

# ក្រឹត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ក្រ. ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

ប្រកាសអោយប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៨៩ នាសម័យប្រជុំសាមញ្ញលើកទី ១៧ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា : **ហេង សំរិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយ

# ស្ដីពី

# ការថែទាំជំនួសចំពោះកុមារ

ខែមេសា ឆ្នាំ២០០៦

លើការលើកស្ទួយដំណោះស្រាយនានានៅតាមគ្រួសារ និង សហគមន៍ ។

ឆ. ជួយលើកស្ទួយគោលការណ៍ស្តីពីការថែទាំជំនួស តាមរយៈគោលនយោបាយសំរាប់បុគ្គលិក ( តួនាទី ការទទួលខុសត្រូវ ការជ្រើសរើសបុគ្គលិក ការបណ្តុះបណ្តាល បៀវត្សរ៍ និងការគ្រប់គ្រង ) និង គោលនយោបាយទាក់ទងដល់ការទទួលយកកុមារមកចិញ្ចឹមថែទាំ (ក្រុមគោលដៅ លក្ខណៈវិនិច្ឆ័យ និង នីតិវិធីផ្សេងៗ ) ។

ជ. ចូលរួមចំណែកក្នុងការសំរបសំរួលនានា ជាមួយបណ្តាអង្គការសង្គមស៊ីវិល និង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

## VIII. និយមន័យ និង បញ្ហាពាក់ព័ន្ធទៅនឹងប្រភេទពិសេសនៃភាពងាយរងគ្រោះ

មានបរិបទជាច្រើន ដែលអាចធ្វើអោយមានគ្រោះថ្នាក់ដល់កុមារដែលត្រូវការ ការថែទាំជំនួស ។ ស្ថានភាពខ្លះ អាចធ្វើអោយកុមារងាយរងគ្រោះ ដោយសារតែ ពុំមានឪពុកម្តាយ ឬ អ្នកអាណាព្យាបាលនៅជាមួយ ឬ ក៏ ឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ពុំអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ឧទាហរណ៍ កុមារកំព្រា កុមារញៀនសារធាតុញៀន និង កត្តាផ្សេងៗទៀត ដែលអាចធ្វើអោយបាត់បង់អំណាចមេបា ឬ ក៏ ត្រូវអាជ្ញាធរមានសមត្ថកិច្ចដកអំណាចមេបា ។

### ១. កុមារកំព្រា

និយមន័យរបស់ពាក្យថា កុមារកំព្រា គឺ " កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ បានទទួលមរណភាព "[៣] ។

យោលទៅតាមនិយមន័យនេះ ចំនួនសរុបនៃកុមារកំព្រា គឺជាចំនួនកុមារដែលកំព្រាម្តាយ និងកុមារកំព្រាឪពុក ដកចេញកុមារកំព្រា ទាំងឪពុក ទាំងម្តាយ ដែលគេបានរាប់បញ្ចូលក្នុងក្រុមទាំងពីរខាងលើ ។

### ២. កុមារមានទំនាស់ជាមួយច្បាប់

កុមារមានទំនាស់ជាមួយច្បាប់ គឺជាកុមារដែលត្រូវបានសង្ស័យ ត្រូវបានចោទប្រកាន់ ឬ ត្រូវបានកាត់អោយជាប់ទោសពីបទបានប្រព្រឹត្តបទឧក្រិដ្ឋ ( មិនថាជាបទល្មើសកំរិតធ្ងន់ ឬ បទល្មើសមធ្យមនោះឡើយ ) ។ កុមារដែលមានទំនាស់ជាមួយច្បាប់ ហើយដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារ ឬ ត្រូវបានដាក់នៅក្នុងមណ្ឌលអប់រំកែប្រែអនីតិជន អាចជា កុមារដែលត្រូវបានឃុំខ្លួនមុនកាត់ទោស (ជាកុមារដែលត្រូវបានបញ្ជូនត្រឡប់មកឃុំខ្លួនវិញរង់ចាំការកាត់ទោស ) ឬជាកុមារដែលត្រូវបានកាត់ទោសរួចហើយ ។ ដោយសារតែ មានការខ្វះខាតមណ្ឌលអប់រំកែប្រែអនីតិជន កុមារមួយចំនួនដែលត្រូវបានកាត់អោយជាប់ទោស ឬ ដែលត្រូវបានបញ្ជូនត្រឡប់មកឃុំខ្លួនវិញ រង់ចាំការកាត់ទោស ត្រូវបានឃុំខ្លួនរួមគ្នាជាមួយនឹង

អ្នកទោស ដែលជាមនុស្សពេញវ័យដែរ ។  ការឃុំកុមារបែបនេះ ធ្វើអោយប៉ះពាល់ដល់សិទ្ធិកុមារក្នុងការ ទទួលបានការថែទាំសមស្រប ។

### ៣.   កុមាររស់នៅក្នុងគ្រួសារក្រីក្រ

គ្រួសារដែលក្រីក្របំផុត ពុំមានលទ្ធភាពផ្ដល់ការថែទាំសមស្របសំរាប់កុមារនៅក្នុងគ្រួសាររបស់ខ្លួនទេ ។ នៅពេលជួបប្រទះបញ្ហា ដូចជា បញ្ហាសុខភាព គ្រោះថ្នាក់ផ្សេងៗ  អាចធ្វើអំពើអ្វីមួយមិនសមស្របចំពោះកូន ដូចជា បោះបង់ចោល ធ្វើអាជីវកម្មកុមារជាកូនរបស់ខ្លួន លក់ ឬ ជួលទៅអោយអ្នកជួញដូរ ។ ក្នុងករណីនេះ កុមារអាចរត់គេចពីផ្ទះ ។

### ៤.   កុមារពិការ

“ ជនពិការសំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាត សរីរាង្គណាមួយ ឬ សតិបញ្ញា បណ្ដាលអោយមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃ ដូចជា ជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្ដាប់ ពិការសតិបញ្ញា និង ប្រភេទពិការផ្សេងៗទៀត  ដែលនាំអោយមានលក្ខណៈមិនប្រក្រតី  និង មានលិខិតបញ្ជាក់ចេញដោយ ក្រសួងទទួលបន្ទុកវិស័យសុខាភិបាល ” [ទិ១] ។ អង្គការសុខភាពពិភពលោកបានអោយនិយមន័យ ពិការភាព គឺជាការមានកំរិត ឬ ខ្វះលទ្ធភាពដោយសារតែ  ជនពិការមិនអាចធ្វើអ្វីមួយបានប្រចាំថ្ងៃដូចមនុស្សធម្មតា  ។ ប្រភេទនៃពិការភាពទាក់ទងទៅនឹងអាកប្បកិរិយាប្រព្រឹត្ត  ការប្រាស្រ័យទាក់ទង ការថែទាំខ្លួន  ការចល័ត  ភាពប៉ិនប្រសប់  និង មុខជំនាញពិសេស ។ ពាក់ព័ន្ធទៅនឹងការថែទាំជំនួស ជាទូទៅ កុមារពិការអសមត្ថភាពតែងតែ ទទួលបានការថែទាំនៅតាមមណ្ឌល ព្រោះម្យ៉ាងដោយសារកុមារពិការជាមនុស្សដែលងាយត្រូវបោះបង់ចោល ហើយមិនសូវមានក្រុមគ្រួសារ ឬសហគមន៍គិតគូរយកមកអោយរស់នៅ និង ផ្ដល់ការថែទាំនោះឡើយ ។

### ៥.   កុមារទទួលផលប៉ះពាល់  ឬ  ផ្ទុកមេរោគអេដស៍  ឬ  មានជំងឺអេដស៍

ទោះជា  មានកុមារត្រឹមមួយចំនួនតូចប៉ុណ្ណោះ  ទទួលរងផលប៉ះពាល់ពី  មេរោគអេដស៍ ឬ ជំងឺអេដស៍ ប៉ុន្តែ ការឆ្លងរាលដាលនៃមេរោគ  និង ជំងឺអេដស៍   និង ការស្លាប់បាត់បង់ជីវិតរបស់ឪពុកម្ដាយដោយសារមេរោគ និង ជំងឺអេដស៍ កំពុងតែបង្កអោយមានការកើនឡើង នូវចំនួនកុមារកំព្រា និង កុមាររស់នៅក្នុងក្រុមគ្រួសារដែលមានកុមារជាមេគ្រួសារ ។ ទោះបីជា ឪពុកម្ដាយនៅមានជីវិតរស់នៅឡើយក៏ដោយ ក៏ការចំណាយទៅលើបញ្ហាសុខភាពបានប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ក្រុមគ្រួសារ ហើយកុមារដែលថែទាំឪពុកម្ដាយឈឺ អាចនឹងបោះបង់សាលារៀនផងដែរ ។ ម្យ៉ាងទៀត  សេចក្ដីត្រូវការខាងផ្លូវចិត្ត  និង

អារម្មណ៍របស់កុមារ ដែលបានទទួលផលប៉ះពាល់ ដោយសារ មេរោគ និង ជំងឺអេដស៍ មានច្រើន ដូច សេចក្តីត្រូវការខាង ការហូបចុក ការអប់រំ ការថែទាំសុខភាព ឬ ជំរក....។ ដើម្បីអោយកុមារដែលបាន ទទួលផលប៉ះពាល់ដោយសារមេរោគ និងជំងឺអេដស៍ មានឱកាសល្អៗ ដូចគ្នានឹងកុមារឯទៀតៗដែរនោះ ចាំបាច់ត្រូវទទួលស្គាល់សេចក្តីត្រូវការទាំងនេះ ។ វិធីដោះស្រាយនានា នៅតាមសហគមន៍មានប្រសិទ្ធិ ភាពណាស់ក្នុងការបង្កើតជាបណ្តាញសុវត្ថិភាព និង ការគាំទ្រចំពោះករណីមួយចំនួនធំ ប៉ុន្តែ ជាចាំបាច់ គឺត្រូវពង្រឹងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ។

## ៦. កុមារទទួលផលប៉ះពាល់ដោយសារអំពើហិង្សាក្នុងគ្រួសារ

កុមារដែលទទួលផលប៉ះពាល់ ដោយសារអំពើហិង្សាក្នុងគ្រួសារ អាចមានអារម្មណ៍ពាក់ព័ន្ធគ្នាជា មួយនឹងអាកប្បកិរិយា ដូចជា ÷

- ភ័យខ្លាចពេលឃើញឪពុកម្តាយឈ្លោះប្រកែកគ្នាម្តងៗ
- គ្មានអំណាចឥទ្ធិពល និង គិតថាខ្លួនមានពិរុទ្ធ ដោយសារខ្លួនពុំមានលទ្ធភាពបញ្ឈប់ អំពើហិង្សា ដែលខ្លួនបានឃើញជាក់ស្តែងនោះបាន
- បាត់បង់ការផ្តោតអារម្មណ៍រៀនសូត្រនៅសាលារៀន
- អាចប្រព្រឹត្តអំពើហិង្សា ដោយធ្វើតាមអ្វី ៗ ដែលបានសង្កេតឃើញនៅផ្ទះ
- ចិត្តមិនស្ងប់
- យល់សុបិនអាក្រក់ ដេកពុំលក់
- ក្រៀមក្រំ និង ធ្លាក់ទឹកចិត្ត ។

អំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុច្រើនដែលធ្វើអោយកុមាររត់ចេញពីផ្ទះហើយក៏អាចជាបញ្ហា នាំអោយអាជ្ញាធរនានា ដកសិទ្ធិអំណាចមេបា និង ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំ ជំនួសវិញផងដែរ ។

## ៧. កុមារទទួលផលប៉ះពាល់ដោយសារធាតុញៀន និង អំពើអបាយមុខ

ការញៀន និង អំពើអបាយមុខ នៅក្នុងគ្រួសារ ទោះជា គ្រឿងស្រវឹង ថ្នាំញៀន ឬ ជាល្បែងស៊ី សងក៏ដោយ ក៏ធ្វើអោយកុមារមានគ្រោះថ្នាក់បានដែរតាមរូបភាពជាច្រើន ។ ការញៀន ទោះជា មនុស្ស ពេញវ័យ ទោះជា កុមារក៏ដោយ ក៏វានៅតែប៉ះពាល់ដល់សុខភាពដូចគ្នាដែរ ហើយព្រមទាំង បង្កអោយ មានការញៀនផ្នែករាងកាយ ដែលភាគច្រើនៗតែ ធ្វើអោយខូចដល់ផ្លូវចិត្ត និង កាយ ។ ដូចជា ស្រា ឬ ថ្នាំញៀន ការលេងល្បែងស៊ីសង ក៏នាំអោយមនុស្សញៀនដែរ ហើយ បានធ្វើអោយក្រុមគ្រួសារទាំងមូល ធ្លាក់ខ្លួនជំពាក់បំណុលគេជាច្រើនលើកច្រើនគ្រាបន្តបន្ទាប់គ្នា ដែលជាការប៉ះពាល់ដល់ជីវភាពរស់នៅ

និង ប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ។ ស្រា ថ្នាំញៀន និង ការលេងល្បែងស៊ីសង អាចបង្កអោយមាន ជំលោះ និង អំពើហឹង្សាក្នុងគ្រួសារ ដែលគំរាមកំហែងសមាជិកគ្រួសារទាំងមូល ។ លើសពីនេះទៀត ស្ថានភាពបែបនេះ អាចបង្កអោយគ្រួសារទាំងមូលបញ្ចាំ ឬ លក់ដូរមធ្យោបាយបង្កបង្កើតផល ដើម្បី បំពេញសេចក្តីត្រូវការនៃការញៀន ដែលរឹងរឹតតែធ្វើអោយអន្តរាយថែមទៀតដល់ជីវភាពរស់នៅរបស់ គ្រួសារ ។ ក្នុងករណីនេះ ឳពុកម្តាយអាចឈានទៅលក់ កូនបង្កើតរបស់ខ្លួន ។

## ៨. កុមារអនាថាតាមចិញ្ចើមថ្នល់

ពាក្យថា កុមារអនាថាតាមចិញ្ចើមថ្នល់គ្របដណ្តប់ស្ថានភាពផ្សេងៗ គ្នាជាច្រើន ÷

- កុមារដែលរស់នៅតាមចិញ្ចើមថ្នល់ ជាទូទៅ ច្រើនតែផ្តាច់ការទាក់ទង ជាមួយក្រុមគ្រួសារ របស់ខ្លួន និង រស់នៅដោយគ្មានអ្នកគ្រប់គ្រងនៅតាមចិញ្ចើមថ្នល់ ។
- កុមារធ្វើការងារនៅតាមចិញ្ចើមថ្នល់ បានចំណាយពេលវេលាយ៉ាងច្រើននៅតាមចិញ្ចើមថ្នល់ ដើម្បី រកប្រាក់ផ្តល់អោយក្រុមគ្រួសាររបស់ខ្លួន ឬ សំរាប់ផ្គត់ផ្គង់ខ្លួនឯង ។ ជាទូទៅ កុមារ អនាថាតាមចិញ្ចើមថ្នល់ប្រភេទនេះ តែងតែវិលត្រឡប់ទៅផ្ទះវិញនៅពេលយប់។
- កុមារ ដែលជាកូនចៅរបស់ក្រុមគ្រួសាររស់នៅតាមចិញ្ចើមថ្នល់ តែងតែរស់នៅ ជាមួយក្រុម គ្រួសាររបស់គេនៅតាមចិញ្ចើមថ្នល់ ។

មូលហេតុដែលនាំអោយពួកគេមករស់នៅតាមចិញ្ចើមថ្នល់ គឺភាពក្រីក្រនៅទីជនបទ អំពើហឹង្សា ក្នុងគ្រួសារ ឬ ការរៀបអាពាហ៍ពិពាហ៍ថ្មីទៀត ជាដើម ។

កុមារអនាថា ទោះជា មានការគាំទ្រតាមកំរិត ដែលឳពុកម្តាយបានផ្តល់អោយក៏ដោយ ក៏កុមារ ទាំងអស់នោះ អាចទទួលផលប៉ះពាល់ផ្ទាល់ និង មានគ្រោះថ្នាក់ ខាងរូបរាងកាយ និង ផ្លូវចិត្តដែរ ដែល ក្នុងនោះ រួមមាន អំពើហិង្សា ការលេងល្បែងស៊ីសង ការប្រព្រឹត្តបទល្មើសផ្សេងៗ ការញៀន ការជួញដូរ និង ពេស្យាចារ ដែល ចាំបាច់ត្រូវពិនិត្យពិចារណា ដើម្បីកំណត់អន្តរាគមន៍អោយមានប្រសិទ្ធភាព ។

## ៩. កុមារត្រូវបានរំលោភបំពាន

កុមារត្រូវបានរំលោភបំពានរួមមាន ÷

- កុមារា ឬ កុមារី ត្រូវបានធ្វើបាបធ្ងន់ធ្ងរលើរូបរាងកាយ ឬ ផ្លូវអារម្មណ៍ ។
- កុមារា ឬកុមារី គឺជាជនរងគ្រោះដោយសារអំពើរំលោភធ្វើបាបផ្លូវភេទ ដូចជា ករណីរំលោភ សេពសន្ថវៈ ស្មន្នការ ការបង្ហាញកេ្តីខ្មាសដល់កុមារ ឬ ទំនាក់ទំនងផ្លូវភេទជាមួយមនុស្ស ពេញវ័យ ។ ការដែលមនុស្សពេញវ័យចូលចិត្តរួមរក្សជាមួយកុមារ និង ការប្រព្រឹត្តអំពើអនា

ចារ គឺជា រូបភាពនៃការរំលោភផ្លូវភេទមួយ ដែលមានមនុស្សពេញវ័យជាអ្នក ប្រព្រឹត្តទៅលើកុមារអាយុពុំទាន់ពេញវ័យ ។

ការរំលោភបំពានលើកុមារ ជាមូលហេតុមួយ ដែលច្រើនធ្វើអោយកុមាររត់ចេញពីផ្ទះ ហើយក៏អាចជាបញ្ហានាំអោយអាជ្ញាធរនានាដកសិទ្ធិអំណាចមេបា ពីឪពុកម្តាយ ហើយ ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំជំនួសវិញផងដែរ ។

## ១០. កុមារត្រូវបានកេងប្រវ័ញ្ច

កុមារត្រូវបានកេងប្រវ័ញ្ចរួមមាន ÷

- កុមារា ឬ កុមារី ជាជនរងគ្រោះនៃអំពើកេងប្រវ័ញ្ចផ្លូវភេទ ដូចជា ក្នុងករណី ពេស្យាចារ ឬការពាក់ព័ន្ធក្នុងអាជីវកម្មរូបអាសអាភាស ។ ការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើកុមារ គឺ សំដៅលើមនុស្សពេញវ័យ ដែលប្រើប្រាស់ផ្លូវភេទកុមារ ដោះដូរជាមួយ នឹងប្រាក់កាស ឬរបស់របរ ជាមួយ កុមារផ្ទាល់ ឬ ជាមួយមនុស្សទីបីណាម្នាក់ ។
- ពលកម្មកុមារ គឺ សំដៅលើរយៈពេលដែលកុមារ ធ្វើការងារច្រើនម៉ោងក្នុងមួយថ្ងៃៗ ប៉ុន្តែទទួលបានប្រាក់កំរៃតិចក្រោមលក្ខខណ្ឌការងារ ដែលអាចបង្កគ្រោះថ្នាក់ ដល់ការអភិវឌ្ឍន៍រូបរាងកាយ និង ផ្លូវចិត្តរបស់កុមារ ដែលរារាំងកុមារមិនអោយទទួលបានការអប់រំរៀនសូត្រ ។ ការងារបែបនេះ ត្រូវចាត់ទុកថា មានផលប៉ះពាល់ដល់ការអភិវឌ្ឍន៍ រូបរាងកាយ បញ្ញាផ្លូវចិត្ត និង សង្គមរបស់កុមារ ។ ការងារនេះ ធ្វើអោយកុមារ បែក ពីក្រុមគ្រួសារ និង ប៉ះពាល់ ដល់អនាគតរបស់កុមារ ។ ( មានចែងក្នុងអនុសញ្ញាលេខ១៨២របស់អង្គការពលកម្មអន្តរជាតិ និងប្រកាសលេខ ១០៦ សកបយ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់ ) ។
- កុមារា ឬ កុមារី ត្រូវបានកេងប្រវ័ញ្ចពលកម្ម រួមមាន កុមារដែលមិនត្រូវបានអនុញ្ញាតិអោយរៀនសូត្រដើម្បីអោយធ្វើការនៅតាមស្រែ ចំការ ឬ ធ្វើការងារក្នុងផ្ទះអោយសាច់ញាតិ ជាដើម ។ ដូចគ្នានឹង នៅតាមបណ្តាប្រទេសជាច្រើនដែរ គឺ ប្រពៃណី និង ទំនៀមទំលាប់របស់កម្ពុជា ច្រើនអនុគ្រោះ ហើយលើកទឹកចិត្តដល់កុមារ ដែលរួមចំណែកជួយដល់ការងារក្នុងផ្ទះ ឬ នៅផ្ទះ ។ ការរួមចំណែកដល់ជីវភាពរស់នៅរបស់គ្រួសារបែបនេះ ត្រូវទទួលបានការសរសើរ និង ជាផ្នែកមួយដ៏សំខាន់សំរាប់កុមារចូលរួម និង យល់ដឹងពីសង្គមជាតិ និង ជាមធ្យោបាយមួយដើម្បីផ្ទេរជំនាញ ដែលទទួលបានពីមនុស្សជំនាន់មួយទៅជំនាន់មួយទៀត ។

ករណីនេះ មិនចាត់ទុកជាអំពើកេងប្រវ័ញ្ចពលកម្មកុមារទេ ល្គីកណា កុមារបានទទួលការអប់រំរៀនសូត្រ និង មិនប៉ះពាល់ការអភិវឌ្ឍន៍ រូបរាងកាយ បញ្ញា ផ្លូវចិត្ត និង សង្គម របស់កុមារ ។

- កុមារា កុមារី ត្រូវបានជួញដូរ ។ ការជួញដូរ គឺជា " ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់ជំរកលាក់ខ្លួន ឬ ការទទួលមនុស្សដោយប្រើមធ្យោបាយគំរាមកំហែង ដោយការប្រើប្រាស់កំលាំង ឬ ការប្រើប្រាស់ទម្រង់ផ្សេងៗទៀត នៃការបង្ខិតបង្ខំ ដូចជា ការចាប់ពង្រត់ ការឆបោក ការបំភ័ន្តបោកប្រាស់ ការរំលោភបំពានដោយអំណាច ឬ លើស្ថានភាពដែលងាយរងគ្រោះ ឬ ការប្រគល់ ឬ ទទួលប្រាក់ ឬ ផលប្រយោជន៍ផ្សេងៗ ដើម្បីទទួលបានការយល់ព្រម ពីជនណាម្នាក់ដែលគ្រប់គ្រងលើមនុស្សម្នាក់ទៀត ក្នុងគោលបំណងធ្វើការកេងប្រវ័ញ្ច ។ ការកេងប្រវ័ញ្ច រួមមាន ការកេងប្រវ័ញ្ចអ្នកដទៃ តាមរយៈ ពេស្យាចារ ឬ ទម្រង់ផ្សេងៗទៀត នៃការកេងប្រវ័ញ្ចផ្លូវភេទ ពលកម្មបង្ខិតបង្ខំ ឬ សេវាបង្ខិតបង្ខំ ទាសករដាច់ថ្លៃ ឬ ការអនុវត្តន៍នានា ដែលមានលំនាំ ដូចជា ទាសករដាច់ថ្លៃ សេវគតិភាព ឬ ការកាត់យក សរីរាង្គណាមួយ ។ ករណីខាងលើនេះ ទោះបីមានការយល់ព្រមរបស់ជនរងគ្រោះក៏ដោយ ក៏ចាត់ទុកជា អំពើជួញដូរកុមារ ដែរ "[៣៣] ។

អំពើកេងប្រវ័ញ្ចកុមារ ជាមូលហេតុមួយ ធ្វើអោយកុមាររត់ចេញពីផ្ទះ ហើយក៏ អាចជាបញ្ហានាំអោយអាជ្ញាធរដកសិទ្ធិអំណាចមេបា ពី ឪពុកម្តាយ ហើយ ផ្ទេរសិទ្ធិអំណាចនេះ ទៅអោយអ្នកដទៃជាអ្នកថែទាំជំនួសវិញផងដែរ ។

**រដ្ឋមន្ត្រី**